# យន្តការដែលមានស្រាប់ដើម្បីឆ្លើយតប នឹងអំពើពុករលួយ




ស្អាតស្អំ

រួមគ្នាប្រឆាំងអំពើពុករលួយ

ផលិតដោយៈ

BUILDING
CAPACITY
WORLDWIDE
Pact Cambodia

ឧបត្ថម្ភដោយៈ

DANIDA

**យន្តការដែលមានស្រាប់ ដើម្បីឆ្លើយតបនឹងអំពើពុករលួយ**

© មករា ២០០៧

យើងលើកទឹកចិត្តឱ្យលោកអ្នក ថតចម្លងផ្នែកណាមួយ ឬផ្នែកទាំងអស់នៃសៀវភៅនេះ និងចែកចាយទៅអ្នកដទៃទៀត ។

# មាតិការឿង


I. សេចក្តីសង្ខេប....1

II. សេចក្តីផ្តើម ....5

III. បទឧក្រិដ្ឋ និង នីតិវិធីព្រហ្មទណ្ឌ 7

ក. បទល្មើសព្រហ្មទណ្ឌ ....7

១. អំពើពុករលួយ (ច្បាប់អ៊ុនតាក់ មាត្រា ៣៨) ....8

២. ការសូកប៉ាន់ (ច្បាប់អ៊ុនតាក់ មាត្រា ៥៨) ....9

៣. ការគៃបំបាត់ធ្វើឡើងដោយអ្នករដ្ឋការ (ច្បាប់អ៊ុនតាក់ មាត្រា ៣៧) .... 10

៤. ការក្លែងឯកសារសាធារណៈ (ច្បាប់អ៊ុនតាក់ មាត្រា ៤៩) .... 11

៥. ការរំលោភបំពានដោយមន្ត្រីពន្ធដារ (ច្បាប់ស្តីពីសារពើពន្ធ មាត្រា ១៣៩).... 112

ខ. នីតិវិធីព្រហ្មទណ្ឌ .... 13

គ. ការអនុវត្តជាក់ស្តែងក្នុងការជំនុំជំរះបទល្មើសអំពើពុករលួយ ....16

IV. ដំណើរការនីតិវិធីផ្នែករដ្ឋបាល....18

ក. មន្ត្រីរាជការស៊ីវិល....19

ខ. ចៅក្រម និងព្រះរាជអាជ្ញា....21

គ. មន្ត្រីនគរបាល....24

ឃ. មន្ត្រីយោធា ....27

ង. មន្ត្រីថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ....28

១. ថ្នាក់ខេត្ត....28

២. ថ្នាក់ស្រុក និងការិយាល័យអំប៉ូដស់មែន ....29

៣. ថ្នាក់ឃុំ និងក្រុមការងារគណនេយ្យភាព....30

ច. អាជ្ញាធរសវនកម្មជាតិ និងនាយកដ្ឋានសវនកម្មនៅតាមក្រសួងនានា....32

ឆ. រដ្ឋសភា....34

ជ. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ......................................35
ឈ. អង្គភាពប្រឆាំងនឹងអំពើពុករលួយ.........................................................................37
ញ. មេធាវី ...................................................................................................................38
V. យន្តការមិនផ្លូវការ...................................................................................................39
ក. ការឆ្លើយតបជាបុគ្គលចំពោះអំពើពុករលួយ.............................................................40
ខ. ការឆ្លើយតបជាសមូហភាពចំពោះអំពើពុករលួយ.......................................................42
VI. សេចក្តីសន្និដ្ឋាន .....................................................................................................44

## I. សេចក្តីសង្ខេប

អំពើពុករលួយគឺជាបញ្ហាមួយដ៏ធំសំរាប់ប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលទទួលស្គាល់បញ្ហានេះ ហើយបានបញ្ចូលការប្រយុទ្ធប្រឆាំងអំពើពុករលួយ ជាផ្នែកមួយដ៏សំខាន់នៃផែនការរបស់ខ្លួនសំរាប់ការរីកចំរើនប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។ទាំងសហគមន៍ម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលបាន និងកំពុងផ្តោតការយកចិត្តទុកដាក់ទៅលើការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ដែលជាចំណុចរួមនៃកិច្ចប្រឹងប្រែងនេះ។ តែទោះជាយ៉ាងនេះក្តី យន្តការមួយចំនួនមានរួចទៅហើយ ដែលយើងអាចយកទៅប្រើបានសំរាប់ការប្រឆាំងអំពើពុករលួយ។

ប្រទេសកម្ពុជាមានច្បាប់ព្រហ្មទណ្ឌ (ជាពិសេស គឺច្បាប់អ៊ុនតាក់ ) ដែលបានហាមឃាត់ សកម្មភាពដែលទាក់ទងនឹងអំពើពុករលួយ ដែលក្នុងនោះមានការស៊ីសំណូក អំពើសូកប៉ាន់ និងការគៃបំបាត់។ វាគឺជារឿងល្មើសច្បាប់ នៅពេលដែលមន្ត្រីរដ្ឋាភិបាលទៅរែអង្គាស សុំ ឬទទួលប្រាក់ (ឬផលប្រយោជន៍ផ្សេងទៀត ) ជាថ្នូរនឹងការប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីផ្តល់ជាប្រយោជន៍ណាមួយ។ដូចគ្នានេះ ដែរវាជាការល្មើសច្បាប់សំរាប់សាធារណជនទាំងឡាយដែលផ្តល់ប្រាក់ (ឬផលប្រយោជន៍ផ្សេងទៀត) ឱ្យទៅមន្ត្រីរាជរដ្ឋាភិបាលជាថ្នូរនឹងការទទួលបាននូវផលប្រយោជន៍ណាមួយ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ គេមិនដែលឃើញមានការកាត់ទោសពីបទល្មើសពុករលួយឡើយ ប៉ុន្តែកាលពីពេលថ្មីៗនេះ ការជំនុំជំរះបែបនេះបានកើតឡើង។ ថ្វីបើការផ្តន្ទាទោសបានផ្តោតទៅលើតែមន្ត្រីថ្នាក់ក្រោម ដូចជាឧទ្យានុរក្ស និងនគរបាលព្រំដែនក៏ដោយ ជាការពិតវាក៏ជាជំហានមួយប្រសើរដែរ បើប្រៀបធៀបនឹងអតីតកាល។ យើងសង្ឃឹមថាការកាត់ទោសនេះ គឺជាជំហានដំបូងឆ្ពោះទៅរកយុទ្ធនាការទូលំទូលាយមួយដើម្បីផ្តន្ទាទោសអំពើពុករលួយ។

ក្រៅពីច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា មាននីតិវិធីរដ្ឋបាលជាច្រើន ដែលអាចយកទៅប្រើបានសំរាប់ប្រឆាំងអំពើពុករលួយនៅក្នុងរង្វង់រដ្ឋាភិបាល។ នីតិវិធីរដ្ឋបាលទាំងនេះ មានលក្ខណៈដាច់ដោយឡែកពីការចោទប្រកាន់បទព្រហ្មទណ្ឌ ហើយជាទូទៅការដាក់ទណ្ឌកម្ម មានត្រឹមការដកហូតបុណ្យស័ក្តិ តួនាទីការផ្លាស់ប្តូរដោយបង្ខំ ការដាក់ឱ្យចូលនិវត្តន៍ ឬបញ្ឈប់ពីការងារដោយបង្ខំ។ ជាឧទាហរណ៍ មន្ត្រីរាជការស៊ីវិលត្រូវស្ថិតនៅក្រោមដំណើរការនីតិវិធីខាងវិន័យ ដូចមានចែងនៅក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រួតពិនិត្យផ្នែកវិន័យទៅលើចៅក្រម និងព្រះរាជអាជ្ញា។ រីឯមន្ត្រីនគរបាល និងយោធា ស្ថិតនៅក្រោមដំណើរការនីតិវិធីផ្នែកវិន័យដោយឡែក។ និយាយឱ្យខ្លីមន្ត្រីរាជការភាគច្រើន តាមទ្រឹស្តីគឺត្រូវស្ថិតនៅក្រោមដំណើរការនីតិវិធីផ្នែកវិន័យជាផ្លូវការមួយ ប្រសិនបើគេត្រូវបានរកឃើញថាអ្នកទាំងនោះប្រព្រឹត្តអំពើពុករលួយ។

កិច្ចខិតខំប្រឹងប្រែង ក្នុងពេលថ្មីៗរបស់រដ្ឋាភិបាលក្នុងដំណើរការវិមជ្ឈការ ក៏បានបង្កើតអោយមានផងដែរនូវយន្តការថ្មីៗ ដែលអាចយកទៅប្រើដើម្បីប្រឆាំងអំពើពុករលួយ។ យន្តការដែលគួរឱ្យចាប់អារម្មណ៍បំផុតនោះ គឺក្រុមការងារគណនេយ្យភាពដែលត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យលើការចាយវាយថវិការបស់ឃុំ-សង្កាត់។ ក្រុមការងារនេះបានផ្តល់នូវវិធានការថ្មីៗមួយចំនួន ដូចជាការរាយការណ៍អនាមិក

ប្រអប់ទទួលពាក្យបណ្ដឹងដែលដាក់នៅតាមឃុំ ការចូលរួមរបស់តំណាងសង្គមស៊ីវិល និងអំណាចក្នុងការដាក់ទណ្ឌកម្មដល់នយោជិតរបស់រដ្ឋ។ ឥឡូវនេះក្រុមការងារគណនេយ្យភាពទាំងនោះ កំពុងដំណើរការនៅតាមខេត្តនីមួយៗ ហើយកន្លងមក ទទួលបានពាក្យបណ្ដឹងជាងហាសិបហើយ។ ក្រុមការងារគណនេយ្យភាពអាចស៊ើបអង្កេតត្រឹមតែពាក្យបណ្ដឹងអំពីការប្រើប្រាសថវិកាឃុំមិនត្រឹមត្រូវប៉ុណ្ណោះ រីឯការចោទប្រកាន់ពីអំពើពុករលួយដែលមិនទាក់ទងនឹងថវិកាឃុំ មិនដែលមានការស៊ើបអង្កេតឡើយ។ តែទោះជាយ៉ាងណាឥឡូវនេះ ក្រសួងមហាផ្ទៃកំពុងពិចារណាលើសំណើរនានាដើម្បីពង្រឹង និងកែលំអក្រុមការងារនេះ។

សរុបសេចក្ដីមក អំពើពុករលួយនៅក្នុងប្រទេសកម្ពុជានៅតែជាបញ្ហាដ៏ធំមួយ។ ទោះបីជាមានសញ្ញានៃភាពល្អប្រសើរខ្លះដែរ ដូចជាការផ្ដន្ទាទោសកាលពីពេលថ្មីៗនេះទៅលើមន្ត្រីរាជរដ្ឋាភិបាលថ្នាក់ទាប និងការបង្កើតឱ្យមានក្រុមការងារគណនេយ្យភាពជាដើម។ ចំណុចដ៏លេចធ្លោទាំងនេះ បង្ហាញនូវកាលានុវត្តភាព សំរាប់ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល ក្នុងការរួមចំណែកដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយដោយគាំទ្រទៅលើយន្តការទាំងនេះ។ និយាយឱ្យទូលាយជាងនេះទៅទៀត នៅមានកិច្ចការជាច្រើនដែលម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល អាចធ្វើដើម្បីធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលបានព័ត៌មានអំពីអំពើពុករលួយ។ ថ្វីបើក្នុងការសិទ្ធិទទួលបានព័ត៌មានតែឯង មិនអាចដោះស្រាយបញ្ហាអំពើពុករលួយនៅក្នុងប្រទេសកម្ពុជាបានក៏ដោយ តែវាគឺជាធាតុមួយដ៏សំខាន់នៃដំណោះស្រាយដែរ។ លើសពីនេះ វាក៏ជាធាតុដែលម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិលគាំទ្រយ៉ាងសកម្ម។

## II. សេចក្តីផ្តើម

ប្រទេសកម្ពុជាកម្ពុជាត្រូវបានគេដឹងច្បាស់ថាមានបញ្ហាដោយសារអំពើពុករលួយ [១]។ មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលបានទទួលស្គាល់ជារឿយៗថា អំពើពុករលួយជាបញ្ហាដ៏ធ្ងន់ធ្ងរនៅក្នុងប្រទេសកម្ពុជា ហើយបានបង្ហាញពីបំណងរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ នៅក្នុងឆ្នាំ ២០០៤ រដ្ឋាភិបាលបានអនុម័ត "យុទ្ធសាស្ត្រចតុកោណសំរាប់ការរីកចំរើន ភាពមានការងារធ្វើ សមធម៌ និងប្រសិទ្ធិភាព"។ យុទ្ធសាស្ត្រចតុ-កោណ ត្រូវបានបង្កើតឡើងដើម្បីតំរង់ទិសគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សំរាប់រយៈពេលពីឆ្នាំ២០០៤ ដល់ ២០០៨។ ចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណគឺផ្តោតលើ "អភិបាលកិច្ចល្អ" ដែលអាចនឹងសំរេចបានតាមរយៈកំណែទំរង់លើវិស័យសំខាន់ៗចំនួនបួន ដែលក្នុងនោះមាន "ការប្រឆាំងអំពើពុករលួយ" ផងដែរ។ តាមរយៈការអនុម័តនូវយុទ្ធសាស្ត្រចតុកោណនេះ រាជរដ្ឋាភិបាលបានដាក់វិធានការប្រឆាំងនឹងអំពើពុករលួយជាស្នូលនៃផែនការរបស់ខ្លួន ដើម្បីជំរុញឱ្យមានការរីកចំរើនប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។

ចំណុចស្នូលនៃកំណែទំរង់របស់រដ្ឋាភិបាលប្រឆាំងនឹងអំពើពុករលួយ គឺការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ។ ដែទោះជាយ៉ាងណា ច្បាប់ប្រឆាំងអំពើពុករលួយនៅតែស្ថិតនៅជាសេចក្តីព្រាង អស់រយៈពេលជាងដប់ឆ្នាំ ហើយនៅមិនទាន់ត្រូវបានអនុម័តនៅឡើយ។ ការអនុម័តច្បាប់នេះ ត្រូវបានដាក់បញ្ចូលក្នុងចំណុចគោលដៅនៃការរីកចំរើន នៅក្នុងសូចនាករណ៍នៃការត្រួតពនិត្យរួមគ្នារបស់កិច្ចប្រជុំពិគ្រោះយោបល់កាលពីឆ្នាំ ២០០៦ [២]។ ជាការគួរឱ្យសោកស្តាយ សេចក្តីព្រាងច្បាប់ដែលបច្ចុប្បន្នស្ថិតនៅក្នុងដៃរបស់រដ្ឋាភិបាលមិនបានឆ្លើយតបពេញលេញទៅនឹងបទដ្ឋានអន្តរជាតិនៅឡើយ។ លើសពីនេះ គេមិនដឹងច្បាស់ថាពេលណាច្បាប់នោះនឹងត្រូវបានអនុម័តទេ [៣]។

សេចក្តីព្រាងចុងក្រោយនៃច្បាប់ប្រឆាំងអំពើពុករលួយកំពុងស្ថិតនៅក្រោមការពិភាក្សានៅឯគណៈ-រដ្ឋមន្ត្រី។ នៅពេលដែលគណៈរដ្ឋមន្ត្រីអនុម័តលើអត្ថបទនេះហើយ វានឹងត្រូវបញ្ជូនទៅរដ្ឋសភា និងព្រឹទ្ធ-សភាដើម្បីអនុម័ត។ បើច្បាប់នោះត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិទាំងពីរហើយ ក្រុមប្រឹក្សាធម្មនុញ្ញ

---

[១] យោងតាមសន្ទស្សន៍នៃការសិក្សាពីអំពើពុករលួយ ឆ្នាំ ២០០៥ របស់អង្គការតម្លាភាពអន្តរជាតិ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី១៣០ ក្នុងចំណោមប្រទេសទាំង១៥០ ដែលត្រូវបានធ្វើការស្ទាបស្ទង់។ ចំណាត់ថ្នាក់នេះទាបជាងប្រទេសជិតខាងកម្ពុជា ដូចជាប្រទេសថៃជាប់ចំណាត់ថ្នាក់ទី ៥៩ ប្រទេសឡាវ ទី៧៧ និងប្រទេសវៀតណាម ទី១០៧។

[២] ការអនុម័តច្បាប់នេះក៏ត្រូវបានដាក់បញ្ចូល នៅក្នុងសូចនាករនៃការត្រួតពិនិត្យរួមគ្នារបស់ក្រុមពិគ្រោះយោបល់សំរាប់ឆ្នាំ ២០០២ និង ២០០៤ ផងដែរ។

[៣] សេចក្តីដកស្រង់ពីកាសែតភ្នំពេញប៉ុស្តិ៍ដែលចេញផ្សាយកាលពីឆ្នាំ ១៩៩៩ និយាយពីការប្រមើលមើលពីការលំបាកក្នុងការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ : " *បន្ទាប់ពីការរៀបចំផែនការអស់រយៈពេលប្រាំឆ្នាំ ការពិភាក្សា និងការថ្កើបទុកចោលដ៏យូរ ......... ច្បាប់ប្រឆាំងអំពើពុករលួយរបស់ជាតិស្ថិតនៅឆ្ងាយដូចជើងមេឃ* ។" សូមអាន " *កម្ពុជាជារាជាណាចក្រនៃអំពើពុករលួយ* : ព្យាយាមរកវិធីដើម្បីបង្វែរខ្សែរទឹក " ភ្នំពេញប៉ុស្តិ៍លេខ ៨/១៤ កក្កដា ៩-២២ ១៩៩៩ និង " *ប្រាំពីរឆ្នាំក្រោយមក ច្បាប់ប្រឆាំងអំពើពុករលួយនៅតែស្ថិតនៅឯជើងមេឃ* "។

អាចត្រូវបានស្នើឱ្យពិនិត្យមើល ថាតើវាស្របរដ្ឋធម្មនុញ្ញឬអត់។ បើរកទៅឃើញថាវាស្របនឹងរដ្ឋធម្មនុញ្ញ ហើយ វាត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រឹត្យ។

ក្នុងសភាពមិនច្បាស់លាស់ជុំវិញការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ និងដោយយល់ឃើញថា ទោះបីជាច្បាប់នេះត្រូវបានប្រកាសឱ្យប្រើក៏ដោយ វាទាមទារពេលវេលាយ៉ាងហោច ១២ ខែ ដើម្បីឱ្យស្ថាប័នប្រឆាំងអំពើពុករលួយ (ACB) ដែលនឹងត្រូវបង្កើតឡើងមានធ្វើសកម្មភាពនោះ របាយការណ៍នេះបង្ហាញពីវិធានការដែលមានស្រាប់ ដែលអាចយកទៅប្រើដើម្បីប្រយុទ្ធប្រឆាំងំពើពុករលួយក្នុងប្រទេសកម្ពុជា។ វិធានការទាំងនេះ ចែកចេញជាបីផ្នែក: ១) វិធានការបណ្តឹងអាជ្ញា ២) វិធានការរដ្ឋបាល ៣) យន្តការមិនផ្លូវការ។ ផ្នែកដែលនិយាយពីបណ្តឹងអាជ្ញា នឹងលើកឡើងពីបញ្ញត្តិច្បាប់ដែលមានស្រាប់ ដែលចាត់ទុកអំពើពុករលួយជាបទឧក្រិដ្ឋ ព្រមទាំងយន្តការដែលមានស្រាប់សំរាប់ការផ្តន្ទាទោស។ ផ្នែកដែលនិយាយពីវិធានការរដ្ឋបាល នឹងរៀបរាប់ពីសវនកម្មផ្ទៃក្នុង និងនីតិវិធីស៊ើបអង្កេតដែលមាននៅក្នុងក្រសួងនីមួយៗរបស់រដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងអំពើពុករលួយ។ នៅទីបញ្ចប់ របាយការណ៍នេះនឹងបញ្ចូលការពិនិត្យមើលដោយសង្ខេបនូវយន្តការមិនផ្លូវការ ដែលបានប្រើប្រាស់នៅថ្នាក់ភូមិ និងឃុំ ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងអំពើពុករលួយ។

## III- បទឧក្រិដ្ឋ និងនីតិវិធីព្រហ្មទណ្ឌ

ទោះបីជាមិនទាន់មានការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយក៏ដោយ អំពើពុករលួយគឺជាអំពើល្មើសច្បាប់រួចទៅហើយនៅក្នុងប្រទេសកម្ពុជា។ នេះគឺជាលទ្ធផលដែលភាគច្រើន កើតចេញពីច្បាប់អ៊ុនតាក់។[៤] ច្បាប់អ៊ុនតាក់ចាត់ទុកជាបទឧក្រិដ្ឋចំពោះការគៃបំបាត់ធ្វើឡើងដោយអ្នករដ្ឋការ ការស៊ីសំណូក ការក្លែងបន្លំឯកសារសាធារណៈ និងអំពើសូកប៉ាន់។ នៅក្នុងច្បាប់ស្តីពីសារពើពន្ធ មានបទបញ្ញត្តិពិសេសមួយដែលផ្តន្ទាទោសព្រហ្មទណ្ឌអំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីពន្ធដារ។បទឧក្រិដ្ឋទាំងនេះនឹងត្រូវលើកយកមកនិយាយម្តងមួយៗ នៅខាងក្រោម។ គ្មាននីតិវិធីពិសេសដោយឡែកសំរាប់ការស៊ើបអង្កេត ឬជំនុំជំរះអំពើពុករលួយ នៅក្នុងតុលាការកម្ពុជាឡើយ ហើយរឿងក្តីព្រហ្មទណ្ឌពាក់ព័ន្ធអំពើពុករលួយត្រូវបានគេចាត់ទុកដូចជាបទល្មើសព្រហ្មទណ្ឌដទៃទៀតដែរ នៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។ យន្តការទូទៅសំរាប់ប្តឹង និងផ្តន្ទាទោសបទព្រហ្មទណ្ឌ ដែលមាននៅក្នុង ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ នឹងត្រូវពិភាក្សាខាងក្រោម។

### ក. បទល្មើសព្រហ្មទណ្ឌ

ច្បាប់អ៊ុនតាក់ បង្កើតបានជាមូលដ្ឋានដ៏សំខាន់បំផុតសំរាប់ច្បាប់ព្រហ្មទណ្ឌក្នុងប្រទេសកម្ពុជា។ វាបង្កប់នូវធាតុទាំងឡាយនៃបទល្មើសព្រហ្មទណ្ឌ និងការផ្តន្ទាទោស។[៥] មាត្រាចំនួន ៤ នៅក្នុងច្បាប់អ៊ុនតាក់ ហាមឃាត់អំពើពុករលួយក្នុងរូបភាពផ្សេងៗ។ វាបានបង្ហាញនូវភាពខុសគ្នារវាងបទល្មើសធ្ងន់ធ្ងរដែលហៅថាបទឧក្រិដ្ឋ និងបទល្មើសមិនសូវធ្ងន់ធ្ងរដែលហៅថាបទមជ្ឈិម។ ជាទូទៅ ការផ្តន្ទាទោសបទឧក្រិដ្ឋមានលក្ខណៈធ្ងន់ធ្ងរជាងបទមជ្ឈិម។ មានមាត្រាពីរដែលទាក់ទងនឹងអំពើពុករលួយ គឺការគៃបំបាត់ធ្វើឡើងដោយអ្នករដ្ឋការ និងការស៊ីសំណូក ត្រូវបានចាត់ទុកជាបទឧក្រិដ្ឋ។ ចំណែកឯបទល្មើសពីរទៀត គឺការក្លែងបន្លំឯកសារសាធារណៈ និងការសូកប៉ាន់ ត្រូវបានចាត់ទុកជាបទមជ្ឈិម[៦]។ នៅក្នុងច្បាប់ស្តីពីសារពើពន្ធក៏មានបទបញ្ញត្តិមួយដែលទុកជាបទឧក្រិដ្ឋផងដែរ ចំពោះមន្ត្រីពន្ធដារណាដែលលួចយកប្រាក់ពន្ធរបស់រដ្ឋ ឬប៉ុនប៉ងប្រមូលប្រាក់ពន្ធមិនបានត្រឹមត្រូវ។

---

[៤] ឈ្មោះជាផ្លូវការនៃច្បាប់អ៊ុនតាក់ គឺ " *បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល* "។ ច្បាប់នោះត្រូវព្រាងឡើងដោយមានជំនួយពីអ៊ុនតាក់ (ដែលហេតុនេះគេតែងតែហៅវាថាច្បាប់អ៊ុនតាក់) ហើយត្រូវបានអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ កាលពីថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២។

[៥] នីតិវិធីព្រហ្មទណ្ឌ ដែលជាបណ្តុំនៃវិធានដែលនិយាយពីការផ្តើមបណ្តឹងអាជ្ញា ការស៊ើបអង្កេត និងជំនុំជំរះដោយតុលាការ មានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (១៩៩៣) ។ នីតិវិធីព្រហ្មទណ្ឌកម្ពុជានឹងត្រូវលើកមកពិភាក្សាខាងក្រោមត្រង់ផ្នែក (III. ខ)។

[៦] ទោះបីមិនមានច្បាប់ប្រឆាំងអំពើពុករលួយក៏ដោយ បទល្មើសនេះទំនងជានឹងត្រូវមានការកែប្រែគួរឱ្យកត់សំគាល់ក្នុងអនាគតដ៏ខ្លី។ រដ្ឋាភិបាលកំពុងប្រឹងប្រែងក្នុងការធ្វើឱ្យការអនុម័តសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ជាអាទិភាព។ នៅពេលដែលអនុម័តរួចហើយក្រមព្រហ្មទណ្ឌថ្មីនេះ នឹងជំនួសឱ្យច្បាប់អ៊ុនតាក់ទាំងស្រុង។

1. ការស៊ីសំណូក (ច្បាប់អ៊ុនតាក់ មាត្រា ៣៨)

បទបញ្ញត្តិសំខាន់ដែលទាក់ទងនឹងអំពើពុករលួយនៅក្នុងច្បាប់អ៊ុនតាក់ គឺមាត្រា៣៨ ដែលចែងថា:

> ដោយមិនគិតដល់ទណ្ឌកម្មខាងវិន័យជាយថាហេតុ គ្រប់អ្នករដ្ឋបាលស៊ីវិល ឬយោធា គ្រប់ភាគីផ្លូវការនៃភាគីណាមួយ ក្នុងចំណោមភាគីទាំងបួននៃកិច្ចព្រមព្រៀងក្រុងប៉ារីស គ្រប់អ្នកទទួលខុសត្រូវនយោបាយដែលស្នើសុំ ឬប៉ុនប៉ងនឹងស្នើសុំ ឬទទួល ឬប៉ុនប៉ងនឹងទទួលក្នុងក្របខ័ណ្ឌនៃការងាររបស់ខ្លួន ឬក្នុងឱកាសបំពេញការងារ នូវទ្រព្យសម្បត្តិ សេវាកម្ម ប្រាក់កាស បុគ្គលិក មុខងារ ឯកសារ សេចក្តីអនុញ្ញាតិ ឬផលប្រយោជន៍អ្វីមួយជាថ្នូរនៃរបស់ណាមួយក្នុងចំណោមរបស់ទាំងនេះ គឺបានប្រព្រឹត្តបទល្មើសស៊ីសំណូកអកម្ម ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ៣ ទៅ ៧ ឆ្នាំ។

ក៏ដូចបទឧក្រិដ្ឋដទៃទៀតដែរ បទល្មើសស៊ីសំណូកមានធាតុផ្សំដោយឡែកៗ។ធាតុផ្សំទាំងនេះ ត្រូវបានដកចេញពីភាសាដែលបានប្រើនៅក្នុងមាត្រាទី៣៨ ដែលរួមមាន:

- ជាអ្នករដ្ឋការ
- ប្រព្រឹត្តិក្នុងក្របខ័ណ្ឌការងាររបស់ខ្លួន
- ស្នើសុំ ឬប៉ុនប៉ងនឹងស្នើសុំ ឬទទួល ឬប៉ុនប៉ងនឹងទទួល
- ជាផលប្រយោជន៍ណាមួយ
- ជាថ្នូរនឹងផលប្រយោជន៍ណាមួយ [៧] ។

ចំណុចគន្លឹះនៃបទល្មើសស៊ីសំណូក គឺថាមន្ត្រីរាជរដ្ឋាភិបាលជាអ្នកទទួល ឬស្នើសុំអ្វីមួយ (ដែលក្នុងនោះអាចរាប់បញ្ចូលទាំងប្រាក់កាស ទ្រព្យសម្បត្តិ សេវាកម្ម ផលប្រយោជន៍ ឬអ្វីមួយដែលមានតំលៃ ឬផ្តល់ប្រយោជន៍តបវិញ )ជាថ្នូរនឹងការប្រើប្រាស់មុខងាររបស់ខ្លួនដើម្បីផ្តល់ប្រយោជន៍តបវិញដល់អ្នកដែលធ្វើការសូកប៉ាន់។

ដើម្បីផ្តន្ទាទោសបុគ្គលណាមួយពីបទស៊ីសំណូកត្រូវបង្ហាញពីធាតុផ្សំទាំងឡាយខាងលើ។ បើបុគ្គលទាំងឡាយត្រូវបានរកឃើញថាមានពិរុទ្ធពីបទស៊ីសំណូក ពួកគេអាចទទួលការផ្តន្ទាទោសជាប់គុកពី ៣ ទៅ

---

[៧] ផ្នែកនេះមិនមានបំណងធ្វើការវិភាគទៅលើបច្ចេកទេសច្បាប់ ស្តីពីធាតុផ្សំនៃបទល្មើសទាក់នឹងការស៊ីសំណូកឡើយ។ វាគ្រាន់តែចង់បញ្ជាក់ពីធាតុផ្សំសំខាន់ៗនៃបទល្មើស ហើយធ្វើការពន្យល់វាឱ្យបានច្បាស់ និងងាយយល់តែប៉ុណ្ណោះ។ ក្រុមគោលដៅនៃរបាយការណ៍នេះគឺ សាធារណជន អង្គការសង្គមស៊ីវិល ម្ចាស់ជំនួយ និងរដ្ឋាភិបាលកម្ពុជា។ នៅក្នុងករណីខ្លះ បញ្ហាផ្លូវច្បាប់ដែលស្មុគស្មាញ និងស្រពិចស្រពិល មិនត្រូវបានលើកមកបកស្រាយឡើយ។

៧ ឆ្នាំ។ គួរកត់សំគាល់ផងដែរថា ការដែលមានបទចោទប្រកាន់ទាក់ទងនឹងអំពើពុករលួយ នឹងមិនរារាំងដល់ដំណើរការនីតិវិធីខាងរដ្ឋបាលដូចគ្នា ដែលធ្វើឡើងចំពោះអំពើពុករលួយឡើយ។[៨]

## ២. អំពើសូកប៉ាន់ (ច្បាប់អ៊ុនតាក់ មាត្រា ៥៨)

មាត្រា ៥៨ នៃច្បាប់អ៊ុនតាក់ បានចែងថាៈ

ជនណាដែលសូក ឬប៉ុនប៉ងសូក គ្រប់អ្នកតំណាងជាប់ឆ្នោត គ្រប់អ្នករដ្ឋការស៊ីវិល និងយោធា គ្រប់ភ្នាក់ងារផ្លូវការនៃភាគីណាមួយ ក្នុងចំណោមភាគីទាំងបួននៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឬគ្រប់គណបក្សនយោបាយដែលចុះឈ្មោះក្នុងបញ្ជី ក្នុងក្របខ័ណ្ឌមុខងាររបស់ខ្លួន ឬក្នុងឱកាសបំពេញមុខងារអស់ទាំងនេះ ដោយសន្យាប្រគល់ដល់អ្នកទាំងនោះ នូវទ្រព្យសម្បត្តិ សេវាកម្ម ប្រាក់ បុគ្គលិក មុខងារ ឯកសារ សេចក្តីអនុញ្ញាត ឬកំរៃអ្វីមួយជាថ្នូរដើម្បីឱ្យបានរបស់ណាមួយក្នុងចំណោមរបស់ទាំងនោះ គឺជាការប្រព្រឹត្តិបទមជ្ឈិមសូកប៉ាន់សកម្ម ហើយត្រូវមានទោសជាប់គុកពីមួយឆ្នាំទៅបីឆ្នាំ។

យោងតាមមាត្រានេះ អំពើសូកប៉ាន់កើតឡើងនៅពេលដែលៈ

១. ជនណាម្នាក់

២. សូក ឬប៉ុនប៉ងសូកអ្នករដ្ឋការណាម្នាក់

៣. នៅពេលដែលអ្នករដ្ឋការនោះកំពុងបំពេញតួនាទីរបស់ខ្លួន

៤. ដោយការសន្យាផ្តល់ជាផលប្រយោជន៍

៥. ជាថ្នូរនឹងការទទួលផលប្រយោជន៍អ្វីមួយ។

អំពើសូកប៉ាន់គឺជាបទល្មើសជាគូនឹងការស៊ីសំណូក។ អំពើពុករលួយតំរូវឱ្យមានអ្នកចូលរួមចំនួនពីរនាក់ គឺមន្ត្រីរដ្ឋាភិបាលដែលបានទទួលប្រយោជន៍ និងសាធារណជនណាម្នាក់ជាអ្នកផ្តល់ប្រយោជន៍ដើម្បីជាថ្នូរនឹងអ្វីមួយ (ជាថ្នូរប្រយោជន៍អ្វីមួយ)។ មន្ត្រីរាជរដ្ឋាភិបាលអាចត្រូវចោទប្រកាន់តែពីបទស៊ីសំណូកប៉ុណ្ណោះ រីឯសាធារណជនវិញអាចត្រូវចោទប្រកាន់ពីបទអំពើសូកប៉ាន់។ ទោះបីវាជាការសូកប៉ាន់ជាគូនឹងបទល្មើសស៊ីសំណូកក៏ដោយ ការសូកប៉ាន់ត្រូវបានចាត់ទុកថាមានលក្ខណៈស្រាលជាងការស៊ីសំណូក។ ពេលដែលការស៊ីសំណូកគឺជាបទឧក្រិដ្ឋពេញលេញអំពើសូកប៉ាន់ត្រូវបានចាត់ ទុកជាបទល្មើសមជ្ឈិមតែប៉ុណ្ណោះ។ បន្ថែមលើនេះទៅទៀត នៅពេលដែលកំរិតទោសជាអតិបរមាសំរាប់ការស៊ីសំណូកគឺជាប់គុកប្រាំពីរឆ្នាំ កំរិតទោសអតិបរមាសំរាប់ការសូកប៉ាន់គឺជាប់គុកបីឆ្នាំ តែប៉ុណ្ណោះ។

---

[៨] តាមពិត ដូចដែលនឹងបង្ហាញនៅពេលក្រោយ សកម្មភាពតែមួយនៃអំពើពុករលួយ អាចនាំឱ្យមានដំណើរការនីតិវិធីបីផ្សេងៗពីគ្នាដូចជា ការជំនុំជំរះពីបទស៊ីសំណូក សំណងរដ្ឋប្បវេណីចំពោះការខូចខាតដែលកើតចេញពីបទល្មើសពុករលួយនេះ និងដំណើរការនីតិវិធីខាងរដ្ឋបាលដែលនាំទៅដល់ការបាត់បង់ការងារ។

### ៣. ការកែបំបាត់ធ្វើឡើងដោយអ្នករដ្ឋការ (ច្បាប់អ៊ិនតាក់ មាត្រា ៣៧)

ច្បាប់អ៊ិនតាក់ក៏បានចាត់ទុកការកែបំបាត់ដោយអ្នករដ្ឋការថាជាបទឧក្រិដ្ឋផងដែរៈ

ជនជាតំណាងជាប់ឆ្នោត អ្នករដ្ឋការស៊ីវិល និងយោធាទាំងអស់ គ្រប់ភ្នាក់ងារផ្លូវការនៃភាគីណាមួយ នៃភាគីកម្ពុជាទាំងបួននៃកិច្ចព្រមព្រៀងប៉ារីស គ្រប់អ្នកទទួលខុសត្រូវខាងនយោបាយដែលក្នុងក្របខ័ណ្ឌ មុខងាររបស់ខ្លួន ឬក្នុងឱកាសបំពេញមុខងារនេះ បានយកធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន លក់ ជួល កែបំបាត់ជាប្រយោជន៍ខ្លួន ឬជាប្រយោជន៍តតិយជនណាមួយ នូវសម្បត្តិទ្រព្យ សេវាកម្ម ប្រាក់កាស បុគ្គលិក ផលប្រ-យោជន៍ ឯកសារ សេចក្តីអនុញ្ញាត ឬមុខងារដែលជារបស់សមូហភាពណាមួយធ្វើជាកម្មសិទ្ធិ ឬជាសិទ្ធិអាស្រ័យផល ត្រូវមានទោសពីបទឧក្រិដ្ឋកែបំបាត់សម្បត្តិសាធារណៈ ហើយត្រូវផ្តន្ទាទោសដាក់គុកពីបទឧក្រិដ្ឋពី ៣ ទៅ ១០ ឆ្នាំ។

ការកែបំបាត់ធ្វើឡើងដោយអ្នករដ្ឋការកើតមាននៅពេលដែលៈ

១. អ្នករដ្ឋការម្នាក់

២. ធ្វើសកម្មភាពក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន

៣. យកធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន លក់ ជួល ប្រើប្រាស់

៤. សម្បត្តិទ្រព្យសាធារណៈ

៥. ទោះដើម្បីប្រយោជន៍ផ្ទាល់ខ្លួន រឺប្រយោជន៍តតិយជនក៏ដោយ

មានចំណុចខុសគ្នាជាគន្លឹះចំនួនពីររវាងការស៊ីសំណូក និងការកែបំបាត់។ ទីមួយ ការស៊ីសំណូកសូកប៉ាន់ តំរូវឱ្យមានអ្នកប្រព្រឹត្តិពីរនាក់ គឺមន្ត្រីសាធារណៈដែលបានទទួលជាប្រយោជន៍ផ្ទាល់ខ្លួន និងសមាជិកសាធារណជនដែលផ្តល់នូវផលប្រយោជន៍នោះ។ ដោយឡែកការកែបំបាត់ មិនតំរូវឱ្យមានការចូលរួមពីជនទីពីរឡើយ។ ទីពីរចំណុចខុសគ្នាជាគន្លឹះគឺថា ក្នុងបទល្មើសការស៊ីសំណូក មន្ត្រីរាជការបានប្រើប្រាស់អ្វីដែលខ្លួនមានតួនាទីគ្រប់គ្រងជាថ្នូរនឹងផលប្រយោជន៍ដទៃទៀត។ ក្នុងការកែបំបាត់ មន្ត្រីរាជការបានយកធ្វើជាប្រយោជន៍ផ្ទាល់ខ្លួនដោយងាយៗ នូវអ្វីដែលរដ្ឋបានប្រគល់ តាមរយៈការបំពេញតួនាទីជាផ្លូវការ។

ជាឧទាហរណ៍ ប្រសិនបើមន្ត្រីរាជការដែលមានសិទ្ធិផ្តល់អាជ្ញាប័ណ្ណ ឬការអនុញ្ញាតឱ្យធ្វើសកម្ម-ភាពអ្វីមួយ បានទទួលប្រាក់ជាថ្នូរនឹងការផ្តល់អាជ្ញាប័ណ្ណមួយទៅឱ្យក្រុមហ៊ុនមួយ ដែលមិនបានបំពេញគុណសម្បត្តិអប្បបរមាសំរាប់ការទទួលបាននូវអាជ្ញាប័ណ្ណនោះ វាគឺជាការស៊ីសំណូក។ ក្នុងករណីនេះ មន្ត្រីនោះបានប្រើតួនាទីរបស់ខ្លួន (លទ្ធភាពក្នុងការផ្តល់អាជ្ញាប័ណ្ណ) ដើម្បីទទួលបានផលប្រយោជន៍សំរាប់ខ្លួនឯង (ជាប្រាក់) ជាថ្នូរនឹងការផ្តល់ប្រយោជន៍ដល់អ្នកសូកប៉ាន់ (ចេញអាជ្ញាប័ណ្ណឱ្យ )។ នេះជាករណីទូទៅនៃការស៊ីសំណូក។ ក៏ប៉ុន្តែ បើសិនជាមន្ត្រីរាជការបានចេញអាជ្ញាប័ណ្ណ តែបានរាយការណ៍មិនពិតពីចំនួន

ទឹកប្រាក់ដែលខ្លួនប្រមូលបាន នោះវាជាការគៃបំបាត់។ ក្នុងករណីក្រោយនេះ មន្ត្រីរាជការបានប្រើប្រាស់មុខតំណែងរបស់ខ្លួន (សិទ្ធិចេញអាជ្ញាប័ណ្ណ) ដើម្បីការមានបានផ្ទាល់ខ្លួន (ដោយកេងកីបយកប្រាក់ដែលទទួលបានពីអ្នកសុំអាជ្ញាប័ណ្ណ)។ ក្នុងករណីក្រោយនេះ វាមិនតំរូវឱ្យមានការធ្វើខុសដោយសាធារណជនដែលមិនដឹងថាមន្ត្រីនោះបានដកយកលុយ ឬមិនដកនោះទេ ។ ជនណាដែលមានទោសពីបទគៃបំបាត់អាចជាប់គុក ពី ៣ ទៅ ១០ ឆ្នាំ។

### ៤. ការក្លែងបន្លំឯកសារសាធារណ: (ច្បាប់អ៊ុនតាក់ មាត្រា ៤៩)

មាត្រាទី ៤៩ នៃច្បាប់អ៊ុនតាក់បានចែងថា:

គ្រប់ជនជ្រើសតាំងដោយការបោះឆ្នោត គ្រប់អ្នករដ្ឋការស៊ីវិល ឬយោធា គ្រប់ភ្នាក់ងារផ្លូវការរបស់ភាគីណាមួយ ក្នុងបណ្តាភាគីខ្មែរទាំងបួននៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឬរបស់គ្រប់គណបក្សនយោបាយដែលបានចុះក្នុងបញ្ជី អ្នកទទួលខុសត្រូវក្នុងបណ្តាភាគីខ្មែរទាំងបួន នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ឬរបស់គ្រប់គណបក្សនយោបាយដែលបានចុះក្នុងបញ្ជី ដែល ក្នុងការបំពេញមុខងាររបស់ខ្លួន បានប្រព្រឹត្តិបទក្លែង ដោយក្លែងហត្ថលេខា ឬដោយលួច កែលិខិតផ្លូវការ កែអក្សរ ឬកែហត្ថលេខា ដោយសន្មតជនម្នាក់ថាជាជនម្នាក់ទៀត ដោយធ្វើអក្សរ ឬសិកបញ្ចូលអក្សរលើ បញ្ជី ឬលិខិតសាធារណ:ឯទៀតៗ ចាប់ពីការធ្វើ ឬការបញ្ចប់បញ្ជី ឬលិខិតសាធារណ: ទាំងនោះ អ្នកណាដែលបានប្រើប្រាស់ដោយដឹងខ្លួន នូវរបស់ក្លែងបន្លំទាំងនេះ នឹងត្រូវមានទោសឧក្រិដ្ឋពីបទក្លែងលិខិតសាធារណ: ហើយត្រូវ ផ្តន្ទាទោសពី ៥ ទៅ ១៥ ឆ្នាំ។

ការក្លែងឯកសារសាធារណ:កើតឡើងនៅពេល:

១. អ្នករដ្ឋការណាម្នាក់

២. ក្នុងតួនាទីផ្លូវការ

៣. ប្រព្រឹត្តិការក្លែងឯកសារ

ក. ក្លែងហត្ថលេខាលើឯកសារ

ខ. កែលិខិតផ្លូវការ កែអក្សរ កែហត្ថលេខា ឬ

គ. សិកបញ្ចូលអក្សរលើបញ្ជី ឬលិខិតសាធារណ:ផ្សេងៗ ចាប់ពីការធ្វើ ឬបញ្ចប់បញ្ជី

៤. និងអ្នកដែលបានប្រើប្រាស់ដោយដឹងខ្លួននូវឯកសារនោះ។

បទល្មើសក្លែងបន្លំឯកសារមានលក្ខណ:ស្មុគស្មាញបន្តិច ជាងបទល្មើសស៊ីសំណូក និងគៃបំបាត់។ បទល្មើសនេះតំរូវឱ្យមានអ្នកប្រព្រឹត្តិពីរនាក់ គឺមន្ត្រីរាជការដែលក្លែងឯកសារ និងមនុស្សម្នាក់ទៀតដែលប្រើប្រាស់ឯកសារនេះ។ លើសពីនេះ វាមានធាតុផ្សំខាងស្មារតីជាក់លាក់ដែលកំណត់ក្នុងបទល្មើសនេះ។

អ្នកដែលប្រើឯកសារក្លែង ត្រូវតែប្រើវាដោយដឹងខ្លួន។ ដូចនេះ វាមិនត្រឹមតែតំរូវឱ្យមានភស្តុតាងថាអ្នកណាម្នាក់ប្រើឯកសារក្លែង ឬថាពួកគេទទួលផលពីឯកសារនោះទេ ប៉ុន្តែវាក៏តំរូវឱ្យមានភស្តុតាងថា ពួកគេប្រើឯកសារនោះ ដោយដឹងថាវាជាឯកសារក្លែងក្លាយផងដែរ។ ការលំបាកក្នុងការបង្ហាញភស្តុតាងពីការប្រើប្រាស់ដោយដឹងខ្លួន នឹងត្រូវកាត់បន្ថយ ក្នុងករណីដែលអ្នកប្រើប្រាស់ឯកសារនោះ ជាមន្ត្រីរាជការដែលជាអ្នកក្លែងឯកសារពីដំបូង ពីព្រោះពួកគេអាចនឹងដឹងថា វាជាឯកសារក្លែងក្លាយ។

ការផ្តន្ទាទោសចំពោះការក្លែងបន្លំក្នុងឯកសារសាធារណៈ ជួនកាលមានភាពច្របូកច្របល់ណាស់។ វាត្រូវបានចាត់ទុកជាបទល្មើសមជ្ឈិម តែទោសជាអតិបរមា (១៥ឆ្នាំ) អាចធ្ងន់ជាងកំរិតទោសអតិបរមានៃបទល្មើសពុករលួយពីរដង។ តាមពិត វាត្រូវទទួលទោសស្ទើរតែដូចគ្នានឹងបទមនុស្សឃាតដែរ ដែលមានកំរិតទោសអតិបរមាជាប់គុកម្ភៃឆ្នាំ។ វាមិនមានភាពច្បាស់លាស់ឡើយ ថាហេតុអ្វីបានជាដូច្នេះ។

### ៥. ការរំលោភបំពានដោយមន្ត្រីពន្ធដារ (ច្បាប់ស្តីពីសារពើពន្ធ មាត្រា ១៣៩)

ក្នុងច្បាប់ស្តីពីសារពើពន្ធ មានបទបញ្ញត្តិពិសេសមួយសំដៅលើអំពើពុករលួយដោយមន្ត្រីពន្ធដារ។ មាត្រា ១៣៩ បានចែងថា:

បុគ្គលណាដែលបានទទួលការចាត់តាំងជាអ្នកអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ ហើយដោយចេតនាបានប្រព្រឹត្តិអំពើដូចខាងក្រោមនេះ ត្រូវជាប់ពិរុទ្ធជាបទល្មើសនឹងច្បាប់ ហើយត្រូវទទួលរងការផ្តន្ទាទោសពិន័យ ជាប្រាក់ពី ប្រាំលាន (៥.០០០.០០០) ដល់ ដប់លាន (១០.០០០.០០០) រៀល ឬជាប់ពន្ធនាគារពី ១ខែ ដល់ ១ ឆ្នាំ ឬទោសទាំងពីរនេះ។

១. ដកប្រាក់ពន្ធសំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួន ឬការប្រើប្រាស់ណាផ្សេង ដែលគ្មានចែងក្នុងបទបញ្ញត្តិស្តីពីពន្ធដារ។

២. ធ្វើរបាយការណ៍មិនត្រឹមត្រូវពីចំនួនប្រាក់ពន្ធដែលប្រមូលបាន ឬទទួលបាន។

៣. ប្រើប្រាស់តួនាទីជាមន្ត្រីពន្ធដារដើម្បីទទួលយកប្រាក់ ឬប្រយោជន៍ផ្សេងទៀតពីអ្នក ជាប់ពន្ធ ឬបុគ្គលផ្សេងទៀត។

៤. ប្រមូល ឬព្យាយាមប្រមូលពន្ធដោយគ្មានការអនុញ្ញាតិ

បុគ្គលណាដែលបានទទួលការចាត់តាំងជាអ្នកអនុវត្តបទបញ្ញត្តិស្តីពីពន្ធដា ហើយដោយចេតនាបានទាមទារប្រាក់លើសពីច្បាប់អនុញ្ញាត ត្រូវទទួលទោសវិនិក្រមតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

បុគ្គលណាដែលបានទទួលការចាត់តាំងជាអ្នកអនុវត្តបទបញ្ញត្តិស្តីពីពន្ធដារ ហើយដោយចេតនាបានទាមទារ ឬទទួលសំណូក ត្រូវទទួលទោសតាមច្បាប់ស៊ីសំណូកជាធរមាន។ អ្នកសូកត្រូវទទួលទោសពីបទការសូកប៉ាន់តាមច្បាប់ព្រហ្មទណ្ឌជាធរមាន។

ទង្វើជាច្រើនដែលត្រូវបានហាមឃាត់ដោយមាត្រានេះ (ហើយសូម្បីតែគ្មានមាត្រានេះក៏ដោយ) អាចបង្កើតជាបទល្មើសដែលផ្ទុយនឹងច្បាប់អ៊ុនតាក់។ ជាឧទាហរណ៍ "ការដកហូតប្រាក់ពន្ធសំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួន" គ្រប់កាលៈទេសៈ អាចត្រូវបានចាត់ចូលជាបទល្មើស តែបំបាត់ធ្វើឡើងដោយមន្ត្រីសាធារណៈ។ ស្រដៀងគ្នានេះដែរ "ការប្រើប្រាស់តួនាទីជាមន្ត្រីពន្ធដារ ដើម្បីទទួលយកប្រាក់ និងផលប្រយោជន៍ផ្សេងទៀតពីអ្នកជាប់ពន្ធ" គឺដូចគ្នាខ្លាំងណាស់ទៅនឹងការប្រើប្រាស់តួនាទីជាមន្ត្រី ដើម្បីទទួល

បានផលប្រយោជន៍ពីសមាជិកណាម្នាក់នៃសាធារណជន ជាថ្នូរនឹងការផ្តល់ជាផលប្រយោជន៍ណាមួយ ដែលជាអំពើពុករលួយ។ តាមពិតទៅ ភាសាដែលបានប្រើនៅក្នុងមាត្រានេះ ហាក់ដូចជាលើកឡើងថា អំពើតែមួយ អាចជាអំពើដែលល្មើសនឹង មាត្រា ១៣៩ នៃច្បាប់ស្តីពីសារពើពន្ធផង និងបទបញ្ញត្តិនៃច្បាប់អ៊ុនតាក់ផង។

### ខ. នីតិវិធីព្រហ្មទណ្ឌ

នីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ពឹងផ្អែកជាទូទៅលើប្រព័ន្ធច្បាប់ស៊ីវិលរបស់បារាំងដែលមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីប្រព័ន្ធច្បាប់ Common Law ដែលគេប្រើប្រាស់ភាគច្រើននៅក្នុងប្រទេសនិយាយភាសាអង់គ្លេស។ នីតិវិធីព្រហ្មទណ្ឌបច្ចុប្បន្ន មានចែងនៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្ម. ទណ្ឌ (ឆ្នាំ ១៩៩៣)។ ច្បាប់នេះនឹងត្រូវជំនួសដោយក្រមនីតិវិធីព្រហ្មទណ្ឌថ្មីដែលកំពុងព្រាង ដោយមានជំនួយផ្នែកបច្ចេកទេស ពីសហគមន៍អន្តរជាតិ។ ទោះជាយ៉ាងនេះក្តី ទំរាំក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានប្រកាសឱ្យប្រើ ហើយដែលមិនប្រាកដថាពេលណានឹងត្រូវបានប្រកាសឱ្យប្រាស់នោះ ប្រទេសកម្ពុជានឹងបន្តប្រើច្បាប់កាលពីឆ្នាំ ១៩៩៣ នោះតទៅទៀត។ មិនទាន់មានបទបញ្ញត្តិដោយឡែកណាមួយ សំរាប់យកទៅអនុវត្តដើម្បីផ្តន្ទាទោសអំពើពុករលួយឡើយ ហើយការផ្តន្ទាទោសអំពើពុករលួយ គប្បីដំណើរការ ដូចគ្នានឹង ការផ្តន្ទាទោសបទព្រហ្មទណ្ឌដទៃទៀតនៅក្នុងប្រទេសកម្ពុជាដែរ។

បណ្តឹងអាជ្ញាទាំងអស់ ត្រូវធ្វើឡើងចំពោះរាល់បទល្មើសព្រហ្មទណ្ឌ។ មានតែមន្រ្តីដែលច្បាប់បានប្រគល់សិទ្ធិឱ្យទេ ទើបធ្វើបណ្តឹងអាជ្ញាបាន។ សូមមើលច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤ ៨ និង ៥២។ មានវិធីពីរ ដែលបទល្មើសព្រហ្មទណ្ឌត្រូវបានដឹងដល់ព្រះរាជអាជ្ញា។ ទីមួយគឺ មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចដើម្បីស៊ើបអង្កេតបទឧក្រិដ្ឋ។ នគរបាលយុត្តិធម៌មានតួនាទីប្រមូលភស្តុតាង ដែលទាក់ទងនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ហើយបង្ហាញភស្តុតាងនោះទៅព្រះរាជអាជ្ញា (សូមមើលមាត្រា ៣៥ និង ៥៦)។ ដូច្នេះវិធីមួយដើម្បីចាប់ផ្តើមដំណើរការរឿងក្តីព្រហ្មទណ្ឌ គឺត្រូវប្តឹងទៅមន្ត្រីនគរបាលយុត្តិធម៌។ ទីពីរគឺ ជនណាម្នាក់ដែលបានដឹងថាមានបទល្មើសណាមួយកើតឡើង អាចរាយការណ៍ពីបទល្មើសនោះ ដោយផ្ទាល់ទៅព្រះរាជអាជ្ញា ដែលជាអ្នកមានតួនាទីទទួលពាក្យបណ្តឹងនោះ (មាត្រា ៥៦)។

នៅពេលដែលព្រះរាជអាជ្ញាបានទទួលរបាយការណ៍ស្តីពីបទឧក្រិដ្ឋរួចហើយ គាត់មានកាតព្វកិច្ចធ្វើការស៊ើបអង្កេតបឋម (មាត្រា ៥៦)។ គោលបំណងនៃការស៊ើបអង្កេតបឋមគឺដើម្បីកំណត់ថាតើមានភស្តុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ឬអត់។ ព្រះរាជអាជ្ញាអាចប្រើនគរបាលយុត្តិធម៌ឱ្យធ្វើការស៊ើបអង្កេតបឋមនេះបាន (មាត្រា ៣៦)។ នៅចុងបញ្ចប់នៃការស៊ើបអង្កេតបឋម ព្រះរាជអាជ្ញានឹងសំរេចថាតើត្រូវធ្វើការចោទប្រកាន់ ឬអត់។ បើព្រះរាជអាជ្ញាជឿជាក់ថាមានបទល្មើសកើតឡើង គាត់នឹងធ្វើការចោទប្រកាន់បឋម ដោយមានបញ្ជាក់ពីបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ និងបុគ្គលដែលត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ (មាត្រា ៦០)។ ប្រសិនបើព្រះរាជអាជ្ញាបដិសេធមិនធ្វើការចោទប្រកាន់បឋម បន្ទាប់ពីបានទទួល

ពាក្យបណ្ដឹងពីអ្នកណាម្នាក់ គាត់ត្រូវជូនដំណឹងដល់អ្នកប្ដឹងនោះអំពីការសំរេចចិត្តមិនចោទប្រកាន់របស់គាត់។ ភាគីអ្នកប្ដឹង បន្ទាប់មកមានសិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះការសំរេចរបស់ព្រះរាជអាជ្ញាទៅសាលាឧទ្ធរណ៍ (មាត្រា ៥៩)។

នៅពេលដែលការចោទប្រកាន់បឋមត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញារួចហើយ សំណុំរឿងត្រូវបានបញ្ជូនទៅឱ្យចៅក្រមស៊ើបអង្កេត (សូមមើលច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៦០)។ បន្ទាប់មកចៅក្រមស៊ើបអង្កេត ទទួលខុសត្រូវក្នុងការចាប់ផ្ដើមធ្វើការស៊ើបអង្កេតជាផ្លូវការ។ ចៅក្រមស៊ើបអង្កេតមានអំណាច យ៉ាងទូលាយក្នុងការស៊ើបអង្កេតបទព្រហ្មទណ្ឌ ហើយអាចសំភាសន៍សាក្សី ប្រមូលភស្ដុតាង ឆែកឆេរលំនៅដ្ឋាន និងស្នើសុំយោបល់ពីអ្នកជំនាញការជាដើម (មាត្រា ៨១ ៨៧ និង៨៨)។ នៅពេលដែលចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ហើយ គាត់នឹងសំរេចថាតើមានភស្ដុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ជាផ្លូវការ ឬយ៉ាងណា (មាត្រា ៩០)។ ព្រះរាជអាជ្ញាអាចប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសំរេចលើកលែងការចោទប្រកាន់នោះ (មាត្រា ៩០ និង ៩៤)។ បើជនរងគ្រោះប្ដឹងទាមទារសំណងរដ្ឋប្បវេណី ដែលកើតចេញពីសកម្មភាពខុសច្បាប់ ដែលបង្កើតបានជាមូលដ្ឋានសំរាប់ការចោទប្រកាន់បឋមនោះ[៩] ដើមបណ្ដឹងរដ្ឋប្បវេណី ក៏អាចប្ដឹងឧទ្ធរណ៍ចំពោះដីកាសំរេចលើកលែងការចោទប្រកាន់នេះដែរ (សូមមើលមាត្រា ៩១)។

ក្នុងអំឡុងពេលប្ដឹងឧទ្ធរណ៍ សាលាឧទ្ធរណ៍មានជន្ទានុសិទ្ធិអនុញ្ញាតឱ្យដើមណ្ដឹងរដ្ឋប្បវេណី បង្ហាញភស្ដុតាងដែលមិនមាននៅក្នុងដីកាសំរេចច្រានចោលការចោទប្រកាន់បឋមរបស់ចៅក្រមស៊ើបអង្កេត (មាត្រា ១៩១)។ សាលាឧទ្ធរណ៍ថែមទាំងអាចបើកការស៊ើបអង្កេតសារជាថ្មី ទៅលើអង្គហេតុទាំងឡាយ បើខ្លួនយល់ឃើញថា ការស៊ើបអង្កេតមុនៗ ធ្វើមិនបានគ្រប់ជ្រុងជ្រោយ (មាត្រា ១៩២)។ ដោយសន្មតថាចៅក្រមស៊ើបអង្កេតពេញចិត្តថា ការស៊ើបអង្កេតបានបង្ហាញភស្ដុតាងគ្រប់គ្រាន់សំរាប់ធ្វើការចោទប្រកាន់ ចៅក្រមស៊ើបអង្កេតនឹងបង្វែរសំណុំរឿង (ដែលមានព័ត៌មានទាំងអស់ដែលប្រមូលបានដោយចៅក្រមស៊ើប-អង្កេត)ទៅឱ្យព្រះរាជអាជ្ញា។ បន្ទាប់មក ព្រះរាជអាជ្ញានឹងបញ្ជាក់លើការចោទប្រកាន់បឋម ដោយធ្វើការចោទប្រកាន់ជាផ្លូវការ។ ក្រោយមក សំណុំរឿងនេះនឹងត្រូវបញ្ជូនទៅសំរាប់បើកការជំនុំជំរះ។

---

[៩] លក្ខណៈពិសេសមួយនៃនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាគឺថា រាល់បទល្មើសព្រហ្មទណ្ឌទាំងអស់ អាចបណ្ដាលឱ្យមានបណ្ដឹងពីរផ្សេងពីគ្នា គឺបណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណី (សូមមើលច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ២)។ ព្រះរាជអាជ្ញាគឺជាអ្នកសំរេចថាតើត្រូវចោទប្រកាន់ជនជាប់ចោទ នៅក្រោមច្បាប់ព្រហ្មទណ្ឌ ឬអត់ (សូម មើលមាត្រា៤ និ ៥២)។ នេះគឺជានីតិវិធីដំបូង។ លើសពីនេះ ជនរងគ្រោះអាចប្ដឹងប្រឆាំងនឹងជនជាប់ចោទក្នុងពេលជាមួយគ្នា ដើម្បីទាមទារសំណងចំពោះការខូចខាតដែលបណ្ដាលមកពីបទល្មើសនេះ (មាត្រា ៥ និង ៩)។ បណ្ដឹងទាំងពីរនេះ ជាញឹកញាប់ត្រូវបានជំនុំជំរះក្នុងពេលជាមួយគ្នា នៅចំពោះមុខចៅក្រមដដែល ដោយមុនដំបូងចៅក្រម សំរេចពីបទល្មើសព្រហ្មទណ្ឌ រួចទើបសំរេចពីបណ្ដឹងទាមទារសំណងរដ្ឋប្បវេណីលើការខូចខាត (មាត្រា ១៦)។ ទោះជាយ៉ាងនេះក្ដី ក៏វាមិនមានការតំរូវឱ្យធ្វើបណ្ដឹងទាំងពីរក្នុងពេលជាមួយគ្នា ឬជំនុំជំរះជាមួយគ្នានោះទេ (មាត្រា ៦)។ ដើមចោទដែលប្ដឹងទាមទារសំណងរដ្ឋប្បវេណី ត្រូវគេហៅថាដើមបណ្ដឹងរដ្ឋប្បវេណី។

ការជំនុំជំរះនៅតាមតុលាការខេត្ត-ក្រុង ធ្វើឡើងដោយចៅក្រមតែមួយរូបទេ (សូមមើលច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា (មាត្រា ៦)។ ចៅក្រមនោះមិនអាចជាចៅ-ក្រមដែលស៊ើបអង្កេតរឿងក្តីនោះទេ (ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩៨)។ ចៅក្រមនេះមានការទទួលខុសត្រូវចំបងក្នុងការសួរសាក្សី។ ព្រះរាជអាជ្ញា មេធាវីការពារ និងដើមបណ្តឹងរដ្ឋប្បវេណីអាចលើកជាសំណួរបានលុះត្រាណាតែចៅក្រមអនុញ្ញាតឱ្យធ្វើដូច្នោះ (មាត្រា ៣២)។ គ្រប់ភាគីទាំងអស់អាចនាំសាក្សីរបស់ខ្លួនមកចំពោះមុខតុលាការ។ សាក្សីរបស់ព្រះរាជអាជ្ញា (សាក្សីដាក់បន្ទុក) ត្រូវបានសួរមុនគេបន្ទាប់មកគឺ សាក្សីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយចុងបញ្ចប់គឺសាក្សីដោះបន្ទុក (មាត្រា ១៣៣)។ បន្ទាប់ពីសួរសាក្សីរួចរាល់ហើយ ភាគីនីមួយៗអាចនិយាយទៅតុលាការ តាមលំដាប់ដូចខាងក្រោម: ១)ដើមបណ្តឹងរដ្ឋប្បវេណី ២) ជនជាប់ចោទ ៣) មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ៤) ព្រះរាជអាជ្ញា និង ៥) មេធាវីការពារជន ជាប់ចោទ។ មុននឹងធ្វើការសន្និដ្ឋាន ចៅក្រមត្រូវពិនិត្យមើលភស្តុតាងទាំងឡាយដែលបង្ហាញដោយភាគីទាំងអស់ ក្នុង អំឡុងពេលជំនុំជំរះ (មាត្រា ១២៥)។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរឿងព្រហ្មទណ្ឌដែលខ្លួនមិនពេញចិត្ត (មាត្រា ១៥៥ ១៦១ និង ១៦៩)។

ការជំនុំជំរះនៅសាលាឧទ្ធរណ៍ ត្រូវធ្វើឡើងដោយចៅក្រមបីរូប (សូមមើលច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា មាត្រា ១១)។ មិនមានការកំរិតព្រំដែនចំពោះបណ្តឹងឧទ្ធរណ៍ទៅសាលាឧទ្ធរណ៍ឡើយ ហើយស្ទើរតែគ្រប់រឿងទាំងអស់ សាលាឧទ្ធរណ៍ធ្វើសវនាការឡើងវិញលើភស្តុតាង និងសាក្សី (ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៩៨)[១០]។ នីតិវិធីសំរាប់ធ្វើសវនាការ សាក្សី និងភស្តុតាងនៅសាលាឧទ្ធរណ៍ ប្រហាក់ប្រហែលគ្នាទៅនឹងនីតិវិធីដែលបានរៀបរាប់ពីខាងលើ សំរាប់តុលាការខេត្ត-ក្រុង (មាត្រា១៨៨-១៩១)។ ការប្តឹងសាទុក្ខទៅតុលាការកំពូលអាចធ្វើឡើងដោយភាគីពាក់ព័ន្ធ ដោយរួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ (មាត្រា ២១១)។

តុលាការកំពូលនៅក្នុងប្រទេសកម្ពុជាមានចៅក្រម៩រូប។ បណ្តឹងសាទុក្ខលើកទីមួយទៅតុលាការកំពូលត្រូវជំនុំជំរះដោយចៅក្រម៥រូប (សូមមើលច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជាមាត្រា ១៦)។ ព្រំដែននៃបណ្តឹងសាទុក្ខលើកទីមួយទៅតុលាការកំពូលមានកំរិតត្រឹមតែលើអង្គច្បាប់ប៉ុណ្ណោះ ហើយតុលាការកំពូលពិចារណាឡើងវិញលើអង្គហេតុទេ (មាត្រា ១៤) ។ ក្នុងករណីដែលរឿងក្តីព្រហ្មទណ្ឌត្រូវបានប្តឹងមកតុលាការកំពូលជាលើកទីពីរ (បន្ទាប់ពីរឿងក្តីនោះត្រូវបានបញ្ជូនត្រឡប់ទៅតុលាការថ្នាក់ក្រោមរួចហើយ )ចៅក្រមទាំង៩រូបនឹងធ្វើការជំនុំជំរះរួមគ្នា (សូមមើលច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា ២២៦)។ នៅពេលជំនុំជំនះរឿងក្តីដែលបានប្តឹងមកជាលើកទី២ តុលាការកំពូលអាចពិចារណាឡើងវិញទាំងលើអង្គហេតុ និងអង្គច្បាប់។

---

[១០] នេះជាចំណុចខុសគ្នាយ៉ាងខ្លាំងពីប្រព័ន្ធច្បាប់ Common Law ដែលការប្តឹងឧទ្ធរណ៍មិនមែនជាការកាត់ក្តីឡើងវិញជាទូទៅ នូវរាល់សេចក្តីសំរេចរបស់តុលាការជាន់ទាបឡើយ ប៉ុន្តែគឺផ្តោតទៅលើកំហុសខុសឆ្គងរបស់តុលាការជាន់ទាប ក្នុងការសំរេចចិត្តតែប៉ុណ្ណោះ។ តុលាការឧទ្ធរណ៍នៃប្រទេសកម្ពុជាមានយុត្តាធិការទំលំទូលាយ និងត្រួតគ្នាយ៉ាងខ្លាំង។

### គ. ការអនុវត្តជាក់ស្តែងក្នុងការជំនុំជំរះបទល្មើសពុករលួយ

គួរឱ្យសោកស្តាយ ទោះបីច្បាប់អ៊ុនតាក់ចាត់ទុកការស៊ីសំណូក អំពើសូកប៉ាន់ និងការគៃបំបាត់ធ្វើឡើងដោយអ្នករដ្ឋការជាបទឧក្រិដ្ឋក្តី កន្លងមកមានការផ្តន្ទាទោសតិចតួចបំផុតចំពោះបទល្មើសទាំងនោះ។ រវាងឆ្នាំ ១៩៩២ និងឆ្នាំ ១៩៩៩(ច្បាប់អ៊ុនតាក់ត្រូវបានអនុម័តនៅឆ្នាំ ១៩៩២) មិនមានការផ្តន្ទាទោសណាមួយចំពោះបទឧក្រិដ្ឋទាក់ទងនឹងអំពើពុករលួយឡើយ ទោះបីមានការទទួលស្គាល់យ៉ាង ទូលាយថាអំពើពុករលួយរីករាលដាលនៅក្នុងរដ្ឋាភិបាលក៏ដោយ[១១]។ ជារឿយៗ មានការលំបាកក្នុងការស្វែងរកព័ត៌មានគួរឱ្យទុកចិត្តស្តីពីរឿងក្តីទាំងឡាយក្នុងតុលាការកម្ពុជា[១២] ក៏ប៉ុន្តែស្ថានភាពទំនងជាល្អប្រសើរជាងមុន ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ សព្វថ្ងៃរឿងក្តីប្រឆាំងនឹងមន្ត្រីថ្នាក់ទាបនៅតាមខេត្ត ហាក់ដូចជាធម្មតា។ ក្នុងករណីខ្លះ មន្ត្រីជាន់ខ្ពស់ (ដូចអភិបាល និងអភិបាលរងខេត្ត) ទំនងជាអាចប្រើខ្សែរយៈនយោបាយរបស់ខ្លួនដើម្បីការពារខ្លួន តែក៏មានរឿងក្តីប្រឆាំងនឹងអភិបាលខេត្តផងដែរ។ ទោះបីជាយ៉ាងនេះក្តី ការពិភាក្សាជាចំហពីការពាក់ព័ន្ធរបស់មន្ត្រីជាន់ខ្ពស់ក្នុងរឿងអំពើពុករលួយ នៅតែជារឿងប្រថុយប្រថានយ៉ាងខ្លាំង[១៣]។ ជាទូទៅ ប្រព័ន្ធនេះ មើលទៅដូចជាមានការឆ្លើយតបទៅលើការចោទប្រកាន់ប្រឆាំងនឹងមន្ត្រីថ្នាក់ទាបច្រើនជាងកាលពីប្រាំមួយ ឬប្រាំពីរឆ្នាំកន្លងទៅ។

---

[១១] សូមអាន “ កម្ពុជាជា រាជាណាចក្រនៃអំពើពុករលួយ: *ព្យាយាមរកវិធីដើម្បីបង្វែរខ្សែរទឹក*” ភ្នំពេញប៉ុស្ត៍លេខ ៨/១៤ កក្កដា ៩-២២ ១៩៩៩។ សូមអានផងដែរ “ អំពើពុករលួយ: *ដែលរាលដាល គ្រប់ទិសទី និងជាបញ្ហា* ” ភ្នំពេញប៉ុស្ត លេខ ១១/១៥ ថ្ងៃទី៩ កក្កដា និង ១ សីហា ២០០២។

[១២] គ្មានព័ត៌មានផ្សាយជាសាធារណៈថាតើរឿងក្តីប្រភេទនីមួយៗចំនួនប៉ុន្មាន ត្រូវបានជំនុំជំរះរៀងរាល់ឆ្នាំ ហើយសេចក្តីសំរេចជាស្ថាពររបស់តុលាការក៏មិនត្រូវបានចាត់ទុកជាព័ត៌មានសាធារណៈដែរ។ គេអាចទទួលបានព័ត៌មានមួយចំនួនពីសកម្មភាពរបស់តុលាការ តាមរយៈសារព័ត៌មាន ប៉ុន្តែព័ត៌មាននេះមានលក្ខណៈចង្អៀតណាស់ ហើយការជ្រើសរើសរឿងក្តីពីតុលាការមកផ្សាយមានភាពលំអៀងទៀតផង។ តែទោះយ៉ាងណាក៏ដោយ ក្នុងករណីភាគច្រើន សារព័ត៌មានគឺជាប្រភពព័ត៌មានតែមួយគត់។

[13] ការចោទប្រកាន់ពីអំពើពុករលួយប្រឆាំងនឹងមន្ត្រីជាន់ខ្ពស់ ហាក់ដូចជាទទួលបានការចោទប្រកាន់បកមកវិញពីបទបរិហារកេរ្តិ៍ ឬផ្សព្វផ្សាយព័ត៌មានមិនពិត សំរាប់អ្នកដែលធ្វើការចោទប្រកាន់នោះ។ បទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិត គឺជាបទល្មើសព្រហ្មទណ្ឌ ទោះបីជាទោសដាក់គុកត្រូវបានដកចេញពីការផ្តន្ទាទោសសំរាប់បទបរិហារកេរ្តិ៍ កាលពីឆ្នាំ ២០០៦ ក៏ដោយ។ បុគ្គលជាច្រើននាក់ដែលបានធ្វើការចោទប្រកាន់មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលពីបទពុករលួយ ត្រូវបានចាប់បញ្ជូនទៅពន្ធនាគារ ឬបានគេចខ្លួនទៅក្រៅប្រទេស។ ជាឧទាហរណ៍ លោក សម រង្ស៊ី ត្រូវបានកាត់ទោសកំបាំងមុខឱ្យជាប់ពន្ធនាគារចំនួន ១៨ ខែ ពីបទបរិហារកេរ្តិ៍ ដែលចោទប្រកាន់ថានាយករដ្ឋមន្ត្រី ហ៊ុន សែន បានសូក ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា ចំនួន ៣០ លានដុល្លារ និងយន្តហោះមួយក្នុងអំឡុងនៃការចរចារបង្កើតរដ្ឋាភិបាលចំរុះ ក្នុងឆ្នាំ ២០០៤។ សូមមើល “ *សម រង្ស៊ី ត្រូវបានកាត់ទោសជាប់គុក ១៨ខែ*” កាសែតខេមបូឌៀ ដេលី ថ្ងៃទី ២៣ ធ្នូ ២០០៥។

ក្នុងឆ្នាំ ២០០៦ មានការជំនុំជំរះខ្លះៗពីរឿងពុករលួយ ដែលធ្វើឡើងចំពោះមន្ត្រីថ្នាក់ខេត្ត ហើយជាញឹកញាប់ធ្វើទៅលើបទចោទប្រកាន់ក្នុងការកាប់ឈើខុសច្បាប់ និងរានចាប់យកដីខុសច្បាប់[១៤]។ នៅក្នុងរឿងក្តីដ៏ល្បីមួយ មន្ត្រី ១៤ នាក់ មកពីខេត្តរត្តនគីរី ត្រូវបានចោទប្រកាន់ថាបានពាក់ព័ន្ធក្នុងការកាប់ឈើខុសច្បាប់ដែលមានតំលៃរាប់លានដុល្លារ នៅក្នុងឧទ្យានជាតិវីរៈជ័យ។ ក្នុងដំណាក់កាលដំបូង រឿងក្តីត្រូវជាប់គាំង ដោយមន្ត្រីតុលាការថ្នាក់ក្រោមមិនមានចេតនា ឬមិនមានលទ្ធភាពស៊ើបអង្កេតលើការចោទប្រកាន់នោះ។ក៏ប៉ុន្តែការស៊ើបអង្កេតបានដំណើរការឡើងវិញ ក្រោយពីសំណុំរឿងនោះត្រូវបានផ្ទេរទៅតុលាការក្រុងភ្នំពេញ។នៅទីបំផុត មន្ត្រីជាន់ទាបចំនួន ១១នាក់ ដែលក្នុងនោះរួមមានឧទ្យានុរក្ស និងនគរបាលព្រំដែន ត្រូវបានកាត់ទោសពីបទចោទប្រកាន់ថាបានប្រព្រឹត្តអំពើពុករលួយ ទទួលសំណូកដើម្បីអនុញ្ញាតឱ្យរថយន្តធុនធំដឹកឈើហ៊ុបខុសច្បាប់ចេញពីឧទ្យានជាតិ។ ក៏ប៉ុន្តែ ការជំនុំជំរះមន្ត្រីជាន់ខ្ពស់បីនាក់ទៀត គឺអតីតអភិបាលខេត្ត អតីតស្នងការនគរបាលខេត្ត និងបញ្ជាការយោធាខេត្ត ត្រូវបានផ្អាក ដោយសារមានបញ្ហាជាមួយនឹងសាក្សី និងភស្តុតាង[១៥]។ មន្ត្រីជាន់ខ្ពស់ទាំងបីនាក់នោះ គឺជាសមាជិករបស់ គណបក្សប្រជាជនកម្ពុជា។ ក្នុងចំណោមមន្ត្រីទាំងបីនាក់ មានតែម្នាក់ប៉ុណ្ណោះដែលកំពុងជាប់ឃុំឃាំងក្នុងពន្ធនាគារ ឯពីរនាក់ទៀតកំពុងគេចខ្លួន។ លទ្ធផលនៃរឿងក្តីនេះបានបង្ហាញថា យ៉ាងហោចណាស់ ការជំនុំជំរះអំពើពុករលួយប្រឆាំងនឹងមន្ត្រីថ្នាក់ទាបបាន និងកំពុងក្លាយជារឿងធម្មតា ប៉ុន្តែសំរាប់មន្ត្រីជាន់ខ្ពស់ ក្នុងករណីខ្លះអាចមានចំណងទាក់ទងខាងនយោបាយ ដែលធ្វើឱ្យរួចផុតពីការចោទប្រកាន់ពីបទពុករលួយ[១៦]។

ក្នុងរឿងក្តីដ៏ល្បីមួយទៀត ធនាគារពិភពលោកបានផ្អាកថវិកាលើគំរោងដែលផ្តល់ថវិកាដោយធនាគារ កាលពីខែឧសភា ២០០៦ បន្ទាប់ពីការស៊ើបអង្កេតផ្ទៃក្នុងមួយបាន រកឃើញថាមានភស្តុតាងពីអំពើពុករលួយ ដោយមន្ត្រីរដ្ឋាភិបាល។ កាលពីដំបូងរដ្ឋាភិបាលបានប្រតិកម្មតបដោយក្តីសង្ស័យ ហើយមន្ត្រីជាន់ខ្ពស់ជាច្រើនរូប ដែលក្នុងនោះមាននាយករដ្ឋមន្ត្រី ហ៊ុន សែន ផងដែរ បានចោទសួរចំពោះការរកឃើញ

---

[១៤] ឧទាហរណ៍សូមអាន " *មន្ត្រីក្រុងព្រះសីហនុ ត្រូវបានចាប់ខ្លួន ទាក់ទិននឹងរឿងដីធ្លី* " កាសែតខេមបូដៀដេលី ថ្ងៃទី ២១ កក្កដា ២០០៦ ទំព័រ ១៧ (មន្ត្រីសុរិយោដីក្រុងព្រះសីហនុ ត្រូវបានចោទប្រកាន់លើបទប៉ុនប៉ងក្លែងប័ណ្ណកម្មសិទ្ធិដី ៥ ហិកតា ជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ។ " *ប្រពន្ធ និងមន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងឈើហ៊ុប* " កាសែតខេមបូឌៀដេលី ថ្ងៃទី ១៧ កក្កដា ២០០៦ ទំព័រ ២១ (អនុប្រធានសង្កាត់រដ្ឋបាលព្រៃឈើនៅខេត្តកំពត ត្រូវបានចោទប្រកាន់ពីបទប្រើប្រាស់តួនាទីរបស់ខ្លួន ដើម្បីជួយប្រពន្ធ ក្នុងការបើកអាជីវកម្មកាប់ឈើខុសច្បាប់។

[១៥] សូមមើល "*ការជំនុំជំរះមន្ត្រីជាន់ខ្ពស់ខេត្តរត្តនគីរីបីរូបពីបទពុករលួយ ត្រូវបានពន្យាពេល* " ខេមបូឌៀដេលី ថ្ងៃទី ២១ កក្កដា ឆ្នាំ ២០០៦ ទំព័រ ១៤។ " *ការជំនុំជំរះរឿងកាប់ឈើខុសច្បាប់នៅខេត្តរត្តនគីរី ចាប់ផ្តើមនៅថ្ងៃព្រហស្បតិ៍* " ខេមបូឌៀដេលី ថ្ងៃទី ១៩ កក្កដា ២០០៦ ទំព័រ ១២។

[១៦] ម្យ៉ាងវិញទៀត ក្នុងរឿងក្តីលេចធ្លោមួយកាលពីពេលថ្មីៗនេះ អតីតអភិបាលខេត្តកំពត ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ តាមមាត្រា ៣៨ នៃច្បាប់អ៊ុនតាក់ ពីអំពើពុកលួយថាបានចូលរួមក្នុងការរានដី និងកាប់ព្រៃខុសច្បាប់ ។ សូមមើល " *អតីតអភិបាលខេត្តជាប់ចោទពីបទល្មើសរឿងដីធ្លី*" ខេមបូឌៀដេលី ថ្ងៃទី ១៩ កក្កដា ២០០៦ ទំព័រ ១១។

របស់ធនាគារ[១៧]។ ទោះជាយ៉ាងណា ក្នុងខែកក្កដា ឆ្នាំ២០០៦ អតីតប្រធានគំរោងមួយដែលផ្តល់ថវិកាដោយធនាគារពិភាពលោក ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទគៃបំបាត់ ក្រោមមាត្រា ៣៧ នៃច្បាប់អ៊ុនតាក់។ មន្ត្រីនោះត្រូវបានចោទប្រកាន់ថាបានគៃបំបាត់ ច្រើនជាង ៨០០.០០០ ដុល្លារ ពីកិច្ចសន្យាកសាងផ្លូវចំនួនបួនខ្សែ ហើយត្រូវបានឃុំខ្លួនបណ្តោះអាសន្នភ្លាមៗ តែម្តង[១៨] ។

មានអំពើពុករលួយគួរកត់សំគាល់ក្នុងដំណើរនៃការប្រមូលពន្ធដារ [១៩]។ យោងតាមការសិក្សាថ្មីៗដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា រដ្ឋាភិបាលប្រមូលបានតែ ២៥ ភាគរយ នៃចំណូលពន្ធដារជាសក្តានុពល ហើយមូលហេតុធំគឺមកពី "ការបង់ប្រាក់ក្រៅផ្លូវការដល់មន្ត្រីរដ្ឋាភិបាល ដើម្បីជៀសវាងការបង់ពន្ធ" [២០]។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវលើឯកសារសាធារណៈ និងរបាយការណ៍សារព័ត៌មាន មិនបាននិយាយពីការផ្តន្ទាទោសណាមួយចំពោះមន្ត្រីពន្ធដារដែលស៊ីសំណូក ក្រោមច្បាប់អ៊ុនតាក់ ឬក្រោមបទបញ្ញត្តិជាក់លាក់នៃច្បាប់ស្តីពីសារពើពន្ធឡើយ។

## IV ដំណើរការនីតិវិធីរដ្ឋបាល

ក្រៅពីដំណើរការនីតិវិធីព្រហ្មទណ្ឌជាផ្លូវការសំរាប់អំពើពុករលួយ ដែលអាចនាំទៅដល់ការជាប់ពន្ធនាគារ និងលទ្ធភាពនៃបណ្តឹងរដ្ឋប្បវេណីស្របជាមួយគ្នាសំរាប់សំណងលើព្យសនកម្ម ច្បាប់ជាច្រើនរបស់ប្រទេសកម្ពុជា ក៏បង្កើតឱ្យមានផងដែរនូវដំណើរការនីតិវិធីរដ្ឋបាលដើម្បីឆ្លើយតបនឹងអំពើពុករលួយ។ ដំណើរការនីតិវិធីទាំងនេះ ដែលជាទូទៅត្រូវបានធ្វើឡើងនៅក្នុងក្រសួងឬស្ថាប័នរបស់រដ្ឋាភិបាល អាចនាំឱ្យមានការស្តីបន្ទោស ការដកថានៈ ការបាត់បង់ផលប្រយោជន៍ ឬបញ្ឈប់ពីការងារសំរាប់និយោជិត។ មិនមានឧបសគ្គរារាំងដល់ការចោទប្រកាន់មន្ត្រីរាជការពីបទល្មើសដែលទាក់ទងនឹងអំពើពុករលួយ ការប្តឹងរដ្ឋប្បវេណីក្នុងពេលជាមួយគ្នា ក៏ដូចជាការចោទប្រកាន់នៅក្រោមដំណើរការនីតិរដ្ឋបាលដូចខាងក្រោមទេ។ មន្ត្រីរាជការថានៈផ្សេងគ្នា ស្ថិតនៅក្រោមដំណើរការនីតិវិធីរដ្ឋបាលខុសៗគ្នា។ ជាឧទាហរណ៍ចៅក្រមត្រូវស្ថិតនៅក្រោមនីតិវិធីមួយ នៅពេលដែលមន្ត្រីរាជការស៊ីវិលត្រូវស្ថិតនៅក្រោម នីតិវិធីដោយឡែកមួយទៀត។ យន្តការរដ្ឋបាលផ្សេងៗគ្នាសំរាប់ទប់ស្កាត់អំពើពុករលួយ នឹងលើកមកពិភាក្សា ដូចតទៅនេះ។

---

[១៧] សូមអាន " *ការអះអាង និងការអះអាងតបវិញ* " ភ្នំពេញប៉ុស្តិ៍ លេខ ១៥/១៣ ថ្ងៃ ៣០ មិថុនា ១៣ កក្កដា ២០០៦។ "*ហ៊ុន សែន និយាយថា នៅតែរង់ចាំភស្តុតាងពីធនាគារពិភពលោក* " ខេមបូឌៀដេលី ១៩ កក្កដា ២០០៦ ទំព័រ ១២។

[១៨] សូមអាន "*មន្ត្រីរដ្ឋាភិបាលត្រូវបានចាប់ខ្លួន ក្នុងរឿងក្តីជាមួយធនាគារពិភពលោក*" ខេមបូឌៀដេលី ២០ កក្កដា ២០០៦ ទំព័រ ១៦។

[១៩] ជាឧទាហរណ៍សូមអាន " *មន្ត្រីពន្ធដារកំពូលចេញទៅ ប្រព័ន្ធរញ៉េរញ៉ៃនៅបន្ត* " ភ្នំពេញប៉ុស្តិ៍ លេខ ១៣/២៧ ៣១ ធ្នូ ២០០៤ - ១៣ មករា ២០០៥។

[២០] សូមអាន " *រដ្ឋមន្ត្រីហិរញ្ញវត្ថុមានប្រសាសន៍ព្រលះរបាយការណ៍ពីអំពើពុករលួយ*" ខេមបូឌៀដេលី ១៩ កក្កដា ២០០៦ ទំព័រ ១២។

### គ. មន្ត្រីរាជការស៊ីវិល

មន្ត្រីរាជការស៊ីវិលកម្ពុជា ដែលរួមទាំងចៅក្រម និងមន្ត្រីរាជការដែលបំរើការក្នុងស្ថាប័ននីតិបញ្ញត្តិ ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល (សូមមើលច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល មាត្រា ១)។ នៅពេលបំពេញការងារ ពួកគេត្រូវគោរពច្បាប់ និងត្រូវហាមឃាត់មិនឱ្យ "ប្រើប្រាស់ឥទ្ធិពល និងអំណាចនៅក្នុងមុខងាររបស់ខ្លួនដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុតគំរាមកំហែង ឬបំពានសិទ្ធិរបស់ប្រជាពលរដ្ឋ (មាត្រា ៣៣-៣៥)។ អំពើបំពាននឹងបញ្ញត្តិនៃមាត្រានេះ អាចបណ្តាលឱ្យទទួលទណ្ឌកម្មផ្នែកវិន័យ (មាត្រា ៣៩)។

តាមពិត មានដំណើរការនីតិវិធីរដ្ឋបាលពីរផ្សេងគ្នា ដែលមានចែងនៅក្នុងច្បាប់ស្តីពីមន្ត្រីរាជការ-ស៊ីវិល ដោយអាស្រ័យទៅតាមទងន់នៃកំហុស និងទណ្ឌកម្មដែលបានលើកឡើង។ កំហុសស្រាលត្រូវបានគេឱ្យឈ្មោះថា "ជាកំហុសថ្នាក់ទី១"។ ទណ្ឌកម្មសំរាប់កំហុសថ្នាក់ទី១ ត្រូវកំណត់ត្រឹមៈ ១) ស្តីបន្ទោស ២) ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ៣) លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ៤)ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ ដែលហាក់សំដៅលើការផ្លាស់ទៅធ្វើការងារថ្មីក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល (សូមមើលច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល មាត្រា ៤០)។ មន្ត្រីរាជការស៊ីវិលដែលត្រូវចោទប្រកាន់ពីកំហុសថ្នាក់ទី១ មានសិទ្ធិប្តឹងសើរើ លើការចោទប្រកាន់ចំពោះខ្លួន ដោយធ្វើការពន្យល់ជាលាយល័ក្ខណ៍អក្សរ។ សូមមើលអនុក្រឹត្យស្តីពីការបង្កើតនីតិវិធី សំរាប់ដាក់ទណ្ឌកម្មខាងវិន័យលើមន្ត្រីរាជការស៊ីវិល ចុះថ្ងៃទី ២៨ មករា ឆ្នាំ ១៩៩៧ (ដែលក្រោយមក ហៅថាអនុក្រឹត្យស្តីពីទណ្ឌកម្មខាងវិន័យលើមន្ត្រីរាជការ) ត្រង់ មាត្រា ៣។ រដ្ឋមន្ត្រីនៃក្រសួងដែលមន្ត្រីរាជការរងការចោទប្រកាន់នោះបំរើការ (រដ្ឋមន្ត្រីពាក់ព័ន្ធ) បន្ទាប់មកត្រូវពិនិត្យឯកសារផ្ទាល់ខ្លួន និងការពន្យល់ជាលាយល័ក្ខណ៍អក្សររបស់មន្ត្រីរាជការ រួចមកទើបសំរេចថាតើត្រូវអនុវត្តទណ្ឌកម្មណាមួយ ដូចបានរៀបរាប់ខាងលើ (មាត្រា ៤)។ មន្ត្រីរាជការស៊ីវិលមិនមានសិទ្ធិសុំអោយមានសវនាការទេ ហើយរដ្ឋមន្ត្រីអាចសំរេចដោយឯកឯងលើសំណុំឯកសារផ្ទាល់ខ្លួន និងការពន្យល់ជាលាយល័ក្ខណ៍អក្សរ។ មិនមានយន្តការសំរាប់ប្តឹងតវ៉ាឡើយ។

កំហុសដែលធ្ងន់ធ្ងរជាងនេះ ត្រូវគេហៅថា កំហុសថ្នាក់ទី២ [២១]។ ទណ្ឌកម្មសំរាប់ទោសកំហុសថ្នាក់ទី២ គឺៈ ១) ស្តីន្ទោសជាទំងន់ បណ្តាលអោយលុបចេញពីតារាងឡើងឋានន្តរស័ក្តិ ២)ដាក់ឱ្យនៅទំនេរគ្មានបៀវត្ស មិនលើសពីមួយឆ្នាំ ៣)បន្ថយឋានន្តរស័ក្តិ ឬថ្នាក់ មួយថ្នាក់ ឬច្រើនថ្នាក់ ៤)ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ និង ៥) បណ្តេញចេញពីមុខដំណែងរាជការ (សូមមើលច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល មាត្រា ៤០ )។ មាននីតិវិធីលំអិតជាង ក្នុងដំណើរសំរាប់ទោសកំហុសថ្នាក់ទី២។ ដើម្បីចាប់ផ្តើម ក្រសួងពាក់ព័ន្ធត្រូវធ្វើការ

---

[២១] គ្មាននិយមន័យជាផ្លូវការអំពីអ្វីជាការរំលោភលើច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល ដែលនាំឱ្យមានកំហុសថ្នាក់ទី១ ឬថ្នាក់ទី២នោះឡើយ ។ ផ្ទុយទៅវិញគ្រាន់តែបញ្ជាក់ថា ទោសកំហុសមួយដែលត្រូវកំណត់ចូលក្នុងថ្នាក់ទីមួយ ឬថ្នាក់ទី២ គឺអាស្រ័យទាំងស្រុងលើទណ្ឌកម្មដែលត្រូវដាក់។ មានន័យថា អំពើតែមួយដូចគ្នា នៅពេលខុសគ្នា អាចត្រូវបានដាក់ទណ្ឌកម្មខុសគ្នា ថាជាបទល្មើសថ្នាក់ទី១ ឬថ្នាក់ទី២ ទៅតាមឆន្ទានុសិទ្ធិ របស់រដ្ឋមន្ត្រីពាក់ព័ន្ធ។ កង្វះខាតនូវនិយមន័យនេះ នាំឱ្យមានឱកាសនៃការអនុវត្តមិនស្របគ្នា និងអនុគ្រោះនិយម។

ស៊ើបអង្កេតបឋមមួយ។ បន្ទាប់មក របាយការណ៍នៃការស៊ើបអង្កេតបឋមត្រូវបញ្ជូនទៅឱ្យរដ្ឋមន្ត្រីពាក់ព័ន្ធដែលជាអ្នកសំរេចថាតើនឹងបន្តនីតិវិធីទៅទៀតឬអត់ ដាក់ទណ្ឌកម្មថ្នាក់ទី១កំរិតស្រាល ឬបដិសេធនីតិវិធីទាំងមូលតែម្តង (សូមមើលអនុក្រិត្យស្តីពីទណ្ឌកម្មខាងវិន័យសំរាប់មន្ត្រីរាជការស៊ីវិល មាត្រា ៦)។

ប្រសិនបើរដ្ឋមន្ត្រីសំរេចបន្តនីតិវិធី គេត្រូវចាត់តាំងឱ្យមានក្រុមប្រឹក្សាវិន័យមួយ មានសមាជិក ៥រូប ដែល ៣ រូបជ្រើសរើសដោយរដ្ឋមន្ត្រីពាក់ព័ន្ធ។ ក្នុងចំណោមអ្នកទាំងបីដែលជ្រើសរើដោយរដ្ឋមន្ត្រីនោះ ម្នាក់នឹងក្លាយជាប្រធានក្រុមប្រឹក្សា ម្នាក់ទៀតជាអ្នករាយការណ៍ ហើយអ្នកចុងក្រោយគ្រាន់តែជាសមាជិកធម្មតាប៉ុណ្ណោះ។ សមាជិក ២ នាក់ទៀតនៃក្រុមប្រឹក្សាវិន័យ គឺជាមនុស្សដែលស្ថិតក្នុងក្របខ័ណ្ឌជាមួយគ្នានឹងអ្នករាជការជាប់ចោទ (មាត្រា ៨)។ បន្ទាប់មក អ្នករាយការណ៍ត្រូវពិនិត្យមើលឯកសារផ្ទាល់ខ្លួនរបស់អ្នករាជការជាប់ចោទ រួចទើបធ្វើការអង្កេត។ នៅចុងបញ្ចប់នៃការអង្កេត អ្នករាយការណ៍ត្រូវរៀបចំរបាយ-ការណ៍ជាលាយលក្ខអក្សរដាក់ជូនក្រុមប្រឹក្សាវិន័យ (មាត្រា ១០)។ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំ ដើម្បីបើកសវនាការ។ អ្នករាជការជាប់ចោទអាចមានអ្នកតំណាងនៅពេលសវនាការនេះ ហើយមានសិទ្ធិហៅសាក្សីព្រមទាំងធ្វើបទបង្ហាញដោយផ្ទាល់មាត់ ឬ លាយលក្ខណ៍អក្សរ (មាត្រា ១២ ហើយសូមមើលផងដែរច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល មាត្រា ៤៩)។ បន្ទាប់ពីស្តាប់ភស្តុតាង ក្រុមប្រឹក្សាវិន័យត្រូវបោះឆ្នោតជាសំងាត់ដើម្បីកំណត់ពីទណ្ឌកម្ម។ ក្រុមប្រឹក្សានឹងដាក់របាយការណ៍ពីការកំណត់ទណ្ឌកម្មនេះជូនទៅរដ្ឋមន្ត្រីពាក់ព័ន្ធដែលជាអ្នកធ្វើសេចក្តីសំរេចចុងក្រោយពីទណ្ឌកម្មណាខ្លះដែលត្រូវអនុវត្ត (សូមមើលអនុក្រិត្យស្តីពីទណ្ឌកម្មខាងវិន័យសំរាប់មន្ត្រីរាជការស៊ីវិល មាត្រា ១៣-១៤)។បើរដ្ឋមន្ត្រីសំរេចឱ្យដាក់ទណ្ឌកម្មស្រាលជាង គាត់ត្រូវពន្យល់ពីមូលហេតុជាលាយល័ក្ខណ៍អក្សរ (មាត្រា ១៥)។

មិនមានមូលហេតុផ្លូវច្បាប់ ថាហេតុអ្វីបានជាមន្ត្រីរាជការស៊ីវិលដែលបានពាក់ព័ន្ធនឹងអំពើពុករលួយមិនអាចត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ និងផ្តន្ទាទោសដំណើរការនីតិវិធីរដ្ឋបាល ក្រោមច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល។ យ៉ាងណាមិញ មាត្រា ៥១ នៃច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល បានដាក់ចេញនូវព្រំដែនសំរាប់ការផ្តន្ទា-ទោសមន្ត្រីរាជការស៊ីវិល។ នៅពេលធ្វើសេចក្តីព្រាងដើម កាលពីឆ្នាំ ១៩៩៤ មាត្រា ៥១ បានហាមឃាត់មិនឱ្យមានការ ផ្តន្ទាទោសមន្ត្រីរាជការស៊ីវិលពីបទល្មើសព្រហ្មទណ្ឌឡើយ លើលែងតែគណៈរដ្ឋមន្ត្រី (សំរាប់មន្ត្រីរាជការជាន់ខ្ពស់) ឬរដ្ឋមន្ត្រីពាក់ព័ន្ធ (សំរាប់មន្ត្រីថ្នាក់ទាប) ផ្តល់ការអនុញ្ញាតឱ្យធ្វើការផ្តន្ទាទោសជាមុនសិន។ ចំណុចនេះត្រូវបានទទួលការរិះគន់ថា បានផ្តល់អភ័យឯកសិទ្ធិយ៉ាងខ្លាំងដល់មន្ត្រីរាជការ ឱ្យរួចផុតពីការផ្តន្ទាទោសព្រហ្មទណ្ឌ។[២២]

ក្នុងឆ្នាំ ១៩៩៩ គេបានធ្វើវិសោធកម្មលើមាត្រា ៥១។ ព្រះរាជអាជ្ញាមិនចាំបាច់មានការអនុញ្ញាតពីរដ្ឋាភិបាល ដើម្បីចោទប្រកាន់មន្ត្រីរាជការពីបទព្រហ្មទណ្ឌដូចមុនទៀតឡើយ តែជាជំនួសគាត់ត្រូវជូនដំណឹងទៅក្រសួងពាក់ព័ន្ធក្នុងអំឡុងពេល ៧២ ម៉ោង បន្ទាប់ពីការសំរេចចោទប្រកាន់មន្ត្រីរាជការ។ លើសពីនេះ

---

[២២] សូមអាន "*ការជំនុំជំរះ និងពលរទុក្ខ នៅក្រសួងយុត្តិធម៌*" ភ្នំពេញប៉ុស្តិ៍ លេខ ៨/១៦ ថ្ងៃទី ៦-១៩ សីហា ១៩៩៩ (" មាត្រា ៥១ ... ត្រូវបានស្តីបន្ទោសដោយអង្គការសិទ្ធិមនុស្សថា ជាយន្តការដែលជំរុញឱ្យមានទម្លាប់និទណ្ឌភាព សំរាប់មន្ត្រីរាជការ ")។

ប្រសិនបើបទល្មើសដែលបានចោទប្រកាន់នោះ កើតឡើងក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីសាធារណៈ រដ្ឋាភិបាលមានកាតព្វកិច្ចការពារមន្ត្រីរាជការស៊ីវិលនោះ[២៣]។ ច្បាប់វិសោធកម្មមាត្រា ៥១ ទទួលបានការរិះគន់ ដោយសារតែវាបង្កើតឱ្យមានគោលការណ៍មួយតែអនុវត្តពីរបែប (Double standard) សំរាប់មន្ត្រី-រាជការស៊ីវិល ហើយអាចឱ្យមន្ត្រីរាជការទាំងនោះបានដឹងខ្លួនជាមុនថាមានការសំរេចចោទប្រកាន់ ដែលការណ៍នេះ បានផ្តល់ឱកាសឱ្យមន្ត្រីរាជការទាំងនោះរត់គេចផុតពីសំណាញ់ច្បាប់[២៤]។

វាហាក់ដូចជាមិនមានពត៌មានជាសាធារណៈ ថាតើមានដំណើរការនីតិវិធីរដ្ឋបាលប៉ុន្មាន ដែលគេយកមកអនុវត្តនៅក្នុងច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល។ តាមពិតមនុស្សជាច្រើន ដែលរួមទាំងមេធាវីខ្មែរមួយចំនួនផង មិនបានដឹងពីនីតិវិធីខាងវិន័យសំរាប់មន្ត្រីរាជការស៊ីវិលឡើយ។ ការណ៍នេះបង្ហាញថា ដំណើរការនីតិវិធី ប្រព្រឹត្តទៅដោយសំងាត់ជាខ្លាំង ឬក៏មិនសូវកើតមានឡើងផង[២៥]។ បណ្តឹងអំពីមន្ត្រីរាជការស៊ីវិលត្រូវដោះស្រាយតាមរយៈរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ (សូមមើលអនុក្រិត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចុះថ្ងៃទី ២៨ ឧសភា ១៩៩៧ មាត្រា ៣)។ ទោះជាយ៉ាងនេះក្តី អ្នកនិពន្ធមិនអាចរកបាននូវព័ត៌មានស្តីពីការរៀបចំអង្គភាពនេះឡើយ។

.

## ខ.ចៅក្រម និងព្រះរាជអាជ្ញា

តុលាការត្រូវបានបង្កើតឡើងជា " អំណាចឯករាជ្យ" ដែល "ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ" (សូមមើលរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៨)។ ដើម្បីជួយដល់អានាគតិភាព ឬភាពមិនលំអៀងរបស់តុលាការ ចៅក្រមមិនអាចត្រូវបានបណ្តេញចេញពីការងារ ដោយក្រសួងយុត្តិធម៌ឡើយ (មាត្រា ១៣៣)។ មានតែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ ដែលមានអំណាចចាត់តាំងចៅក្រមថ្មី និងដាក់វិន័យលើចៅក្រមក្នុង មុខងារ (មាត្រា ១៣៣-១៣៤)។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសមាជិក ៩ រូប ហើយព្រះមហាក្សត្រគឺជាព្រះប្រធានដោយស្វ័យប្រវត្តិ (សូមមើលច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មាត្រា ២ )។ សមាជិកផ្សេងទៀតរួមមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល និងសាលាឧទ្ធរណ៍ និងចៅក្រមបីរូបទៀតដែលជ្រើសរើសដោយចៅក្រម ។

---

[២៣] អំពើពុករលួយតែងតែកើតមានឡើងក្នុងក្របខ័ណ្ឌនៃមុខងារសាធារណៈ ពីព្រោះធាតុផ្សំមួយនៃបទល្មើសដែលត្រូវតែបង្ហាញច្បាស់ គឺថាមន្ត្រីរាជការនោះកំពុងធ្វើសកម្មភាពក្នុងព្រំដែននៃភារកិច្ចរបស់ខ្លួន ក្នុងខណៈពេលអំពើពុករលួយកើតឡើង ។ ដោយអានឱ្យហ្មតចត់ទៅឃើញថា មាត្រា ៥១ អាចបង្ខំរដ្ឋាភិបាលឱ្យការពារមន្ត្រីរាជការស៊ីវិល ដែលរដ្ឋាភិបាលខ្លួនឯងចោទប្រកាន់ពីអំពើពុករលួយ។

[២៤] សូមអាន "*ការជំនុំជំរះ និងពលវទុក្ខ នៅក្រសួងយុត្តិធម៌* " ភ្នំពេញប៉ុស្ត៍ លេខ ៨/១៦ ថ្ងៃទី ៦-១៩ សីហា ១៩៩៩ ។

[២៥] កាលពីថ្ងៃទី ៥ ធ្នូ ឆ្នាំ ២០០៦ មានរបាយការណ៍នៅក្នុងកាសែតខេមបូឌៀដេលីថា រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ គាត ឈន់ បានប្រកាសថាមន្ត្រីរាជការនៅក្នុងនាយកដ្ឋានគយ និងរដ្ឋាករ នឹងទទួលការផាកពិន័យខាងរដ្ឋបាល សំរាប់ការពាក់ព័ន្ធ ក្នុងការរត់ពន្ធរថយន្តចង្កូតស្តាំ និងប្រភេទស្ព័រប្រមាណជា ៨០០ គ្រឿង ដែលនាំចូលតាមច្រកព្រំដែនថៃ នៅក្នុងខេត្តបន្ទាយមានជ័យ។ ចំនួននៃការផាកពិន័យនេះ មិនត្រូវបានដឹងឡើយ ហើយលោក គាត ឈន់ មិនបាននិយាយអំពីទណ្ឌកម្មលើមន្ត្រីរាជការ ក្រៅពីការផាកពិន័យឡើយ។ គេនិយាយថា អំពើពុករលួយនោះ ត្រូវបានរកឃើញដោយអង្គភាពប្រឆាំងអំពើពុករលួយរដ្ឋាភិបាល។

នៅពេលសំរេចពីវិធានការវិន័យលើចៅក្រម ឬព្រះរាជអាជ្ញា អនុក្រុមនៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួបប្រជុំក្នុងឋានៈជាក្រុមប្រឹក្សាវិន័យ (ព្រះមហាក្សត្រ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនចូលនៅក្នុងក្រុមប្រឹក្សាវិន័យទេ) ដែលមានប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលជាប្រធាន អាស្រ័យលើអ្នកដែលត្រូវចោទប្រកាន់នោះជាចៅក្រម ឬព្រះរាជអាជ្ញា (មាត្រា ១២)។ ច្បាប់នេះមិនបានលំអិតអំពីអ្វីដែលត្រូវធ្វើក្នុងពេលសវនាការទេ គឺគ្រាន់តែបញ្ជាក់ថា ការបោះឆ្នោតដាក់វិន័យណាមួយ ត្រូវធ្វើជាសំងាត់ (មាត្រា ១៨)។ ជាឧទាហរណ៍ ក្នុងច្បាប់នេះមិនមានចែងច្បាស់សោះ ថាតើអ្នកដែលទទួលចោទប្រកាន់ ឬក៏អ្នកប្តឹងមានសិទ្ធិចូលរួមក្នុងសវនាការ និងការពារខ្លួនក្នុងសវនាការឬអត់[២៦]។ បន្ទាប់មក អនុសាសន៍របស់ក្រុមប្រឹក្សាវិន័យ នឹងត្រូវបញ្ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីសំរេច (មាត្រា ១៥)។ សេចក្តីសំរេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនបើកឱ្យមានបណ្តឹងតវ៉ាទេ។

មិនមានយន្តការផ្លូវការនៅក្នុងច្បាប់ សំរាប់ឱ្យសាធារណជនដើម្បីប្តឹងទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ។ ប៉ុន្តែសេចក្តីរាយការណ៍របស់សារព័ត៌មានបានបង្ហាញថា ក្រសួងយុត្តិធម៌បានផ្តល់ការគាំទ្រខាងរដ្ឋបាលដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយរាល់បណ្តឹងអំពីចៅក្រម និងព្រះរាជអាជ្ញា ត្រូវដាក់តាមរយៈក្រសួងយុត្តិធម៌[២៧]។ ដូចនេះ វាហាក់ដូចជាក្រសួងយុត្តិធម៌ ក៏ធ្វើការស៊ើបអង្កេតបឋមលើពាក្យបណ្តឹងទាំងនោះផងដែរ។

តុលាការខ្មែរត្រូវបានសាធារណជនយល់ឃើញថាជាស្ថាប័នពុករលួយបំផុត ក្នុងចំណោមស្ថាប័នរដ្ឋនៃប្រទេសកម្ពុជា ដែលការណ៍នេះទាមទារឱ្យឧត្តមក្រុមប្រឹក្សាឆ្លើយតបទៅនឹងអំពើពុករលួយនៅក្នុងវិស័យតុលាការ[២៨]។ ក៏ប៉ុន្តែ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានភាពអសកម្មយ៉ាងខ្លាំង រហូតដល់ខែ មិនា ឆ្នាំ

---

[២៦] លើសពីនេះទៅទៀត មិនមានភាពច្បាស់លាស់ឡើយ ថាតើអ្វីទៅដែលជាបទល្មើសដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចដាក់ទណ្ឌកម្មបាន ពីព្រោះមិនទាន់មានក្រមសីលធម៌សំរាប់ចៅក្រមនៅឡើយ។ មានវិធានជាច្រើនស្ថិតនៅជាសេចក្តីព្រាងនៅឡើយ ប៉ុន្តែមិនប្រាកដថាតើពេលណាគេនឹងប្រកាសឱ្យប្រើ ឬថាតើគេនឹងប្រកាសឱ្យប្រើឬអត់។ ជាការជាក់ស្តែង ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមហាក់មានឆន្ទានុសិទ្ធិយ៉ាងសេរី ក្នុងការសំរេចពីអ្វីដែលជាបទល្មើសនោះ។

[២៧] សូមអាន " *ការផ្លាស់ប្តូរអំណាច បានធ្វើឱ្យតុលាការឱ្យស្ថិតក្រោមការត្រួតត្រារបស់រាជរដ្ឋាភិបាល*" ខេមបូឌៀដេលី ថ្ងៃទី ៩ ឧសភា ២០០៥ (ដោយកត់សំគាល់ថា ក្រសួងយុត្តិធម៌នឹងដោះស្រាយពាក្យបណ្តឹងទាំងអស់ ជំនួសឧត្តមក្រុមប្រឹក្សា )។ សូមអានផងដែរនូវរបាយការណ៍ទូទាំងពិភពលោក ឆ្នាំ ២០០៦ របស់អង្គការ Human Rights Watch ក្រោមចំណងជើងថា *ព័ត៌មានសង្ខេបពីប្រទេសកម្ពុជា* ត្រង់ទំព័រទី ២ ( "ក្នុងខែឧសភា ឆ្នាំ ២០០៥ នាយករដ្ឋមន្ត្រីបានពង្រឹងអំណាចរបស់គាត់លើតុលាការ ដោយដាក់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ដែលជាស្ថាប័នវិន័យសំរាប់តុលាការ ហើយត្រូវតែជាស្ថាប័នឯករាជ្យ) ឱ្យស្ថិតនៅក្រោមក្រសួងយុត្តិធម៌ ")។

[២៨] ការស្ទាបស្ទង់មតិមួយទៅលើអង្គភាពអាជីវកម្មនានា បានបង្ហាញថា ៧០ ភាគរយនៃអ្នកឆ្លើយតបជឿជាក់ថា អំពើពុករលួយទាក់ទងនឹងការសំរេចក្តីរបស់តុលាការ កើតមានញឹកញាប់ជាងគេ។ សូមអានរបាយការណ៍របស់វិទ្យាស្ថានសេដ្ឋកិច្ចនៃកម្ពុជា ក្រោមចំណងជើងថា *របាយការណ៍ពីភាពប្រកួតប្រជែងនៅកម្ពុជា ឆ្នាំ ២០០៥-២០០៦* ទំព័រ ២០-២១ និងទំព័រទី ២១ នៃបរិសិដ្ឋ (Apendix page 21)។ ការស្ទាបស្ទង់មតិដដែលនោះ បានរកឃើញថា អ្នកឆ្លើយតបជឿថា ការកែទំរង់វិស័យតុលាការជាមធ្យោបាយល្អបំផុត ដើម្បីធ្វើកែលំអប្រសិទ្ធភាពរបស់រដ្ឋាភិបាល។ ការសិក្សាកាលពីពេលថ្មីៗមួយទៀតរបស់វិទ្យាស្ថានសេដ្ឋកិច្ចនៃកម្ពុជា បានរកឃើញថា អង្គភាពអាជីវកម្មមានទស្សនៈថា តុលាការជាស្ថាប័នសាធារណៈមានលក្ខណៈសុចរិតតិចតួចបំផុត។ សូមអានអត្ថបទ " *ក្រុមហ៊ុនមើលឃើញចៅក្រមថាជាជនពុករលួយបំផុត*" ខេមបូឌៀដេលី ចុះថ្ងៃទី ១៣ កក្កដា ២០០៦ ទំព័រ១។ សូមអានផងដែរ ឯកសាររបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមដែលមានចំណងជើងថា *អំពើពុករលួយ និងគ្រួសារនៅកម្ពុជា* ខែមិនា ២០០៥ ទំព័រ ៤៥-៤៦ (ដែលរាយការណ៍ថាគ្រប់ស្ថាប័នទាំងអស់របស់រដ្ឋាភិបាល ត្រូវសាធារណជនយល់ឃើញថាមិនគួរឱ្យទុកចិត្ត ហើយតុលាការត្រូវបានមើលឃើញមិនសុចរិតសោះ។

២០០៥ ទើបនាយករដ្ឋមន្ត្រីប្រកាសពីយុទ្ធនាការកណ្តាប់ដៃដែក ដើម្បីកែទំរង់តុលាការ។ ជាផ្នែកមួយនៃយុទ្ធនាការកណ្តាប់ដៃដែកនោះ ចៅក្រមមួយចំនួនបានទទួលវិន័យសំរាប់ "ទង្វើខុសឆ្គង" ទោះបីជាក្នុងករណីជាច្រើនដែល គេមិនដែលប្រកាសឱ្យដឹង ថាតើចៅក្រមទាំងនោះរំលោភច្បាប់អី ឬធ្វើខុសនឹងវិធានអីក៏ដោយ។ ចៅក្រមមួយរូប និងព្រះរាជអាជ្ញាមួយរូបត្រូវបានបណ្តេញចេញពីតំណែង រីឯចៅក្រមម្នាក់ទៀតត្រូវបានផ្លាស់ទៅធ្វើការនៅតុលាការខេត្តផ្សេង ចៅក្រមមួយចំនួនត្រូវព្យួរការងារ ហើយចៅក្រមមួយចំនួនទៀតត្រូវផ្លាស់ទៅធ្វើការនៅក្រសួងយុត្តិធម៌។ ក្រោយមកមិនដល់មួយឆ្នាំផង ចៅក្រមដែលជាប់វិន័យទាំងនោះបានចូលកាន់តំណែងវិញយ៉ាងស្ងប់ស្ងៀម[២៩]។ មានតែចៅក្រមម្នាក់ និងព្រះរាជអាជ្ញាម្នាក់ដែលត្រូវបានបណ្តេញចេញប៉ុណ្ណោះ ដែលមិនទាន់បានចូលធ្វើការវិញនៅឡើយ។

បើយើងពិនិត្យឱ្យជិតដល់លើករណីទាំងពីរនេះ យើងឃើញថាមានសក្តានុពលនៃបញ្ហាជាច្រើននៅក្នុងប្រព័ន្ធណាដែលមានលក្ខណៈលាក់កំបាំងដូចជាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ចៅក្រមម្នាក់ឈ្មោះ ហ៊ីង ធីរិទ្ធិ ទំនងជាត្រូវបានទទួលវិន័យ ហើយបានផ្លាស់ពីភ្នំពេញឱ្យទៅធ្វើការនៅខេត្តស្ទឹងត្រែង ព្រោះតែគាត់បានដោះលែងជនជាប់សង្ស័យពីរនាក់ពីបទមនុស្សឃាតគិតទុកជាមុន ដោយសារខ្វះភស្តុតាង ទោះបីមានបញ្ជាពីមន្ត្រីជាន់ខ្ពស់ ឱ្យបញ្ជូនជនសង្ស័យទាំងនោះទៅកាត់ទោសក៏ដោយ[៣០]។ សេចក្តីសំរេចរបស់គាត់ត្រូវបានគេប្តឹងឧទ្ធរណ៍ ហើយជនជាប់សង្ស័យទាំងពីរនាក់នៅជាប់ឃុំដដែល[៣១]។ ថ្វីបើការខ្វះព័ត៌មានសាធារណៈអំពីតុលាការ ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើឱ្យមានការលំបាកក្នុងការវាយតំលៃរឿងក្តីនោះ លោក ហ៊ីង ធីរិទ្ធិ ទំនងជាត្រូវជាប់ទោសវិន័យ ដោយសារតែគាត់មិនឱនលំទោនតាមការគាបសង្កត់ផ្នែកនយោបាយ។

ក្នុងករណីមួយផ្សេងទៀត ពាក់ព័ន្ធនឹងព្រះរាជអាជ្ញាឈ្មោះ យ៉ាំ យ៉េត។ នៅពេលដែលនាយករដ្ឋ-មន្ត្រី ហ៊ុន សែន ប្រកាសពីកណ្តាប់ដៃដែករបស់គាត់ដើម្បីបង្ក្រាបលើប្រព័ន្ធតុលាការ ក្នុងខែមិនា ២០០៥ លោកព្រះរាជអាជ្ញាខេត្តបាត់ដំបង ឈ្មោះ យ៉ាំ យ៉េត ត្រូវបានចាត់តាំងឱ្យកាន់រឿងក្តីពុករលួយនៅក្នុង

---

[២៩] សូមអាន "*យុទ្ធនាការកណ្តាប់ដៃដែករបស់នាយករដ្ឋមន្ត្រី ធ្វើឱ្យចៅក្រម និងព្រះរាជអាជ្ញាបះសក់*" កាសែត ភ្នំពេញប៉ុស្តិ៍ លេខ ១៤/១៤ ថ្ងៃទី ១៥-២៨ កក្កដា ២០០៥ ព្រមទាំង "*កណ្តាប់ដៃដែករបស់ហ៊ុន សែន បានបញ្ចប់ ត្រឹមតែជាការទះដៃ*" កាសែត ភ្នំពេញប៉ុស្តិ៍ លេខ ១៥/១៣ ថ្ងៃ ៣០ មិថុនា -១៣ កក្កដា ២០០៦។

[៣០] សូមអានរបាយការណ៍របស់លោកតំណាងពិសេសរបស់លោកអគ្គលេខាអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ចុះថ្ងៃទី ២០ ធ្នូ ២០០៤។ ឯកសាររបស់អង្គការសហប្រជាជាតិ E/CN.4/2005/116 ទំព័រ ២២-២៣ ។

[៣១] ជនសង្ស័យទាំងពីរនាក់ ក្រោយមកត្រូវបានកាត់ទោសពីបទមនុស្សឃាដ ហើយកាត់ទោសឱ្យជាប់គុក ២០ ឆ្នាំ។ យោងតាមតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា "ស្ថាប័នអយ្យការ មិនបានរកស្តុតាងដើម្បីភ្ជាប់ចុងចោទទៅនឹងឧក្រិដ្ឋកម្មឡើយ ហើយក៏មិនបានពិចារណាលើគោលការណ៍ជាមូលដ្ឋានស្តីពីការជំរះក្តីដោយយុត្តិធម៌ឡើយ ដូចជា គោលការណ៍សន្មតជាមុនថាគ្មានទោស និងភាពមិនលំអៀងរបស់តុលាការ ជាដើម"។ សូមអានសេចក្តីប្រកាសពត៌មានដែលមានចំណងជើងថា "*លោកតំណាងពិសេស អំពាវនាវឱ្យបន្តការស៊ើបអង្កេតលើករណីឃាតកម្មលើប្រធានសហជីព* ***ជា វិជ្ជា*** *ហើយសុំឱ្យមានការដោះលែង លោក* ***ជាម ចន្នី*** *ជាបន្ទាន់*" ចុះថ្ងៃទី ១៦ សីហា ២០០៥ ដែលអាចរកបាននៅក្នុង http://www.ohchr.org/english/press/docs/Leuprecht16august.pdf

តុលាការ។ នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតរបស់គាត់ ព្រះរាជអាជ្ញា យ៉ាំ យ៉េត បានផ្ញើរលិខិតទៅតុលាការក្រុងភ្នំពេញ ស្នើឱ្យដោះលែងជនជាប់សង្ស័យមួយរូប ដែលត្រូវបានឃុំខ្លួនដោយខុសច្បាប់ នៅឯស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ តាមបញ្ជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន។ ប៉ុន្មានខែក្រោយមក លោកយ៉ាំ យ៉េត ត្រូវបានព្យួរការងារដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយចោទប្រកាន់ថា គាត់មិនបានអនុវត្តត្រឹមត្រូវតាមនីតិវិធីក្នុងការផ្ញើលិខិតនោះ [៣២]។ ទណ្ឌកម្មនោះ ហាក់ដូចជាមិនសមាមាត្រទៅនឹងទោសកំហុសដែលបានចោទប្រកាន់នោះសោះ ហើយការណ៍នេះអាចសន្និដ្ឋានថា យ៉ាំ យ៉េត ពិតជាជាប់ទោសវិន័យដោយសារតែគាត់មិនធ្វើតាមបទបញ្ជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន។

ដោយសារតែខ្វះភាពប្រាកដប្រជាអំពីនីតិវិធី សំរាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមប្រតិបត្តិ គួបផ្សំនឹងកង្វះតម្លាភាពជុំវិញរឿងក្តីនីមួយៗដែលខ្លួនធ្វើសវនាការ នាំឱ្យលេចឡើងនូវចម្ងល់ស្តីពីប្រសិទ្ធភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាយន្តការសំរាប់ឆ្លើយតបនឹងអំពើពុករលួយក្នុងវិស័យតុលាការ។ រឿងនេះកាន់តែធ្វើឱ្យមានចម្ងល់ថែមទៀត ជុំវិញការតែងតាំងឱ្យកាន់ការងារឡើងវិញនូវចៅក្រមភាគច្រើនដែលបានជាប់ទោសវិន័យ ក៏ដូចជាបញ្ហាដែលបានលើកឡើងនៅក្នុងករណីរបស់ ហ៊ីង ធីរិទ្ធី និង យ៉ាំ យ៉េត ។ តែទោះជាយ៉ាងណា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នតែមួយដែលមានអំណាចដាក់វិន័យលើចៅក្រម និងព្រះរាជអាជ្ញា។

## គ. នគរបាល

នគរបាលជាតិត្រូវបានគ្រប់គ្រងដោយក្រសួងមហាផ្ទៃ[៣៣] ហើយបទវិន័យសំរាប់នគរបាលត្រូវគ្រប់-គ្រងដោយសេចក្តីសំរេចរបស់ក្រសួងមហាផ្ទៃ (សេចក្តីសំរេចលេខ៦ អំពីបទវិន័យសំរាប់កំលាំងនគរបាលជាតិ ចុះថ្ងៃទី ២៥ វិច្ឆិកា ១៩៩៦)។ នគរបាលត្រូវតែគោរពតាមច្បាប់ ហើយការមិនគោរពច្បាប់ នឹងត្រូវទទួលទណ្ឌកម្ម (មាត្រា ១.៨)។ ទំងន់នៃទណ្ឌកម្ម និងនីតិវិធីត្រូវកំណត់ដោយស្ថានភាពទំងន់នៃទោសកំហុស។ ខុសពីនីតិវិធីរដ្ឋបាលផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា វិធានសំរាប់គ្រប់គ្រងនគរបាល មានចែងលំអិតនូវចំនុចខ្លះស្តីពីទោសកំហុសប្រភេទណា ដែលនាំឱ្យមានទណ្ឌកម្មត្រឹមណា។ យោងតាមមាត្រា ៨.គ.១ នៃសេចក្តីសំរេចអំពីបទវិន័យសំរាប់កំលាំងនគរបាលជាតិ ទោសកំហុសដែលស្រាលបំផុត ដូចជាការមកធ្វើការយឺតអវត្តមានដោយមិនមានច្បាប់អនុញ្ញាត ការស្លៀកពាក់ឯកសណ្ឋានមិនបានត្រឹមត្រូវ នឹងត្រូវទទួលការព្រមាន

---

[៣២] សូមអានអត្ថបទរបស់ Lee Bertiaume និង ប្រាក់ ចាន់ថុល " *កំណែទំរង់ប្រព័ន្ធតុលាការរបស់កណ្តាប់ដៃដែក កេងយកចំណេញសំរាប់ខ្លួនឯង* " ឌឹខេមបូឌៀដេលី ថ្ងៃ១៩ សីហា ២០០៥ ទំព័រ ១។

[៣៣] សូមមើលច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ មាត្រា ២។

ឬស្តីបន្ទោស។ ការព្រមាន ឬស្តីបន្ទោសត្រូវធ្វើឡើងដោយអ្នកគ្រប់គ្រងផ្ទាល់របស់អ្នកប្រព្រឹត្តខុស (សូមមើល មាត្រា ៨.ក)។

ទោសកំហុសកាន់តែធ្ងន់ នាំឱ្យមានទណ្ឌកម្មកាន់តែធ្ងន់ ព្រមទាំងឱ្យមាននីតិវិធីកាន់តែច្រើនដែរ។ អំពើទាំងឡាយខាងក្រោម អាចនាំទៅដល់ការទម្លាក់ឋានន្តរស័ក្តិ ការផ្លាស់ប្តូរកន្លែងធ្វើការ និងការបណ្តេញចោលៈ

១. ការប្រព្រឹត្តទោសកំហុសស្រាលៗ ដោយមន្ត្រីដែលធ្លាប់ទទួលការព្រមាន ឬស្តីបន្ទោស ពីរ ឬច្រើន ដងមកហើយ។
២. ការទទួលការសូកប៉ាន់ច្រើនជាង ៥០០០ រៀល
៣. ការកេងបំបាត់ទ្រព្យសម្បត្តិរដ្ឋដែលមានតំលៃលើសពី ១០០.០០០រៀល
៤. ការប្រើប្រាស់មុខតំណែង តួនាទី និងអំនាច ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន
៥. ការក្លែងបន្លំឯកសារសាធារណៈ ឬកែកាឡែភស្តុតាង និង
៦. ការជាកពិន័យដោយមិនចេញវិក្កយបត្រត្រឹមត្រូវ។

សូមមើល មាត្រា ៨.គ.២ [៣៤] ។ មុននឹងមន្ត្រីណាម្នាក់ត្រូវបានទំលាក់ឋានន្តរស័ក្តិ ផ្លាស់ចេញពីកន្លែង ឬបណ្តេញចេញ រូបគេត្រូវឆ្លងកាត់នីតិវិធីរបស់ក្រុមប្រឹក្សាវិន័យ ដូចមានចែងនៅក្នុងច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល។ នៅក្នុងវិធានទាំងនោះ មន្ត្រីនោះទទួលបាននូវការការពារយ៉ាងមាំ ដែលក្នុងនោះរួមមានសវនាការចំពោះមុខក្រុមប្រឹក្សាវិន័យ និងសិទ្ធិមានតំណាង (សូមមើល ផ្នែល ៤(ក) សំរាប់ព័ត៌មានលំអិត។

នៅទីបញ្ចប់ មានទោសកំហុសជាច្រើន ដែលនាំឱ្យមានការបញ្ជូនខ្លួនមន្ត្រីនោះដោយផ្ទាល់ ទៅកាន់តុលាការតែម្តង ដើម្បីចោទប្រកាន់ពីបទព្រហ្មទណ្ឌ ដែលក្នុងនោះរួមមានៈ

១. ត្រូវចាប់ខ្លួនបានក្នុងពេលកំពុងប្រព្រឹត្តបទល្មើសជាក់ស្តែង
២. ការលក់អាវុធ ឬគ្រាប់រំសេវ
៣. ការធ្វើទារុណកម្មលើមនុស្សដែលជាប់ឃុំនៅទីខុំឃាំងរបស់នគរបាល រហូតបណ្តាលឱ្យស្លាប់
៤. អំពើក្បត់ជាតិ។

សូមមើលមាត្រា ៨.គ.៣ ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុតនៅក្នុងបទវិន័យនេះ គឺវាខ្វះពេក។ អំពើពុករលួយ និងការកេងបំបាត់មិនត្រូវបានបញ្ចូលទាល់តែសោះនៅក្នុងបទវិន័យនោះ។ ការណ៍នេះបង្ហាញថាជាទូទៅ ស្ថាប័ននគរបាលនឹងមិនបញ្ជូនភ្នាក់ងារនគរបាលទៅតុលាការដើម្បីជំរះ ពីបទប្រព្រឹត្តិអំពើពុករលួយ ឬកេងបំបាត់ឡើយ។ តាមមើល ការចោទប្រកាន់បែបនោះ ប្រហែលជាអាចដោះស្រាយជាលក្ខណៈផ្ទៃក្នុង

[៣៤] មានទោសកំហុសដែលមានរាយឈ្មោះ ចំនួន ២០ ដែលអាចនាំទៅដល់ការទម្លាក់ឋានន្តរស័ក្តិ ការផ្លាស់ចេញពីកន្លែងធ្វើការ និងការណ្តេញចោល។ ទោសកំហុសដែលលើកឡើងខាងលើ ទំនងជាទាក់ទងនឹងអំពើពុករលួយច្រើន។

របស់នគរបាលតែប៉ុណ្ណោះ ដោយអាចប្រើ ឬមិនប្រើដំណើរការនីតិវិធីរដ្ឋបាលដូចរៀបរាប់ខាងលើ [៣៥]។ ការណ៍នេះគឺផ្ទុយស្រឡះពីច្បាប់អ៊ុនតាក់ ដែលដាក់ការស៊ីសំណូក និងការគៃបំបាត់ជាបទល្មើសព្រហ្មទណ្ឌ ដោយមិនគិតពីចំនួនទឹកប្រាក់ឡើយ។ ថ្មីៗនេះ ក្រសួងមហាផ្ទៃបានថ្លែងថា ខ្លួននឹងស៊ើបអង្កេតរាល់ការចោទប្រកាន់ពីអំពើពុករលួយនៅក្នុងកងកម្លាំងនគរបាល[៣៦]។

ប្រសិនបើមន្ត្រីនគរបាលម្នាក់ត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅក្រសួងមហាផ្ទៃក្នុងអំឡុងពេល ៧២ ម៉ោង (សូមអានព្រះរាជក្រិត្យ ស្តីពីលក្ខន្តិកៈដោយឡែកសំរាប់នគរបាលជាតិ ព្រះរាជក្រិត្យលេខ ០៥០១/១៧៨ ចុះថ្ងៃទី ២២ ឧសភា ២០០១ មាត្រា ៤៥ [៣៧]។ ចំណុចនេះប្រហាក់ប្រហែលទៅនឹងមាត្រា ៥១ នៃច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល (សូមមើល ផ្នែកទី ៤ (ក))។ មន្ត្រីណាម្នាក់ដែលត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌ "អាច"ត្រូវព្យួរការងារ។ មន្ត្រីណាម្នាក់ដែលត្រូវបានកាត់ឱ្យមានទោស តែបានប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសំរេចរបស់តុលាការជាន់ទាប ត្រូវតែព្យួរការងារ ក្នុងអំឡុងពេលជាប់បណ្តឹងឧទ្ធរណ៍។ មន្ត្រីណាម្នាក់ដែលផុតបណ្តឹងឧទ្ធរណ៍អស់ហើយ ហើយត្រូវបានកាត់ឱ្យជាប់ពន្ធនាគារ ត្រូវបណ្តេញចេញពីការងារ (សូមមើលព្រះរាជក្រិត្យស្តីពីលក្ខន្តិកៈដោយឡែករបស់នគរបាលជាតិ មាត្រា ៤៦-៤៧)។

អ្នកនិពន្ធមិនអាចរកបានឡើយ នូវស្ថិតិដែលបង្ហាញពីចំនួនមន្ត្រីនគរបាលដែលទទួលទណ្ឌកម្មខាងវិន័យ នៅក្រោមសេចក្តីសំរេចស្តីពីបទវិន័យនេះ ។ អ្នកនិពន្ធក៏មិនអាចរកបានដែរនូវព័ត៌មានស្តីពីចំនួនមន្ត្រីនគរបាលដែលត្រូវបានចោទប្រកាន់ជាផ្លូវការ ពីបទព្រហ្មទណ្ឌ។ ព័ត៌មានបែបនេះហាក់ដូចជាមិនត្រូវ

---

[៣៥] តាមពិត ក្នុងឧប្បត្តិហេតុជាច្រើននៅក្នុងឆ្នាំ២០០៥ និង២០០៦ មន្ត្រីនគរបាលដែលនៅក្រៅម៉ោងធ្វើការ បានបាញ់លើជនស៊ីវិល ហើយភាគក្នុងករណីភាគច្រើន មន្ត្រីនគរបាលទាំងនោះមិនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋឡើយ។ ជាឧទាហរណ៍ ក្នុងពេលថ្មីៗនេះ មន្ត្រីនគរបាលម្នាក់បានដេញតាមសិស្សសាលាម្នាក់ដែលជិះម៉ូតូប៉ះរថយន្តរបស់ខ្លួន ហើយបានបាញ់សិស្សនោះចំខ្នងចំនួនបីគ្រាប់។ មន្ត្រីនគរបាលនោះត្រូវបានដោះលែងដោយគ្មានការចោទប្រកាន់ បន្ទាប់ពីបានបង់ប្រាក់ចំនួន ៥២០០ ដុល្លារ ទៅឱ្យជនរងគ្រោះ ។ សូមអាន " *នគរបាលបង់លុយឱ្យកូនសិស្ស បន្ទាប់ពីបាញ់កូនសិស្សត្រូវចំនួនបីគ្រាប់* " ខេមបូឌៀដេលី ថ្ងៃ ២៤ កក្កដា ២០០៦ ទំព័រទី ១៥។ សូមអានផងដែរនូវអត្ថបទ " *ការបង់លុយ ធ្វើឱ្យមន្ត្រីនគរបាលរួចខ្លួនពីបទមនុស្សឃាដ* " ឌីខេមបូឌៀដេលី ថ្ងៃ ២១-២១ តុលា ២០០៦ទំព័រទី៣ (ដែលរៀបរាប់ពីមន្ត្រីនគរបាលម្នាក់បានដកកាំភ្លើងខ្លីរបស់ខ្លួន ហើយបាញ់សំលាប់បុរសម្នាក់ ប៉ុន្តែមិនត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទេ ហើយអនុញ្ញាតឱ្យត្រលប់ទៅធ្វើការវិញ បន្ទាប់ពីបង់ប្រាក់ ៣០០០ដុល្លារ ទៅឱ្យគ្រួសារជនរងគ្រោះ)។ អធិការនគរបាលខណ្ឌដូនពេញបានថ្លែងថា " គ្រួសារជនល្មើស និងជនរងគ្រោះបានព្រមព្រៀងគ្នា ដូចនេះហើយទើបគេព្រមទទួលយកសំណងដើម្បីបញ្ចប់រឿង ដោយហេតុថា វានឹងខាតពេលវេលា បើសិនជាគេដាក់ពាក្យបណ្តឹងទៅតុលាការ "។ និទណ្ឌភាពជាពិសេសសំរាប់បទល្មើសមិនធ្ងន់ធ្ងរ ហាក់ដូចជានិយាមនៅក្នុងនាយកដ្ឋាននគរបាល។ ម្យ៉ាងវិញទៀត ក្នុងករណីថ្មីៗនេះ មន្ត្រីនគរបាលក្រុងភ្នំពេញ ៦ នាក់ ត្រូវបានគេរកឃើញថា មានទោសពីបទមនុស្សឃាដ បន្ទាប់ពីធ្វើទារុណកម្ម និងសំលាប់នារីម្នាក់ក្នុងមន្ទីរឃុំឃាំង។ សូមអាន " *នគរបាល៦ នាក់ ត្រូវបានកាត់ឱ្យជាប់ទោសពីបទធ្វើទារុណកម្ម និងសំលាប់មនុស្ស* " ខេមបូឌៀដេលី ថ្ងៃ ២២-២៣ កក្កដា ២០០៦ ទំព័រទី៣។

[៣៦] សូមអាន " របាយការណ៍ : *ក្រុមហ៊ុនឯកជនមើលឃើញថា ចៅក្រមជាអ្នកពុករលួយបំផុត* " ឌីខេមបូឌៀដេលី ថ្ងៃទី ១៣ កក្កដា ២០០៦ ទំព័រ ១៤ ។

[៣៧] ព្រះរាជក្រិត្យនេះបំពេញបន្ថែមទៅលើសេចក្តីសំរេចស្តីពីបទវិន័យរបស់កងកម្លាំងនគរបាលជាតិ ចុះខែវិច្ឆិកា ១៩៩៦។

បានគេផ្សព្វផ្សាយឱ្យដឹងជាសាធារណៈឡើយ។ ជាសរុបមក ការចោទប្រកាន់ជាផ្លូវការពីបទព្រហ្មទណ្ឌ ក៏ដូចជាដំណើរការនីតិវិធីខាងវិន័យ ហាក់ដូចជាមិនត្រូវបានគេធ្វើឡើងញឹកញាប់ឡើយ[៣៨]។

### ឃ. យោធិន

កងយោធពលខេមរភូមិន្ទ ត្រូវបានរៀបចំ និងគ្រប់គ្រងដោយច្បាប់ស្តីពី លក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ (១៩៩៧) (ដែលបន្ទាប់ទៅនេះហៅថា ច្បាប់ស្តីពីយោធិន)។ កងយោធពលខេមរភូមិន្ទ ត្រូវបានហាមឃាត់មិនឱ្យប្រើតំណែង ឥទ្ធិពល ឬអំណាច ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ឬទៅបំភិតបំភ័យ គំរាមកំហែង ឬរំលោភសិទ្ធិរបស់ប្រជាពលរដ្ឋឡើយ (មាត្រា ២៥)។ ការហាមឃាត់នេះភាគច្រើនគឺហាមឃាត់លើសកម្មភាពទាក់ទងនឹងអំពើពុករលួយ ឬការកេងបំបាត់។ ទណ្ឌកម្មខាងរដ្ឋបាលនៅក្រោមច្បាប់ស្តីពីយោធិន គឺដើម្បីបញ្ជាក់បន្ថែមទៅលើទណ្ឌកម្មនៅក្រោមច្បាប់ព្រហ្មទណ្ឌទូទៅ ប៉ុន្តែមិនមែនជាការជំនួសឱ្យនោះទេ (មាត្រា ៤៥) សូមមើល ផងដែរនូវប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាវិន័យ ចុះថ្ងៃទី ១៣ ខែ កញ្ញា ១៩៩៩ (ដែលបន្ទាប់ទៅនេះហៅថាប្រកាសស្តីពីការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាវិន័យ)។

ច្បាប់ស្តីពីយោធិន ដាក់ឱ្យមានទណ្ឌកម្មខាងរដ្ឋបាល ទៅលើយោធិនទាំងឡាយណាដែលប្រព្រឹត្តកំហុស (សូមមើលច្បាប់ស្តីពីយោធិន មាត្រា ៤៥)។ ប៉ុន្តែគួរឱ្យសោកស្តាយ ដោយសារច្បាប់នេះមិនបាននិយាយទាល់តែសោះ អំពីវិធីនៃដំណើរការនីតិវិធីខាងរដ្ឋបាលនេះ។ ច្បាប់នេះមិនបានបង្ហាញថាតើសាធារណជនអាចប្តឹងតវ៉ា អំពីយោធិនដែរឬទេ ហើយក៏មិនបានបង្ហាញថាតើអង្គភាពណាមួយនៅក្នុងកងខេមរភូមិន្ទជាអ្នកទទួលពាក្យបណ្តឹង។ ដូចនេះ មើលទៅទំនងជាបណ្តឹងនឹងត្រូវធ្វើឡើងដោយមេបញ្ជាការរបស់យោធិននោះ ហើយបញ្ជូនឡើងតាមលំដាប់ថានានុក្រម។ ការណ៍នេះបង្ហាញថា បណ្តឹងគប្បីត្រូវធ្វើទៅមន្ត្រីជាមេបញ្ជាការរបស់យោធិននោះ។

មុននឹងមានយោធិនណាម្នាក់ត្រូវបានដាក់ទណ្ឌកម្មក្រោមច្បាប់ស្តីពីយោធិន ត្រូវមានការប្រជុំក្រុមប្រឹក្សាវិន័យសិន (មាត្រា ៤៦)។ ក្រុមប្រឹក្សាវិន័យមានសមាសភាព ៧ នាក់ ក្នុងនោះ ៣ នាក់តែងតាំងដោយក្រសួងការពារជាតិ និង៤នាក់ទៀតជាមន្ត្រីមកពីអង្គភាពរបស់យោធិនជាប់បណ្តឹង (ដែលត្រូវតែមានឋានន្តរសក្តិខ្ពស់ជាងយោធិនជាប់បណ្តឹង)។ មន្ត្រី ៣ នាក់ដែលតែងតាំងដោយក្រសួងការពារជាតិ មានឋានៈជាប្រធាន អនុប្រធាន និងអ្នករាយការណ៍ (សូមមើលប្រកាសស្តីពីការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាវិន័យ មាត្រា ៣)។ អ្នករាយការណ៍ការមានភារកិច្ចស៊ើបអង្កេតរឿង ព្រមទាំងរៀបចំរបាយការណ៍លាយល័ក្ខអក្សរ ស្តីពីលទ្ធផលនៃការស៊ើបអង្កេតផងដែរ (មាត្រា ៥)។ បន្ទាប់មកទើបក្រុមប្រឹក្សាវិន័យជួបប្រជុំ ដោយមានវត្តមានរបស់យោធិនជាប់បណ្តឹងផងដែរ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍នោះ (មាត្រា ៧)។ បន្ទាប់មកទៀត

---

[៣៨] សូមមើលកំណត់ចំណាំ លេខ ៣៤។

ទើបក្រុមប្រឹក្សាបោះឆ្នោតជាសំងាត់ ដើម្បីស្នើឡើងនូវទណ្ឌកម្ម (មាត្រា ៨)។ ទណ្ឌកម្មដែលត្រូវដាក់រួមជាមួយនឹងកំណត់ហេតុសវនាការ ត្រូវបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងការពារជាតិ (ឬអាជ្ញាធរ មានសមត្ថកិច្ចណាមួយ) ដើម្បីធ្វើការសំរេចជាចុងក្រោយ អំពីទណ្ឌកម្មនោះ (មាត្រា ៩)។យោងតាមច្បាប់ស្តីពីយោធិនត្រង់មាត្រា ៤៧ រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចបដិសេធមិនធ្វើតាមអនុសាសន៍របស់ក្រុមប្រឹក្សាវិន័យ ហើយអាចដាក់ទណ្ឌកម្មស្រាលជាង។ ទណ្ឌកម្មរួម មានៈ ១)ការព្យួរការងារជាបណ្តោះអាសន្ន ២)ការលុបឈ្មោះចេញពីតារាងតម្លើងឋានន្តរស័ក្តិ ៣)ការដកហូតមុខតំណែង ដោយដាក់នៅក្នុងស្ថានភាពទំនេរ ៤)ការលុបឈ្មោះចេញពីក្របខណ្ឌ (មាត្រា ៤៨)។

អ្នកនិពន្ធមិនអាចស្វែងរកបានឡើយ នូវស្ថិតិស្តីពីចំនួនយោធិនដែលទទួលទណ្ឌខាងវិន័យជាផ្លូវការ ហើយអ្នកនិពន្ធក៏មិនអាចរកព័ត៌មាន ថាតើធ្លាប់មានយោធិនប៉ុន្មាននាក់ត្រូវបានចោទប្រកាន់ជាផ្លូវការពីបទព្រហ្មទណ្ឌ។ ព័ត៌មានបែបនេះហាក់ដូចជាមិនមានការផ្សព្វផ្សាយជាសាធារណៈសោះ។

## ខ. មន្ត្រីថ្នាក់ខេត្ត ស្រុក និងឃុំ

រដ្ឋបាលថ្នាក់ខេត្ត និងស្រុក ស្ថិតនៅក្រោមការណែនាំ និងត្រួតពិនិត្យដោយក្រសួងមហាផ្ទៃ (សូមមើលច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ មាត្រា ២)។ ដោយសារគោលនយោបាយវិមជ្ឈការ ថ្នាក់ឃុំមានឯករាជ្យភាពច្រើនពីរដ្ឋាភិបាលកណ្តាល ប៉ុន្តែនៅតែរាយការណ៍ទៅក្រសួងមហាផ្ទៃអំពីបញ្ហាសំខាន់ៗ។ យន្តការដែលអាចប្រើដើម្បីដោះស្រាយអំពើពុករលួយនៅថ្នាក់ខេត្ត និងស្រុក នឹងត្រូវលើកមកពិភាក្សាមុនគេ។

### 2. ថ្នាក់ខេត្ត

រដ្ឋាភិបាលថ្នាក់ខេត្ត គឺជាតំណាងរបស់រាជរដ្ឋាភិបាល ហើយស្ថិតនៅក្រោមយុត្តាធិការផ្ទាល់របស់ក្រសួងមហាផ្ទៃ (សូមមើល ប្រកាសស្តីពីតួនាទី ការទទួលខុសត្រូវ និងអង្គការលេខរបស់រដ្ឋបាល ខេត្ត-ក្រុង ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ១៩៩៤ មាត្រា ១)។ រដ្ឋាភិបាលថ្នាក់ខេត្ត មានតួនាទីរួមមួយដើម្បីអនុវត្តច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងផ្តល់របាយការណ៍ការងាររបស់ខ្លួនដល់ក្រសួងមហាផ្ទៃ (មាត្រា ២)។ រដ្ឋាភិបាលថ្នាក់ខេត្តនីមួយៗ ដឹកនាំដោយអភិបាលខេត្តម្នាក់ និងអភិបាលរងខេត្តមួយចំនួន (មាត្រា៣)។ រដ្ឋបាលថ្នាក់ខេត្តនីមួយៗមានអង្គភាពមួយចំនួនដូចជា ខុទ្ទកាល័យ អគ្គលេខាធិការដ្ឋាន មន្ទីរហិរញ្ញវត្ថុ និងមន្ទីរអធិការកិច្ច (មាត្រា ៤)។ ថ្វីបើគ្មានអង្គភាពណាមួយ មានភារកិច្ចជាក់លាក់ក្នុងការដោះស្រាយអំពើ-ពុករលួយ មន្ទីរអធិការកិច្ចនៅក្នុងខេត្តនីមួយៗ មានតួនាទីតាមដាន និងត្រួតពិនិត្យសកម្មភាពរបស់មន្ត្រីថ្នាក់ខេត្ត និងស្រុក (មាត្រា ៤.០៤)។ លើសពីនេះ នគរបាលខេត្តត្រូវរាយការណ៍ទៅអភិបាលខេត្ត ហើយរដ្ឋាភិបាលថ្នាក់ខេត្តមានអំណាចក្នុងការបញ្ជានគរបាល ឱ្យស៊ើបអង្កេត "បទព្រហ្មទណ្ឌ និងបទល្មើសនានា" (មាត្រា ២.៦)។ ដោយរួមបញ្ចូលគ្នា រចនាសម្ព័ន្ធថ្នាក់ខេត្ត និងអំណាចរបស់អភិបាលខេត្ត បង្កើតបានជាប្រព័ន្ធមួយដែលអាចយកទៅប្រើ ដើម្បីស៊ើបអង្កេតអំពើពុករលួយ និងផ្តន្ទាទោសអ្នកប្រព្រឹត្ត នៅថ្នាក់ខេត្តបាន។ ក៏ប៉ុន្តែ បទសំភាសន៍បានបង្ហាញថា អភិបាលខេត្តមិនបានប្រើអំណាចរបស់ខ្លួនដើម្បីស៊ើបអង្កេត តាមប្រព័ន្ធមួយ សំរាប់ដោះស្រាយអំពើពុករលួយឡើយ។

### 3. ថ្នាក់ស្រុក និងការិយាល័យអំប៊ុដស៍មេន

រដ្ឋបាលថ្នាក់ស្រុក មានលក្ខណៈដូចគានឹងរដ្ឋបាលថ្នាក់ខេត្ត ប៉ុន្តែមានរចនាសម្ពន្ធ័មិនស្មុគស្មាញដូចថ្នាក់ខេត្តឡើយ។ អង្គការលេខនៅថ្នាក់ស្រុកត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ (មាត្រា ៨)។ យោងតាមប្រកាសនោះ ស្រុកនីមួយៗត្រូវមានសាលាស្រុកមួយដែលមាន ការិយាល័យចំនួន ៣ គឺការិយាល័យរដ្ឋបាល ការិយាល័យសង្គមកិច្ច និងការិយាល័យសេដ្ឋកិច្ច (សូមមើលប្រកាសស្តីពីតួនាទី មុខងារ ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធសាលាស្រុក-ខណ្ឌ ចុះថ្ងៃទី ១៦ មីនា ២០០០ មាត្រា ១១-១២-១៩)។ គ្មានការិយាល័យណាមួយ មានតួនាទីឱ្យជាក់លាក់ក្នុងការទទួល និងស៊ើបអង្កេតបណ្តឹងស្តីពីអំពើពុករលួយឡើយ។ តែទោះជាយ៉ាងណា អភិបាលស្រុកមានតួនាទីផ្សព្វផ្សាយ ត្រួតពិនិត្យ និងអនុវត្តច្បាប់ ហើយរាយការណ៍ពីកាងារទាំងនេះជូនទៅអភិបាលខេត្ត (សូមមើលប្រកាសស្តីពីមុខងារ ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធនៃរដ្ឋបាល ខេត្ត-ក្រុង ចុះថ្ងៃទី ១៥ កុម្ភៈ១៩៩៤ មាត្រា ៧)។ អភិបាលស្រុកក៏ដើរតួនាទីជាមន្ត្រីរដ្ឋបាល និងជាមន្ត្រីនគរបាលយុត្តិធម៌នៅមូលដ្ឋានដែរ ដែលការណ៍នេះអាចនិយាយបានថា គាត់មានអំណាចក្នុងការស៊ើបអង្កេតអំពើពុករលួយ។

មានស្រុកពីរ គឺស្រុកសៀមរាបនៃខេត្តសៀមរាប និងស្រុកបាត់ដំបងនៃខេត្តបាត់ដំបង ត្រូវបានជ្រើសរើសសំរាប់គំរោងសាកល្បងរចនាសម្ព័ន្ធរដ្ឋបាលថ្មីៗមួយចំនួន ដែលមានគោលដៅធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាព និងអភិបាលកិច្ចល្អ។ រចនាសម្ព័ន្ធថ្មីមួយ គឺ "ការិយាល័យប្រជាពលរដ្ឋ" ឬ ហៅថាការិយាល័យអំប៊ុដស៍មេន ដែលបានបង្កើតឡើងនៅក្នុងរដ្ឋបាលថ្នាក់ស្រុក (សូមមើលសេចក្តីសំរេចស្តីពីរចនាសម្ព័ន្ធ និងរដ្ឋបាលនៅស្រុកបាត់ដំបង និងស្រុកសៀមរាប ចុះថ្ងៃទី ១១ មិថុនា ២០០៣ មាត្រា ១២ )។ ការិយាល័យប្រជាពលរដ្ឋនេះ នេះមានភារកិច្ចផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ និងទទួលពាក្យបណ្តឹងអំពី "ភាពមិនប្រក្រតី និងកង្វះខាត" របស់មន្ត្រីស្រុក។ នៅក្នុងប្រកាសមួយដែលចែងអំពីប្រតិបត្តិការនៃការិយាល័យនេះ ក្រសួងមហាផ្ទៃបានបញ្ជាក់ច្បាស់ថា ការិយាល័យនេះមានកាតព្វកិច្ចទទួល និងស៊ើបអង្កេតពាក្យបណ្តឹងអំពីអំពើពុករលួយ និងការជំរិតយកប្រាក់ (សូមមើលប្រកាសស្តីពីរចនាសម្ព័ន្ធ និងការគ្រប់គ្រងការិយាល័យអំប៊ុដស៍មេន នៅស្រុកសៀមរាប និងស្រុកបាត់ដំបង មាត្រា ៣)។ ដើម្បីជួយដល់ការស៊ើបអង្កេត "តំណាងប្រជាពលរដ្ឋ" (ប្រធានការិយាល័យអំប៊ុដស៍មេន) មានអំណាចក្នុងការសាកសួរមន្ត្រីស្រុក និងទទួលឯកសារពីការិយាល័យនានានៅថ្នាក់ស្រុក (មាត្រា ១៤)។ ប្រសិនបើតំណាងប្រជាពលរដ្ឋមិនអាចដោះ-ស្រាយពាក្យបណ្តឹងបាន ឬមន្ត្រីស្រុកមិនសហការក្នុងការស៊ើបអង្កេត តំណាងប្រជាពលរដ្ឋអាចបញ្ជូនរបាយការណ៍នៃបណ្តឹង និងការស៊ើបអង្កេត ទៅអភិបាលស្រុកដើម្បីដោះស្រាយ (មាត្រា ៣ ,១៥)។ លើសពីនេះ កំណត់ហេតុពីការស៊ើបអង្កេត ត្រូវបើកទូលាយដល់ប្រជាពលរដ្ឋ ហើយបុគ្គលដែលដាក់ពាក្យ-បណ្តឹង មានសិទ្ធិទទួលបាននូវរបាយការណ៍ស្តីពីលទ្ធផលនៃការស៊ើបអង្កេត (មាត្រា ៣, ១៦)។

ក៏ប៉ុន្តែ ក៏ការិយាល័យអំប៊ុដស៍មេនទាន់បានទទួលពាក្យបណ្តឹងណាមួយដែលអាច ចោទប្រកាន់បាននៅឡើយទេ។ ការិយាល័យនៅស្រុកសៀមរាប និងបាត់ដំបងបានដំណើរអស់រយៈពេលប្រហែលជាមួយឆ្នាំ

ហើយ ប៉ុន្តែទទួលបានពាក្យបណ្តឹងសរុបតែ ១០ ប៉ុណ្ណោះ។ បណ្តឹងនីមួយៗសុទ្ធតែមានការសំរេច ឬ ចំណាត់ការពីថ្នាក់ខេត្ត។ មិនមានពាក្យបណ្តឹងណាមួយស្ថិតក្រោមយុត្តាធិការរបស់តំណាងប្រជាពលរដ្ឋឡើយ ហើយក៏គ្មានបណ្តឹងណាមួយទាក់ទងនឹងអំពើពុករលួយនៅរដ្ឋបាលថ្នាក់ស្រុកដែរ។ ជាលទ្ធផល មិនមានការស៊ើបអង្កេត ឬការដោះស្រាយជម្លោះណាមួយត្រូវបានធ្វើឡើងដោយតំណាងប្រជាពលរដ្ឋឡើយ។ ការដែលចំនួនពាក្យបណ្តឹងមានតិចយ៉ាងនេះ មួយចំណែកអាចបណ្តាលមកពី ពាក្យបណ្តឹងត្រូវតែធ្វើឡើងជាលាយល័ក្ខអក្សរ ហើយប្រជាពលរដ្ឋត្រូវតែផ្តល់ឈ្មោះ និងព័ត៌មានសំរាប់ទាក់ទង។ ការិយាល័យអំប៊ុដស៍មេនតាមពិតត្រូវរក្សាទុកព័ត៌មានទំនាក់ទំនងនេះជាការសំងាត់ ប៉ុន្តែការដែលតម្រូវឱ្យអ្នកប្តឹងបង្ហាញអត្តសញ្ញាណរបស់ខ្លួន អាចធ្វើអ្នកទាំងនោះមិនហ៊ានរាយការណ៍ពីអំពើពុករលួយ។ ចំនួនពាក្យបណ្តឹងដែលមិនអាចចាត់ការបានបង្ហាញថា មានសេចក្តីត្រូវការឱ្យមានការិយាល័យអំប៊ុដស៍មេននៅថ្នាក់ខេត្ត [៣៩]។

### 4. ថ្នាក់ឃុំ និងក្រុមការងារគណនេយ្យភាព

ឃុំ-សង្កាត់ ប្រតិបត្តការងារក្នុងប្រព័ន្ធមួយដែលខុសស្រឡះពីថ្នាក់ខេត្ត និងថ្នាក់ស្រុក។ ចាប់តាំងពីឆ្នាំ ២០០១ មក ឃុំ-សង្កាត់បានទទួលនូវឯករាជ្យភាពយ៉ាងច្រើន ដែលនេះជាផ្នែកមួយនៃគោលនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល (សូមមើលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ មាត្រា ១)។ មន្ត្រីថ្នាក់ឃុំ-សង្កាត់មិនត្រូវបានតែងតាំងដោយរដ្ឋាភិបាលឡើយ ផ្ទុយទៅវិញ គឺត្រូវបានបោះឆ្នោតដោយផ្ទាល់ដោយប្រជាពលរដ្ឋក្នុង ដែលបន្ទាប់មករួមគ្នាបង្កើតជាក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលដើរតួនាទីជារដ្ឋាភិបាលមូលដ្ឋាន (មាត្រា ៤, ៩, ១០)។ តាមការពិត ក្រុមប្រឹក្សាឃុំ-សង្កាត់នៅតែត្រូវប្រតិបត្តិនៅក្រោមគោលការណ៍ណែនាំដែលបង្កើតឡើងដោយក្រសួងមហាផ្ទៃ ឬក៏វាអាចត្រូវរំលាយ (សូមមើលមាត្រា ៥៣-៥៩)។

ប្រជាពលរដ្ឋតាមឃុំ-សង្កាត់នីមួយៗ មានសិទ្ធិប្តឹងតវ៉ាស្ទើរតែគ្រប់បញ្ហាទាំងអស់ទៅក្រុមប្រឹក្សាឃុំ រីឯក្រុមប្រឹក្សាវិញ មានកាតព្វកិច្ចឆ្លើយតបទៅនឹងបណ្តឹងទាំងនោះ (សូមមើលអនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់ ចុះថ្ងៃទី ២៥ មីនា ២០០២ (មាត្រា ៣១)។ ទន្ទឹមនឹងនេះ ក៏មានអង្គភាពដែលមានអាណត្តិច្បាស់លាស់ដើម្បីទទួល និងស៊ើបអង្កេតពាក្យបណ្តឹងអំពីការប្រើប្រាស់មិនត្រឹមត្រូវ នូវថវិកាឃុំ-សង្កាត់។ អង្គភាពនោះ គឺ "ក្រុមការងារគណនេយ្យភាពថវិកាឃុំ-សង្កាត់ ថ្នាក់ខេត្ត-ក្រុង" (សូមមើលសេចក្តីសំរេចស្តីពីការបង្កើតក្រុមការងារគណនេយ្យភាពថវិកាឃុំ-សង្កាត់ ខេត្ត-ក្រុង)។ ក្រុមការងាគណនេយ្យភាពនេះ ត្រូវគេបង្កើតឡើងនៅថ្នាក់ខេត្ត ហើយរួមមានសមាជិកមកពីសាលាខេត្ត ក្រុមប្រឹក្សាឃុំ និងអង្គការសង្គមស៊ីវិល (មាត្រា២)។ ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត-ក្រុង មានតួនាទីប្រមូល ពិនិត្យ និងស៊ើបអង្កេតពាក្យបណ្តឹង ស្តីពីការប្រើប្រាស់ថវិកាឃុំ-សង្កាត់មិនត្រឹមត្រូវ (មាត្រា ៤)។ លើសពីលើនេះ ក្រុមការងារគណនេយ្យភាពថ្នាក់ខេត្ត-ក្រុង មានភារកិច្ចដាក់ចេញ និងអនុវត្ត

---

[៣៩] រដ្ឋាភិបាលកំពុងពិចារណាលើផែនការពង្រីករចនាសម្ព័ន្ធរដ្ឋបាលថ្មីនេះ ទៅកន្លែងដទៃទៀតចំនួនបួន គឺ ភ្នំពេញ កំពង់ចាម ប៉ោយប៉ែត និងក្រុងព្រះសីហនុ ក្នុងឆ្នាំ ២០០៧ ប៉ុន្តែហាក់ដូចជាមិនមានផែនការណាមួយដើម្បីចម្លងយករចនាសម្ព័ន្ធរដ្ឋបាលថ្មីនេះសំរាប់ថ្នាក់ខេត្តឡើយ។

នូវវិធានការវិន័យចំពោះបុគ្គលិកទាំងឡាយដែលរកឃើញថា បានប្រើប្រាស់ថវិកានោះមិនត្រឹមត្រូវ។ រាល់ពាក្យបណ្តឹងទាំងអស់ ត្រូវបានកត់ត្រាទុកក្នុងបញ្ជី ហើយរាល់សេចក្តីសំរេចទាំងឡាយ ត្រូវរាយការណ៍ឡើងទៅក្រុមការងារគណនេយ្យភាពថ្នាក់ជាតិ (មាត្រា ៤-៦)។

មានវិធីបីយ៉ាងដើម្បីប្តឹងទៅក្រុមការងារគណនេយ្យភាព។ បណ្តឹងអាចធ្វើដោយផ្ទាល់មាត់ទៅកាន់សមាជិកណាម្នាក់នៃក្រុមការងារ ដែលបន្ទាប់មកមានកាតព្វកិច្ចជួយរៀបចំរបាយការណ៍ជាលាយល័ក្ខណ៍អក្សរទាក់ទងនឹងការចោទប្រកាន់នោះ (មាត្រា ៨)។ លើសពីនេះ ក្រុមការងារនេះត្រូវចែកប័ណ្ណព័ត៌មានស្តីពីគណនេយ្យភាព ដែលមានផ្នែកមួយសំរាប់សរសេរពាក្យបណ្តឹង។ មកពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរនេះក្រោយមក ត្រូវផ្ញើទៅក្រុមការងារ (មាត្រា ៥-៨)។ ចំណុចចុងក្រោយ ជាពិសេសសំរាប់ក្រុមការងារគឺត្រូវបង្កើតប្រអប់ដាក់ពាក្យបណ្តឹង ហើយដាក់វានៅសាលាខេត្ត-ក្រុង សាលាស្រុក-ខណ្ឌ និងសាលាឃុំ-សង្កាត់ទាំងអស់។ ប្រអប់ដាក់ពាក្យបណ្តឹងនោះ ក៏អាចដាក់នៅតាមការិយាល័យអង្គការសង្គមស៊ីវិលផងដែរ។ ប្រជាពលរដ្ឋអាចដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរក្នុងប្រអប់ពាក្យបណ្តឹងនោះ។ ទំរង់នៃពាក្យបណ្តឹងត្រូវមាននៅតាមគ្រប់ប្រអប់ពាក្យបណ្តឹងទាំងអស់។ ទំរង់នៃពាក្យបណ្តឹងមិនតម្រូវឱ្យកំណត់អត្តសញ្ញាណឡើយ ហើយភាគច្រើននៃពាក្យបណ្តឹងដែលបានទទួលបាន មានលក្ខណៈអនាមិក។ ទោះជាយ៉ាងនេះក្តី ក្នុងករណីខ្លះពាក្យបណ្តឹងមានឈ្មោះ និងអាស័យដ្ឋានរបស់អ្នកប្តឹង។

នៅពេលដែលបានទទួល និងចុះបញ្ជីពាក្យបណ្តឹងហើយ ក្រុមការងារគណនេយ្យភាពត្រូវសំរេចដោយការបោះឆ្នោតយកមតិភាគច្រើន ថាតើពាក្យបណ្តឹងមួយណាដែលត្រូវស៊ើបអង្កេត និងបន្ទាប់ពីស៊ើបអង្កេតចប់សព្វគ្រប់ តើវិធានការវិន័យណាខ្លះដែលត្រូវអនុវត្ត បើសិនជារកឃើញកំហុស (មាត្រា ៩)។ ទណ្ឌកម្មខាងវិន័យ មានទំរង់ច្រើនយ៉ាង។ សំរាប់មន្ត្រីរាជការ ដែលត្រូវបានរកឃើញថា បានប្រើប្រាស់មិនត្រឹមត្រូវនូវថវិកាឃុំ-សង្កាត់ ឬទទួលសំណូក រូបគេនឹងត្រូវបញ្ឈប់ពីការងារ ហើយលទ្ធផលនៃការស៊ើបអង្កេត នឹងត្រូវបញ្ជូនទៅសាមីក្រសួង ដើម្បីសំរេចវិធានការវិន័យ ក្រោមច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល (សូមមើលឧបសម្ព័ន្ធ ២ អំពីវិធានការខាងវិន័យ សំរាប់ជនណាដែលរំលោភលើបញ្ហាគណនេយ្យភាព)។ វិធានការខាងវិន័យក្រោមច្បាប់ស្តីពីមន្ត្រីរាជការស៊ីវិល បានរៀបរាប់ពីខាងលើរួចហើយក្នុងផ្នែក IV (ក)។ បុគ្គលិកដែលត្រូវបានរកឃើញថាបានប្រើប្រាស់ថវិកាមិនត្រឹមត្រូវ នឹងត្រូវបញ្ឈប់ពីការងារ រីឯអ្នកជាប់កិច្ចសន្យា ឬផ្គត់ផ្គង់ដែលសូកប៉ាន់មន្ត្រីឃុំ-សង្កាត់ នឹងត្រូវបញ្ចប់កិច្ចសន្យា ហើយពួកគេនឹងត្រូវហាមឃាត់មិនឱ្យចូលរួមក្នុងការដេញថ្លៃគំរោងថ្នាក់ឃុំតទៅទៀត។ នៅទីបំផុត សមាជិកក្រុមប្រឹក្សាឃុំដែលត្រូវបានរកឃើញថាមានពាក់ព័ន្ធនឹងបញ្ហាគណនេយ្យភាព នឹងត្រូវរាយការណ៍ទៅក្រសួងមហាផ្ទៃ ហើយអាចត្រូវគេដកចេញ។ នៅក្នុងឯកសារស្តីពីក្រុមការងារគណនេយ្យភាព មិនមាននិយាយអំពីការបញ្ជូនលទ្ធផលនៃការស៊ើបអង្កេតទៅព្រះរាជអាជ្ញាទេ បើទោះជាជាសកម្មភាពដែលត្រូវហាមឃាត់មួយចំនួន អាចជាបទល្មើសនៅក្រោមច្បាប់អ៊ុនតាក់ក៏ដោយ។

នៅក្នុងបទសំភាសន៍មួយ តំណាងក្រសួងមហាផ្ទៃបានបញ្ជាក់ហើយបញ្ជាក់ទៀតថា ក្រុមការងារគណនេយ្យភាពមិនត្រូវបង្កើតឡើងសំរាប់ប្រឆាំងអំពើពុករលួយទេ។ ផ្ទុយទៅវិញ ក្រុមការងារនេះត្រូវគេ

បង្កើតឡើងដើម្បីពង្រឹងគណនេយ្យភាពទាក់ទងនឹងការប្រើប្រាស់ថវិកាឃុំ-សង្កាត់។លើសពីនេះ ក្រុមការងារនេះ គ្រាន់តែជាផ្នែកនៃប្រព័ន្ធយន្តការរួមមួយ ដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនគណនេយ្យភាព ក្នុងរបៀបចាយប្រាក់របស់ឃុំ-សង្កាត់។ ទោះជាយ៉ាងណាក៏ដោយ ក្រុមការងារនេះមានមុខងារដែលអាចយកទៅប្រើដើម្បីស៊ើបអង្កេតពីអំពើពុករលួយបាន។

ឥឡូវនេះ ក្រុមការងារគណនេយ្យភាពកំពុងប្រតិបត្តិនៅគ្រប់ខេត្តទាំងអស់ ហើយចាប់តាំងពីខែមិថុនា ឆ្នាំ ២០០៥ មក ទទួលបានពាក្យបណ្តឹងចំនួន ៥៩ អំពីការប្រើប្រាស់ថវិកាមិនត្រឹមត្រូវ។ ក្នុងចំណោមពាក្យបណ្តឹងទាំងនោះ មានចំនួន ១១ករណីត្រូវបានដោះស្រាយចប់សព្វគ្រប់។ ដំណោះស្រាយទាំងនោះរួមមាន ការបញ្ឈប់ការងារបុគ្គលិកថ្នាក់ស្រុក ការបញ្ចប់កិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់ ការព្រមានជាលាយ-លក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំឱ្យធ្វើតាមនីតិវិធីសមស្របនៅពេលចាយវាយថវិកាឃុំ។

មន្ត្រីមកពីក្រសួងមហាផ្ទៃបានបញ្ជាក់ថា ក្រុមការងារគណនេយ្យភាពទទួលបានពាក្យបណ្តឹងអំពីអំពើពុករលួយ ដែលមិនពាក់ព័ន្ធនឹងថវិកាឃុំ-សង្កាត់។ ក៏ប៉ុន្តែ ក្រុមការងារនោះមិនបានចាត់វិធានការលើបណ្តឹងទាំងនោះឡើយ ដោយសារតែខ្លួនគ្មានសិទ្ធិដើម្បីស៊ើបអង្កេតអំពើពុករលួយ លើកលែងតែបណ្តឹងដែលទាក់ទងនឹងថវិកាឃុំ-សង្កាត់។ ជាទូទៅ ក្រសួងមហាផ្ទៃពេញចិត្តនឹងការងាររបស់ក្រុមការងារគណនេយ្យភាព ហើយកំពុងពិចារណាលើសំណើផ្សេងៗ ដើម្បីការពង្រីកទំហំការងាររបស់ក្រុមការងារនេះ។

## ច. អាជ្ញាធរសវនកម្មជាតិ និង នាយកដ្ឋានសវនកម្មនៅតាមក្រសួងនានា

អាជ្ញាធរសវនកម្មជាតិត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០០ ដើម្បីធ្វើសវនកម្មលើ "ប្រតិបត្តិការ-សេដ្ឋកិច្ច គណនី ប្រព័ន្ធ ការត្រួតពិនិត្យ ប្រតិបត្តិការ និងកម្មវិធីរបស់ស្ថាប័នរដ្ឋាភិបាល ស្របតាមបទដ្ឋានសវនកម្មដែលទទួលយកបានជាទូទៅ..." (សូមមើលច្បាប់សវនកម្ម មាត្រា ១)។ តួនាទីដោយឡែកមួយរបស់អាជ្ញាធរសវនកម្មជាតិ គឺដើម្បីធានាថា "*ការត្រួតពិនិត្យ នីតិវិធី និងការអនុវត្ត*" នៅក្នុងក្រសួងនាយកដ្ឋាន និងភ្នាក់ងារនានា "*មានលក្ខណៈគ្រប់គ្រាន់ដើម្បីធានាអនុលោមភាព*" ស្របតាមច្បាប់ និងលិខិតបទដ្ឋានរបស់ប្រទេសកម្ពុជា (មាត្រា ៤.គ)។ អាជ្ញាធរសវនកម្មជាតិក៏មានតួនាទីធ្វើសវនកម្មលើ "*ភាពត្រឹមត្រូវ និងពេញលេញ ... របស់ទិន្នន័យហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់ក្រសួង...*" (មាត្រា ៥)។ ទោះបីជាពាក្យ *អំពើពុករលួយ* មិនមាននិយាយនៅក្នុងច្បាប់ក៏ដោយ ក៏អាជ្ញាធរសវនកម្ម ពិតជាមានតួនាទីក្នុងការទប់ស្កាត់អំពើពុករលួយ ហើយក៏ជាឧបករណ៍មួយដើម្បីឆ្លើយតបនឹងអំពើពុករលួយដែរ។

ដើម្បីបំពេញតួនាទីរបស់ខ្លួន អាជ្ញាធរសវនកម្មជាតិមានអំណាចដើម្បីប្រមូលព័ត៌មាននានា។ អគ្គសវនករដែលជាប្រធានអាជ្ញាធរសវនកម្មជាតិ មានអំណាចស្នើសុំឯកសារពីក្រសួងនានា ហើយបង្គាប់ឱ្យមន្ត្រីក្រសួងនោះចូលខ្លួនមកឆ្លើយបំភ្លឺ (មាត្រា ៣០)។ លើសពីនេះ មន្ត្រីអាជ្ញាធរសវនកម្មជាតិ អាចចូលទៅក្នុងទីតាំងនៃស្ថាប័នណាមួយ ដែលកំពុងត្រូវបានធ្វើសវនកម្ម ហើយមានសិទ្ធិពេញលេញ និងដោយសេរីក្នុងការពិនិត្យឯកសារ និងបញ្ជីស្នាមរបស់ស្ថាប័ននោះ (មាត្រា ៣២)។ ទណ្ឌកម្មសំរាប់ការរារាំងរំខានដល់សវនកម្ម

គឺការផាកពិន័យពី ១លាន ទៅ ៥លានរៀល ឬជាប់ពន្ធនាគារពី ១ខែ ដល់ ៣ ខែ ឬទណ្ឌកម្មទាំងពីរនេះរួមគ្នាតែម្តង។ ការដាក់ទណ្ឌកម្មសំរាប់ការផ្តល់ពត៌មានមិនពិតទៅឱ្យអាជ្ញាធរសវនកម្មជាតិ រួមមានការផាកពិន័យជាប្រាក់ ៥លានរៀល ឬច្រើនជាងនេះ ការដាក់គុកពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ ឬទណ្ឌកម្មទាំងពីរ (មាត្រា ៤៤, ៤៥ ) ។

អគ្គសវនករត្រូវជូនដំណឹងទៅរដ្ឋសភា ព្រឹទ្ធសភា គណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ នៅពេលណាដែលបានរកឃើញពី "*ភាពមិនប្រក្រតីធ្ងន់ធ្ងរ*" នៅក្នុងគណនី (មាត្រា ២៤)។ លើសពីនេះ អាជ្ញាធរសវនករ ត្រូវចេញផ្សាយរបាយការណ៍ជាសាធារណៈអំពីសវនកម្មនីមួយៗដែលបានធ្វើឡើង (មាត្រា ២២ ២៥ និង ២៩)។ តែទោះជាយ៉ាងណា របាយការណ៍សវនកម្មនៅតែត្រូវជាឯកសារសម្ងាត់ ប្រសិនបើមានព័ត៌មានដែលអាច "ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ កិច្ចការការពារជាតិ ឬបូរណភាព" របស់ប្រទេសកម្ពុជា ឬបើសិនជារបាយការណ៍នោះ "ធ្វើឱ្យប៉ះពាល់ដោយអយុត្តិធម៌ ដល់ផលប្រយោជន៍ពាណិជ្ជកម្មរបស់នីតិបុគ្គល ឬរូបវន្តបុគ្គលណាមួយ " (មាត្រា ៣៨ )។ មានភាពមិនច្បាស់លាស់ឡើយ ថាតើរបាយការណ៍បែបនេះមានផ្សាយជាសាធារណៈឬអត់ [៤០]។

នៅក្នុងការអនុវត្តជាក់ស្តែង ក្រសួងដែលមានអំណាច ដូចជាក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ មើលទៅហាក់ដូចជាមិនត្រូវបានធ្វើសវនកម្មទាល់តែសោះ ក្នុងខណៈដែលក្រសួងមិនសូវមានអំណាច ត្រូវការពេលច្រើនឆ្នាំ ដើម្បីឆ្លើយតបទៅនឹងសំណើសុំព័ត៌មានពីអាជ្ញាធរសវនកម្មជាតិ។ អស់រយៈពេលជាច្រើនឆ្នាំ អាជ្ញាធរសវនកម្មជាតិបានពន្យាពេលមិនធ្វើសវនកម្មថវិកាជាតិ ហើយបានយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ស្តីពីក្រសួងដែលខ្លួនបានធ្វើសវនកម្ម [៤១]។ ក្នុងករណីខ្លះ អាជ្ញាធរសវនកម្មជាតិហាក់ដូចជាមិនបានធ្វើសវនកម្មដើម្បីឆ្លើយតបនឹងការចោទប្រកាន់របស់សាធារណជនពីអំពើពុករលួយឡើយ [៤២]។ តាមការស្រាវជ្រាវលើឯកសារសាធារណៈ គេមិនអាចរកភស្តុតាងឃើញថា សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ នាំឱ្យមានការកាត់ទោសពីបទព្រហ្មទណ្ឌចំពោះសកម្មភាពទាំងឡាយដែលទាក់ទងនឹងអំពើពុករលួយឡើយ។

ក្រៅពីការបង្កើតឱ្យមានអាជ្ញាធរសវនកម្មជាតិ ច្បាប់ស្តីសវនកម្មក៏បានបង្កើតឱ្យមាននាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅតាមក្រសួងនីមួយៗផងដែរ (សូមមើលច្បាប់ស្តីពីសវនកម្ម មាត្រា ៤១, ៤៣)។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនេះ ត្រូវមាន " *ភារកិច្ចធ្វើការពិនិត្យ និងវាយតំលៃដោយឯករាជ្យ លើប្រសិទ្ធភាពក្នុងការអនុវត្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ* " (មាត្រា ៤២)។

---

[៤០] អ្នកនិពន្ធបានស្វែងរករបាយការណ៍ដែលបោះពុម្ពដោយអាជ្ញាធរសវនកម្មជាតិ តែមិនអាចរកបាន។

[៤១] សូមអាន " *អាជ្ញាធរសវនកម្មបន្ទោសក្រសួងអំពីការយឺតយ៉ាវខាងថវិកា* " ភ្នំពេញប៉ុស្តិ៍ លេខ ១៤/០៣ ថ្ងៃទី ១១-២៤ កុម្ភៈ ២០០៥ ។ សូមអានផងដែរ " *អាជ្ញាធរសវនកម្មបញ្ចប់របាយការណ៍ស្តីពីថវិកាក្រសួង* " ភ្នំពេញប៉ុស្តិ៍ លេខ ១៣/០១ ថ្ងៃ ២-១៥ មករា ២០០៤។

[៤២] អាជ្ញាធរសវនកម្មសន្យាថានឹងធ្វើសវនកម្មលើការចោទប្រកាន់ពីអំពើពុករលួយ ដែលធនាគារពិភពលោកបានលើកឡើងកាលពីពេលថ្មីៗនេះ អំពីគំរោងដែលខ្លួនផ្តល់ថវិកាឱ្យ។ សូមអានផងដែរនូវអត្ថបទ " *ការចោទប្រកាន់ និងការចោទប្រកាន់តបវិញ* " ភ្នំពេញប៉ុស្តិ៍ លេខ ១៥/១៣ ៣០ មិថុនា-១៣ កក្កដា ២០០៦។

នាយកដ្ឋានទាំងនោះ ត្រូវរាយការណ៍ទៅអ្នកទទួលខុសត្រូវក្រសួងរបស់ខ្លួន ប៉ុន្តែមិនមែនរាយការណ៍ផ្ទាល់ទៅអាជ្ញាធរសវនកម្មជាតិនោះទេ។ ដូច្នេះគេមិនដឹងថា នាយកដ្ឋានទាំងនោះមានឯករាជ្យភាពប៉ុណ្ណាឡើយ ហៅក្នុងការអនុវត្តការងារ។ លើសពីនេះ នាយកដ្ឋានសវនកម្មផ្ទៃក្នុងទាំងនោះហាក់ដូចជាមិនមានអំណាចក្នុងការប្រមូលព័ត៌មានដូចអាជ្ញាធរសវនកម្មជាតិឡើយ[៤៣]។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានរិះគន់ជាសាធារណៈចំពោះមន្ត្រីហិរញ្ញវត្ថុ និងមន្ត្រីសវនកម្មថា ជា " *មេគាបយកប្រាក់* " ពីរដ្ឋ ។ យោងតាមនាយករដ្ឋមន្ត្រី មន្ត្រីអធិការកិច្ចតាមក្រសួងនីមួយៗ គាបយកប្រាក់ពីនាយកដ្ឋាននានាក្នុងក្រសួង ដោយគំរាមរាយការណ៍ពីភាពមិនប្រក្រតី បើសិនជានាយកដ្ឋានទាំងនោះមិនបង់ប្រាក់ឱ្យខ្លួន[៤៤]។

### ឆ. រដ្ឋសភា

ទាំងស្ថាប័នរដ្ឋសភានិងព្រឹទ្ធសភា សុទ្ធតែមានស្ថាប័នដែលទទួលខុសត្រូវក្នុងការប្រឆាំង អំពើពុក-រលួយ។ នៅក្នុងរដ្ឋសភា គឺគណៈកម្មការទី៤ ដែលទទួលបន្ទុកមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ។ នៅក្នុងព្រឹទ្ធសភា អង្គភាពដែលសំខាន់ជាងគេ គឺគណៈកម្មការទទួលបន្ទុកមហាផ្ទៃ ការពារជាតិ និងប្រឆាំងអំពើពុករលួយ។ គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៅក្នុងរដ្ឋសភា និងព្រឹទ្ធសភាក៏មានតួនាទីប្រឆាំងនឹងអំពើពុករលួយដែរ ពីព្រោះគណកម្មការទាំងនោះជាអ្នកទទួលរបាយការណ៍សវនកម្ម ដែលធ្វើឡើងដោយអាជ្ញាធរសវនកម្មជាតិ (សូមមើល ផ្នែក IV.ឆ )។ មានពត៌មានតិចតួចបំផុតត្រូវបានផ្សព្វផ្សាយជាសាធារណៈអំពីប្រតិបត្តិការរបស់ស្ថាប័នទាំងនេះ ហើយផ្នែកខាងក្រោមនេះជាពត៌មានបានពីកិច្ចសំភាសន៍។

គណៈកម្មការទាំង២នេះ មិនមានអំណាចស៊ើបអង្កេតជាផ្លូវការឡើយ ហើយក៏មិនមានបុគ្គលិកថវិកា និងជំនាញដើម្បីអនុវត្តការស៊ើបអង្កេតអំពើពុករលួយដែរ[៤៥]។ ទោះជាយ៉ាងណាក៏ដោយ ក៏គណៈកម្មការទាំងពីរនេះ ទទួលបាន ពាក្យបណ្តឹងអំពីអំពើពុករលួយយ៉ាងទៀងទាត់។ ជាពិសេសសមាជិករដ្ឋសភាត្រូវបានជំរុញឱ្យពិគ្រោះជាមួយម្ចាស់ឆ្នោតដោយទៀងទាត់ ហើយពាក្យបណ្តឹងស្តីពីអំពើពុករលួយត្រូវបានលើកឡើងក្នុងពេលពិគ្រោះយោបល់ជាសាធារណៈ។ ក្រៅពីនេះ គណៈកម្មការសិទ្ធិមនុស្ស នៃស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា ក៏ទទួលពាក្យបណ្តឹងដែរ ដែលក្នុងនោះមានបណ្តឹងខ្លះទាក់ទងនឹងអំពើពុករលួយ។ ក៏ដូចជាគណៈ

---

[៤៣] មាត្រាដែលបង្កើតឱ្យមាននាយកដ្ឋានសវនកម្មផ្ទៃក្នុង មិនបាននិយាយអំពីការប្រមូលពត៌មាន ហើយប្រការទាំងឡាយស្តីពីការប្រមូលព័ត៌មាននៅក្នុងច្បាប់ស្តីពីសវនកម្ម គឺមានកំរិតយ៉ាងខ្លាំងសំរាប់អាជ្ញាធរសវនកម្ម។

[៤៤] សូមអាន " សម្តេចហ៊ុន សែនៈ *ខ្មោះដៃបានត្រៀមជាស្រេចសំរាប់មន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*" ព្រឹត្តិបត្រកញ្ចក់សង្គម ចុះថ្ងៃទី ១៥-២១ ឧសភា ២០០៥ ទំព័រទី៦-៧។

[៤៥] តាមពិតអ្នកជំនាញការម្នាក់បានស្នើឡើងថា គណៈកម្មការរបស់ព្រឹទ្ធសភាអាចមិនមានអំណាចត្រួតពិនិត្យឡើយ ពីព្រោះតួនាទីរបស់ព្រឹទ្ធសភា ត្រូវបានចែងយ៉ាងចង្អៀតនៅក្នុងរដ្ឋធម្មនុញ្ញ ហើយមិនមានរាប់បញ្ចូលការត្រួតពិនិត្យលើការអនុវត្តច្បាប់ឡើយ។

កម្មការប្រឆាំងអំពើពុករលួយដែរ គណៈកម្មការសិទ្ធិមនុស្សមិនមានបុគ្គលិក ថវិកា ឬជំនាញដើម្បីធ្វើការស៊ើបអង្កេតឡើយ។

មធ្យោបាយសំខាន់សំរាប់អ្នកតំណាងរាស្ត្រ ក្នុងការឆ្លើយតបនឹងបណ្តឹងពីអំពើពុករលួយ គឺការអញ្ជើញមន្ត្រីរដ្ឋាភិបាលឱ្យចូលមកឆ្លើយបំភ្លឺ ចំពោះពាក្យបណ្តឹងដែលលើកឡើងក្នុងសវនាការសាធារណៈ។ កំណត់ហេតុពីសវនាការនេះ ត្រូវទុកជាផ្នែកមួយនៃឯកសារសាធារណៈ ទោះជាពេលខ្លះគេពិបាករកវាក៏ដោយ។ ជារឿយៗមន្ត្រីរដ្ឋាភិបាលចូលខ្លួនមកបំភ្លឺ បើសិនជាមានការអញ្ជើញពីប្រធានគណៈកម្មការ តែជាទូទៅមន្ត្រីទាំងនោះមិនចូលខ្លួនមកបំភ្លឺឡើយ បើសិនជាការអញ្ជើញនោះធ្វើឡើងដោយសមាជិកថ្នាក់ទាប។ គេមិនបានដឹងប្រាកដថា ការដោះស្រាយតាមវិធីនេះ កើតឡើងញឹកញាប់ប៉ុណ្ណានោះឡើយ។

មធ្យោបាយមួយទៀតដែលគណៈកម្មការអាចយកទៅប្រើបាន គឺការសរសេរលិខិតទៅក្រសួង ឬស្ថាប័នរដ្ឋដែលពាក់ព័ន្ធ ដើម្បីសុំព័ត៌មាន ស្នើសុំធ្វើការស៊ើបអង្កេត ឬជំរុញឱ្យដោះស្រាយ បណ្តឹងស្តីពីអំពើ-ពុករលួយ។ ក៏ប៉ុន្តែ ក្នុងករណីជាច្រើន រាជរដ្ឋាភិបាលមិនបានឆ្លើយតបនឹងលិខិតទាំងនោះឡើយ។ ការណ៍នេះមើលទៅដូចជាមិនមានយន្តការណាមួយដើម្បីតាមដាន ថាតើរាជរដ្ឋាភិបាលបានដោះស្រាយត្រឹមត្រូវនូវបណ្តឹងដែលតំណាងរាស្ត្របញ្ជូនទៅឱ្យ យ៉ាងណានោះទេ។ តំណាងរាស្ត្រក៏អាចព្យាយាមលើកឡើងនូវបញ្ហាពុករលួយជាក់លាក់ណាមួយ តាមការជជែកវែកញែកបណ្តឹងនោះជាមួយអ្នកសារព័ត៌មាន។ គ្មានគណៈកម្មការណាមួយបានផ្តល់របាយការណ៍ទៀងទាត់ពីការងារ ឬការរកឃើញរបស់ខ្លួនឡើយ។

## ៥. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ( MONASRI ) បង្កើតឡើងដោយច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងឆ្នាំ ១៩៩៩។ ក៏ប៉ុន្តែច្បាប់នោះមានលក្ខណៈសង្ខេបខ្លាំងពេក ដោយទុកឱ្យសេចក្តីលំអិតអំពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងនោះ ចែងនៅក្នុងអនុក្រឹត្យមួយទៅវិញ បន្ទាប់ពីច្បាប់នោះត្រូវបានប្រកាសឱ្យប្រើ (សូមមើលច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច មាត្រា ៤ លេខ រស/រកម/ ០៦៩៩/០៥ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៩)។ MONASRI មានតួនាទីពីរគឺ: ១)រក្សាទំនាក់ទំនងរវាងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ២)ត្រួតពិនិត្យប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការរំលោភអំណាច និងការប្រព្រឹត្តិខុសផ្សេងៗទៀត (មាត្រា ២ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងទំនាក់ទំនងជាមួយសភា ព្រឹទ្ធសភា និងអធិការកិច្ច លេខ ៦៧/-អនក្រ/បក ចុះថ្ងៃទី ៣ សីហា ១៩៩៩)។ ក្នុងវិស័យអធិការកិច្ច MONASRI មានភារកិច្ច: ១) ត្រួតពិនិត្យ និងសើរើការងាររបស់នាយកដ្ឋានអធិការកិច្ចនៅតាមក្រសួង និងខេត្ត-ក្រុងនីមួយៗ ២)ស៊ើបអង្កេតការចោទប្រកាន់ពីការប្រព្រឹត្តិមិនត្រឹមត្រូវ ឬអំពើពុករលួយ ក្នុងចំណោមមន្ត្រីរាជការ នគរបាល ឬយោធិន និង ៣)រៀបចំរបាយការណ៍

ការងារខ្លួនជូនរាជរដ្ឋាភិបាល (សូមមើល អនុក្រិត្យស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច មាត្រា ៣(ខ) ១១_១៥)។

MONASRI មានអំណាចស៊ើបអង្កេតយ៉ាងទូលំទូលាយ។ ជាឧទាហរណ៍ ក្រសួងមានលទ្ធភាពសួរចម្លើយជនជាប់សង្ស័យពីអំពើពុករលួយ ស្រាវជ្រាវនិងប្រមូលឯកសារ ហើយថែមទាំងព្យួរការងារបុគ្គលណាដែលបដិសេធមិនសហការជាមួយការស៊ើបអង្កេតរបស់ MONASRI ទៀតផង (មាត្រា ៣(ខ) និង ១០)។ ក៏ប៉ុន្តែ ក្រសួងនេះមិនមានឯករាជ្យភាពឡើយ។ ក្រសួងធ្វើតែការងារណាដែល រាជរដ្ឋាភិបាលចាត់ឱ្យធ្វើតែប៉ុណ្ណោះ ហើយរាយការណ៍ផ្ទាល់ជូននាយករដ្ឋមន្ត្រី (មាត្រា ៣.ខ)។ ក្រសួងអាចផ្សព្វផ្សាយរបាយការណ៍របស់ខ្លួនជាសាធារណៈបាន លុះត្រាតែរបាយការណ៍នោះបានត្រួតពិនិត្យ និងឯកភាពដោយរាជរដ្ឋាភិបាល ហើយក្រសួងអាចបញ្ជូនសំណុំរឿងប្រព្រឹត្តិខុសឆ្គងនោះទៅតុលាការបាន លុះត្រាតែនាយករដ្ឋមន្ត្រីឯកភាពសិន (មាត្រា ៣.ខ.១៥)។ នៅក្នុងអគ្គនាយកដ្ឋានអធិការកិច្ច របស់ MONASRI មាននាយកដ្ឋាន "ទទួលពាក្យបណ្តឹង និងស៊ើបអង្កេត" ដែលមានតួនាទី ទទួល និងស៊ើបអង្កេតពាក្យបណ្តឹងពីសាធារណជន និងស៊ើបអង្កេតការចោទប្រកាន់ពីអំពើពុករលួយដែលចេញផ្សាយតាមសារពត៌មាន (មាត្រា ១៤)។

និយាយដោយចំហ MONASRI បានសំរេចជោគជ័យលើការងារពីរ។ ទីមួយ កាលពីឆ្នាំ ២០០៣ ក្រសួងបានដឹកនាំការកែប្រែសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ។ ដោយមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិមួយចំនួន រួមទាំងអង្គការផេកកម្ពុជាផង និងអង្គការសង្គមស៊ីវិលមួយចំនួន MONASRI បានធ្វើការកែសំរួលសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ដែលបានដាក់ជូនទៅរដ្ឋសភាក្នុងឆ្នាំ ២០០៣ តែខកខានមិនបានអនុម័ត។ គេសង្ឃឹមថាសេចក្តីព្រាងច្បាប់នោះអាចដាក់ជូនទៅរដ្ឋសភាក្នុងឆ្នាំ ២០០៦។

ទីពីរ ក្រសួងបានធ្វើការស៊ើបអង្កេតអំពើពុករលួយធំៗមួយចំនួន ។ ជាឧទាហរណ៍ ក្នុងឆ្នាំ ២០០៥ ក្រសួងបានចេញរបាយការណ៍មួយមានចំណងជើងថា " របាយការណ៍ឆ្នាំកន្លងមក និងផែនការសំរាប់ឆ្នាំ ២០០៥" ដែលបានរកឃើញថា រដ្ឋាភិបាលកម្ពុជាបានបាត់បង់ថវិកាសរុប ២៦.៣ លានដុល្លារ ដោយសារអំពើពុករលួយក្នុង ៩ ករណីដែលបានរាយការណ៍[៤៦]។ លើសពីនេះ គឺ MONASRI នេះហើយដែលបានដឹកនាំការស៊ើបអង្កេតរបស់រាជរដ្ឋាភិបាលកម្ពុជា ទៅលើការចោទប្រកាន់ពីបទកេងបន្លំ និងអំពើពុករលួយក្នុងកម្មវិធីមួយចំនួនរបស់ធនាគារពិភពលោក ដែលនាំឱ្យធនាគារពិភពលោកផ្អាកការផ្តល់ថវិកាដល់គំរោងជាច្រើន កាលពីខែមិថុនា ឆ្នាំ២០០៦[៤៧]។ MONASRI ក៏បានស៊ើបអង្កេតទៅលើការិយាល័យគយ នៅក្រុង

---

[៤៦] យោងតាមមន្ត្រី MONASRI រវាងឆ្នាំ១៩៩៩ និងឆ្នាំ ២០០៥ MONASRI បានទទួល និងស៊ើបអង្កេត ៥៣ ពាក្យបណ្តឹង ។ សូមអាន " *ក្រសួងអធិការរាយការណ៍ថាប្រាក់ ៣០ លានដុល្លារ ដែលបាត់ដោយអំពើពុករលួយ*" Development Weekly លេខ២១៤ ថ្ងៃទី ២៣_២៩ ឧសភា ២០០៥ ទំព័រ ១១។ ម្យ៉ាងវិញទៀត របាយការណ៍ឆ្នាំ ២០០៥ គឺជារបាយការណ៍ទីមួយហើយ ដែល MONASRI បានធ្វើចាប់តាំងពីបង្កើតក្រសួងនេះឡើងក្នុងឆ្នាំ ១៩៩៩ មក បើទោះជាក្រសួងត្រូវធ្វើរបាយការណ៍អធិការកិច្ចជារៀងរាល់ឆ្នាំក៏ដោយ។

[៤៧] សូមអាន " *ធ្វើការដើម្បីឱ្យប្រទេសកម្ពុជារួចផុតពីភាពក្រីក្រ*" របាយការណ៍របស់ធនាគារពិភពលោក ខែកក្កដា ២០០៦ ទំព័រ ២៥។

ព្រះសីហនុដែរ បន្ទាប់ពីមានការចោទប្រកាន់ពីអំពើពុករលួយពាក់ព័ន្ធនឹងមន្ត្រីគយ [៤៨]។ យ៉ាងហោច ក៏មាន មានករណីមួយដែរ ពោលគឺការចោទប្រកាន់របស់ធនាគារពិភពលោកពីអំពើពុករលួយ ត្រូវបានធ្វើការស៊ើប អង្កេតដែលនាំឱ្យមានការចោទប្រកាន់លើបុគ្គលម្នាក់ [៤៩]។

### ឈ. អង្គភាពប្រឆាំងអំពើពុករលួយ

នៅក្នុងគណៈរដ្ឋមន្ត្រី មានអង្គភាពមួយដែលមានឈ្មោះថា ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដែល ទទួលបន្ទុកអនុវត្តកម្មវិធីកំណែទំរង់រដ្ឋបាលរបស់រាជរដ្ឋាភិបាល (សូមមើលអនុក្រិត្យស្តីពីការបង្កើតក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល ចុះថ្ងៃទី ១០ មិថុនា ១៩៩៩ មាត្រា ១)។ នៅក្នុងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានអង្គភាពមួយទៀត មានឈ្មោះថា "*អង្គភាពប្រឆាំងអំពើពុករលួយ* "។ អង្គភាពប្រឆាំងអំពើពុករលួយ គឺជាអង្គភាពដែលទើបបង្កើតឡើងកាលពីពេលថ្មីៗ ជំនួសឱ្យអង្គភាពចាស់ដែលមានឈ្មោះថា "អង្គភាពប្រឆាំង សកម្មភាពពុករលួយ ( Entity Against Corruption Activities) " [៥០]។

អង្គភាពក្រោយនេះ ទទួលតួនាទីជាច្រើន បន្តពីអង្គភាពចាស់ ដែលក្នុងនោះរួមមាន:

១. ប្រមូលឯកសារ និងពត៌មានទាក់ទងនឹងអំពើពុករលួយ

២. រៀបចំផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលស្តីពីអំពើពុករលួយ និង

៣. អនុវត្តវិធានការប្រឆាំងអំពើពុករលួយរបស់រាជរដ្ឋាភិបាល

សូមមើលអនុក្រិត្យស្តីពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី ២២ សីហា ២០០៦ មាត្រា ៣។ ក៏ប៉ុន្តែ អង្គភាពប្រឆាំងអំពើពុករលួយ ក៏មានកិច្ចការ និងតួនាទីថ្មីដែលអង្គភាពចាស់គ្មានដែរ។ អ្វីដែលសំខាន់នោះគឺ ឥឡូវនេះអង្គភាពថ្មីមានអាណត្តិមួយច្បាស់លាស់ ដើម្បីទទួល និងស៊ើបអង្កេតពាក្យ បណ្តឹងពីអំពើពុករលួយតាមរយៈ "ផ្នែកស៊ើបអង្កេត" របស់ខ្លួន (មាត្រា ៧)។ អង្គភាពប្រឆាំងអំពើពុករលួយ ហាក់ដូចជាមិនមានអំណាចស៊ើបអង្កេតថ្មីឡើយ (ដូចជាអំណាចកោះហៅឱ្យផ្តល់ឯកសារ ឬបង្ខំមន្ត្រីរដ្ឋា ភិបាលឱ្យឆ្លើយបំភ្លឺ ) ហើយអង្គភាពទំនងជានឹងធ្វើការ " ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច"។ គេមិនដឹងច្បាស់ថា របៀបធ្វើការបែបនេះនឹងមានប្រសិទ្ធិភាពប៉ុណ្ណាឡើយ។ ជាឧទាហរណ៍ គេមិនដឹងច្បាស់ ថាតើអង្គភាពប្រឆាំងអំពើពុករលួយនឹងធ្វើដូចម្តេច បើសិនជាអាជ្ញាធរមានសមត្ថកិច្ចបដិសេធមិនសហការ។

---

[៤៨] សូមអាន " *ក្រសួងអធិការកិច្ចនឹងចុះស្វែងរកការពិតពីមន្ត្រីគយក្រុងព្រះសីហនុ ក្នុងរយៈពេល ១ខែ* " ព្រឹត្តិបត្រ កញ្ចក់សង្គម ថ្ងៃ ៣០ មករា ២០០៥-៥ កុម្ភៈ ២០០៥ ទំព័រ ១០-១១

[៤៩] កំណត់សំគាល់ ១៨។

[៥០] អង្គភាពប្រឆាំងសកម្មភាពពុករលួយ បានត្រូវបង្កើតដោយអនុក្រិត្យ ស្តីពីការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ចុះថ្ងៃទី ២៧ តុលា ១៩៩៩។ អង្គភាពប្រឆាំងអំពើពុករលួយថ្មីមួយទៀតបានជំនួសឱ្យអង្គភាពនេះ តាមរយៈអនុក្រិត្យស្តីពីការបង្កើតអង្គភាពប្រឆាំង អំពើពុករលួយ ចុះថ្ងៃទី ២២ សីហា ២០០៦ ។ មើល មាត្រា ១១ ( ចូរសំគាល់ថា អនុក្រិត្យឆ្នាំ ២០០៦ បានធ្វើឱ្យមោឃៈនូវអនុក្រិត្យឆ្នាំ ១៩៩៩។

ក្រៅពីការទទួល និងស៊ើបអង្កេតពាក្យបណ្តឹង អង្គភាពប្រឆាំងអំពើពុករលួយក៏មាន ផ្នែកជំរុញការអនុវត្តច្បាប់ (មាត្រា ៨ )ផងដែរ។ ការងារមួយរបស់ផ្នែកជំរុញការអនុវត្តច្បាប់ គឺការសហការជាមួយនគរបាលយុត្តិធម៌ ដើម្បីផ្តល់ពត៌មានចាំបាច់សំរាប់ធ្វើការចោទប្រកាន់ជាផ្លូវការពីបទព្រហ្មទណ្ឌ ចំពោះបុគ្គលនានា ។ ការណ៍នេះគឺជាជំហានវិជ្ជមានមួយ ដោយសារកន្លងមកអំពើពុករលួយត្រូវបានចាត់ទុកជាករណីរដ្ឋបាល ដែលអាចដោះស្រាយដោយផ្ទៃក្នុងស្ថាប័នតែប៉ុណ្ណោះ ជាជាងចាត់ទុកជាបទព្រហ្មទណ្ឌ។

អង្គភាពប្រឆាំងនឹងអំពើពុករលួយចាស់ មានបុគ្គលិកសំខាន់ៗតែ ៥-៦នាក់ប៉ុណ្ណោះ ហើយភាគច្រើនទំនងជាមានភាពអសកម្ម។ដូចនេះអង្គភាពប្រឆាំងអំពើពុករលួយចាស់ មិនមែនជាយន្តការប្រឆាំងអំពើពុក-រលួយដ៏មានប្រសិទ្ធភាពឡើយ។ ដោយសារ អង្គភាពប្រឆាំងអំពើពុករលួយក្រោយនេះទើបនឹងបង្កើតឡើងថ្មី ដូចនេះ គេមិនទាន់ដឹងថាអង្គភាពមានថវិកាគ្រប់គ្រាន់ និងមានបុគ្គលិក ដែលមានការបណ្តុះបណ្តាល ដើម្បីធ្វើការដោយប្រសិទ្ធភាពយ៉ាងណានោះទេ។ ទោះជាយ៉ាងនេះក្តី តាមឯកសារ អង្គភាពថ្មីទំនងជាប្រសើរជាងអង្គភាពចាស់។

### ៣. មេធាវី

ជាទូទៅ មេធាវីមិនមែនជាមន្ត្រីរាជការទេ [៥១] ដូច្នេះជាធម្មតាមិនអាចប្រព្រឹត្តិអំពើពុករលួយបានដូចដែលបានកំណត់ក្នុងច្បាប់អ៊ុនតាក់ឡើយ ទោះបីគេអាចមានទោសពីបទការសូកប៉ាន់ក៏ដោយ [៥២]។ តែទោះ ជាយ៉ាងណាមេធាវីត្រូវបានគ្រប់គ្រងដោយច្បាប់ ហើយតំរូវឱ្យគោរពបទដ្ឋានសីលធម៌មួយចំនួន។ " មេធាវីណាដែលរំលោភវិធាន និងធ្វើសកម្មភាពដែលប៉ះពាល់ដល់ក្រមសីលធម៌ និងកិត្តិយសរបស់មេធាវីត្រូវទទួលទណ្ឌកម្មខាងវិន័យ ... " (សូមមើលច្បាប់ស្តីពីគណៈមេធាវី មាត្រា ៥៩)។ ទោះបីជាក្រមសីលធម៌របស់គណៈមេធាវី មិនឆ្លើយតបផ្ទាល់ទៅនឹងអំពើពុករលួយក៏ដោយ ក៏វាបានហាមឃាត់ទង្វើណាដែលផ្ទុយនឹងច្បាប់ដែរ (សូមមើលក្រមសីលធម៌ មាត្រា ៦)។ អាចសន្មតបានថា ក្រមសីលធម៌នេះ គ្របដណ្តប់ដល់ការចូលរួមក្នុងសកម្មភាពពុករលួយទាំងឡាយ ដែលក្នុងនោះរួមមានការស៊ីសំណូក សូកប៉ាន់ផងដែរ។

មេធាវីអាចត្រូវបានចោទប្រកាន់ពីបទរំលោភក្រមសីលធម៌ ពីសំណាក់សាធារណជន អគ្គព្រះរាជ-អាជ្ញាអមសាលាឧទ្ធរណ៍ ឬដោយផ្ទាល់ពីក្រុមប្រឹក្សាគណៈមេធាវី។ បណ្តឹងត្រូវធ្វើផ្ទាល់ទៅក្រុមប្រឹក្សាគណៈមេធាវី (ស្ថាប័នគ្រប់គ្រងរបស់គណៈមេធាវី) ហើយក្រុមប្រឹក្សាគណៈមេធាវីនឹងចាត់តាំងមេធាវីឱ្យ

---

[៥១] មេធាវីភាគច្រើនបំផុត ធ្វើការជាឯកជន។ ជាការពិត ច្បាប់ស្តីពីគណៈមេធាវីចែងថា វិជ្ជាជីវៈមេធាវីមានវិសមិតភាពជាមួយ "មុខងារសាធារណៈ" ហើយច្បាប់នោះរារាំងមេធាវីមិនឱ្យប្រកបវិជ្ជាជីវៈឡើយ បើសិនជាគេមានមុខតំណែងណាមួយក្នុងរដ្ឋាភិបាល។ សូមមើល ច្បាប់ស្តីពីគណៈមេធាវី មាត្រា ៥៣។

[៥២] តាមពិត នៅក្នុងបទសម្ភាសន៍ខ្លះជាមួយនឹងមេធាវីកម្ពុជា ពួកគេបានប្រាប់អ្នកនិពន្ធថា មេធាវីខ្លះដើរតួជាអន្តរការីរត់ការសូកប៉ាន់ រវាងកូនក្តីរបស់ខ្លួនជាមួយនឹងបុគ្គលិកតុលាការ ។ មេធាវីណាដែលបានជួយរត់ការសូកប៉ាន់ ធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធផលរបស់តុលាការ នឹងមានទោសពីបទសូកប៉ាន់ ក្រោមមាត្រា ៥៨ នៃច្បាប់អ៊ុនតាក់។

ស៊ើបអង្កេតលើបណ្តឹងនោះ (សូមមើលច្បាប់ស្តីពីគណៈមេធាវី មាត្រា ៦០)។ មេធាវីស៊ើបអង្កេតនឹងរៀបចំរបាយការណ៍មួយ ហើយផ្តល់ឱ្យភាគីទាំងអស់។ បន្ទាប់មក ក្រុមប្រឹក្សាគណៈមេធាវីប្រជុំពិភាក្សាលើករណីនេះ ស្តាប់ពីមេធាវីជាប់ចោទ រួចចេញសេចក្តីសំរេចដែលត្រូវមាន "មូលហេតុច្បាស់លាស់" សំរាប់សេចក្តីសំរេចនោះ (មាត្រា ៦០-៦១)។ ក្នុងសេចក្តីសំរេចរបស់ខ្លួន ក្រុមប្រឹក្សាគណៈមេធាវីអាចដាក់ទណ្ឌកម្មមួយ ឬច្រើន ដូចខាងក្រោមៈ ១) ព្រមាន ២)ដាក់ឱ្យសាកល្បងរហូតដល់ ៥ ឆ្នាំ ៣)មិនឱ្យប្រកបវិជ្ជាជីវៈផ្នែកច្បាប់រហូតដល់ ២ ឆ្នាំ ៤)ហាមឃាត់មិនឱ្យចូលជាក្រុមប្រឹក្សាគណៈមេធាវីរហូតដល់ ៥ ឆ្នាំ និង ៥)បណ្តេញចេញពីការប្រកបវិជ្ជាជីវៈផ្នែកច្បាប់ (មាត្រា ៦៣-៦៥)។ ទាំងភាគីអ្នកប្តឹង ទាំងមេធាវីជាប់ចោទ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចប្តឹងជំទាស់នឹងសេចក្តីសំរេចរបស់គណៈមេធាវីទៅសាលាឧទ្ធរណ៍បាន (មាត្រា ២៤ ២៥ ៦២)។

ជាការគួរឱ្យសោកស្តាយ ចាប់តាំងពីចុងឆ្នាំ ២០០៤មក គណៈមេធាវីបានគាំងសកម្មភាព ដោយសារតែវិវាទក្នុងរឿងជ្រើសរើសប្រធាន រវាងបេក្ខជនពីរនាក់ដែលទាមទារថាខ្លួនជាប្រធានពេញសិទ្ធិតែរៀងខ្លួន [៥៣]។ វិវាទនោះបានធ្វើឱ្យគណៈមេធាវី ស្ទើរតែមិនបានប្រជុំទាល់តែសោះ ក្នុងឆ្នាំ ២០០៥ និង២០០៦ ពីព្រោះគ្មានភាគីណាមួយមានអ្នកគាំទ្រគ្រប់គ្រាន់ ដើម្បីបំពេញកូរ៉ុម។

## III. យន្តការមិនផ្លូវការ

ថ្វីបើមានយន្តការផ្លូវការជាច្រើនសំរាប់ដោះស្រាយនឹងអំពើពុករលួយ ដែលមួយចំនួនត្រូវបានលើកយកមកពិភាក្សាខាងលើនោះ ការសិក្សាពីផលប៉ះពាល់នៃអំពើពុករលួយ បានបង្ហាញស្របគ្នាថា ជនក្រីក្រតាមជនបទ (ដែលជាចំនួនភាគច្រើននៃពលរដ្ឋកម្ពុជាទាំងអស់) មិនបានប្រើប្រាស់យន្តការជាផ្លូវការនេះដើម្បីដោះស្រាយទំនាស់នោះឡើយ [៥៤]។ តាមពិត អំពើពុករលួយភាគច្រើន មិនត្រូវបានរាយការណ៍ ឬដោះស្រាយតាមវិធីណាមួយឡើយ។ សកម្មភាពប្រឆាំងនឹងអំពើពុករលួយ ឬអំពើខុសច្បាប់ហាក់ដូចជាកើតឡើងញឹកញាប់បំផុត នៅពេលដែលអំពើនោះប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួនច្រើននៅក្នុងពេលតែមួយ ហើយមានលទ្ធភាពសំរាប់ដោះស្រាយជាសមូហភាព។ ក៏ប៉ុន្តែ បើទោះជាមានវិធានការជាសមូហភាពក៏ដោយ ក៏សកម្មភាពនោះហាក់ដូចជាមិនដើរតាមវិធានជាផ្លូវការសំរាប់រាយការណ៍ ឬដោះស្រាយអំពើពុករលួយឡើយ។

---

[៥៣] សូមអាន "*វិវាទរឿងតំណែងប្រធាន បានបែងចែកគណៈមេធាវីកម្ពុជា*" ភ្នំពេញប៉ុស្តិ៍ លេខ ១៣/២៣ ថ្ងៃទី ៥-១៨ វិច្ឆិកា ២០០៤។

[៥៤] ផ្នែកនេះ ភាគច្រើនផ្អែកលើការសិក្សាចំនួនបីកាលពីពេលថ្មីៗ ស្តីអំពីអំពើពុករលួយៈ ១) "*អំពើពុករលួយ និងគ្រួសារកម្ពុជា*" ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (ខែមិនា ឆ្នាំ ២០០៥), ២) "*រស់នៅក្រោមវិធាននៃអំពើពុករលួយ*" ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (ខែមិនា ឆ្នាំ ២០០៥) និង ៣) "*យុត្តិធម៌សំរាប់ជនក្រីក្រ?*" ដោយមជ្ឈមណ្ឌលសំរាប់ការសិក្សាជាន់ខ្ពស់ និងធនាគារពិភពលោក (នឹងចេញក្នុងឆ្នាំ ២០០៦)។ ផ្នែកនេះត្រូវបានបំពេញបន្ថែម ដោយពត៌មានពីកិច្ចសំភាសន៍ជាមួយអ្នកដែលជិតស្និទនឹងបញ្ហា ដែលក្នុងនោះរួមមានមន្ត្រីរាជការ អ្នកពិគ្រោះឯកជន និងបុគ្គលិកអង្គការអន្តរជាតិ។

នៅពេលអំពើពុករលួយកើតឡើងលើបុគ្គល ឬគ្រួសារតែមួយ ប្រជាពលរដ្ឋកម្ពុជាច្រើនតែព្យាយាមដោះស្រាយដោយមិនរាយការណ៍។

## គ. ការឆ្លើយតបជាលក្ខណៈបុគ្គលចំពោះអំពើពុករលួយ

អំពើពុករលួយភាគច្រើនកើតឡើងលើបុគ្គល ឬគ្រួសារតែមួយ។ នៅក្នុងគ្រួសារ ស្ត្រីជាអ្នកប្រឈមញឹកញាប់បំផុតនឹងអំពើពុករលួយ និងត្រូវបានបង្ខំឱ្យសូកប៉ាន់។ ករណីនេះទំនងជាដោយសារតាមទម្លាប់ស្ត្រីជាអ្នកកាន់ប្រាក់កាសក្នុងគ្រួសារ។ ជាឧទាហរណ៍ ជាធម្មតាស្ត្រីជាអ្នកទៅផ្សារទិញម្ហូប នាំកូនទៅពេទ្យ ជូនកូនទៅសាលា និងទៅការិយាល័យរដ្ឋបាលដើម្បីសុំលិខិតស្នាមផ្លូវការ។ ដូច្នេះ ស្ត្រីអាចប្រឈមនឹងស្ថានភាពគ្រប់បែបយ៉ាង ដែលពេលខ្លះចាំបាច់ត្រូវបង់ប្រាក់អំពើពុករលួយ។

អំពើពុករលួយដែលអ្នកទីក្រុង និងអ្នកជនបទបានជួបប្រទះ គឺមានលក្ខណៈខុសគ្នា។ ជាមធ្យមអ្នកទីក្រុងក្នុងមួយគ្រួសារៗ បង់ប្រាក់ច្រើនជាងគេសំរាប់អំពើពុករលួយ (ប្រហែលជាដោយសារគេប្រើសេវារដ្ឋាភិបាលច្រើន) តែបើគិតជារួមវិញ គ្រួសារនៅជនបទបង់ប្រាក់ច្រើនជាងគេសំរាប់អំពើពុករលួយ ពីព្រោះអ្នកជនបទមានចំនួនច្រើនជាងអ្នកក្រុង។ គ្រួសារតាមជនបទជួបប្រទះនឹងអំពើពុករលួយ នៅពេលគេទាក់ទងជាមួយអ្នកផ្តល់សេវាសាធារណៈនៅឯមូលដ្ឋាន ជាពិសេសនគរបាល សាលារៀន និងការសុខាភិបាលសាធារណៈ។ អ្នកជនបទកំរទាក់ទងណាស់ជាមួយតុលាការ រដ្ឋាភិបាលកណ្តាល ឬសូម្បីតែថ្នាក់ស្រុក ឬថ្នាក់ខេត្ត ក៏ដោយ។ ជនក្រីក្រក៏មិនសូវជឿជាក់ដែរលើនគរបាល តុលាការ និងរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន (ដូចជាក្រុមប្រឹក្សាឃុំ ឬសាលាស្រុក)។ ដូច្នេះ គេស្ទាក់ស្ទើរនឹងប្រើប្រាស់រចនាសម្ព័ន្ធទាំងនេះ ដើម្បីដោះស្រាយអំពើពុករលួយណាស់។ ភាគច្រើននៃប្រជាពលរដ្ឋក្រីក្រនៅជនបទយល់ថា ការរាយការណ៍ពីពុករលួយជាផ្លូវការគឺជាការខាតពេល (ដោយមិនរំពឹងថារដ្ឋាភិបាលនឹងចាត់ការឱ្យមាំទាំ) ហើយអាចជាការប្រថុយគ្រោះថ្នាក់ខ្លាំង (ព្រោះអ្នកដែលត្រូវគេប្តឹង ជារឿយៗស្ថិតក្នុងតំណែងមានអំណាច ដែលអាចយកទៅប្រើប្រឆាំងនឹងអ្នកប្តឹងបាន)។ យោងតាមលទ្ធផលនៃការស្ទាបស្ទង់មតិមួយដែលធ្វើឡើងនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ២០០១ ដែលមានឈ្មោះថា International Crime Vitim Survey មានតែ ១ភាគរយ នៃជនរងគ្រោះដោយសារអំពើពុករលួយប៉ុណ្ណោះ ដែលបានរាយការណ៍ទៅនគរបាល។ ផ្ទុយទៅវិញ ១០០ភាគរយនៃជនរងគ្រោះដោយចោរលួចទ្រព្យ បានរាយការណ៍ពីចោរ ហើយជាង៥០ភាគរយនៃជនរងគ្រោះដោយចោរប្លន់ បានរាយការណ៍ពីករណីចោរប្លន់[៥៥]។

ប្រជាពលរដ្ឋខ្មែរភាគច្រើនមិនចូលចិត្តអំពើពុករលួយ ហើយទទួលស្គាល់ថាវាមានផលជាអវិជ្ជមានដល់ជីវភាពរស់នៅ និងសិទ្ធិរបស់ខ្លួនក្នុងការទទួលបានសេវា ប៉ុន្តែពួកគេមានអារម្មណ៍ថាមិនមានអំណាចដើម្បីធ្វើដោះស្រាយរឿងនោះ។ ជាជាងព្យាយាមដោះស្រាយអំពើពុករលួយ មនុស្សភាគច្រើនសុខចិត្តចៀស

---

[៥៥] សូមអាន របាយការណ៍បណ្តោះអាសន្នស្តីពីរដ្ឋបាលរបស់ International Crime Victim Survey for Cambodia ថ្ងៃទី ២៧ មិនា ឆ្នាំ ២០០២ ដោយគំរោងជំនួយយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា។

វាងវា។ យន្តការនៃការចៀសវាង មានលក្ខណៈខុសគ្នា។ អ្នកខ្លះជៀសវាងមិនប្រើសេវាសាធារណៈតែម្តង ពីព្រោះពួកគេមិនមានលទ្ធភាពបង់ប្រាក់តាមដែលគេតំរូវឱ្យបង់។ ជាឧទាហរណ៍ ប្រជាពលរដ្ឋអាចមិនទៅធ្វើសំបុត្រកំណើតសំរាប់កូន ហើយអាចមិនទៅចុះឈ្មោះជាមួយអាជ្ញាមូលដ្ឋាន។ ប្រជាពលរដ្ឋអាចសុខចិត្តដោះដូរស្បៀងអាហារជាមួយអ្នកជិតខាង ជាជាងទៅផ្សារដែលត្រូវបង្ខំចិត្តឱ្យបង់សំណូកនៅតាមផ្លូវ។ បើមានលទ្ធភាព ប្រជាពលរដ្ឋភាគច្រើនសុខចិត្តបញ្ជូនកូនទៅរៀននៅសាលារៀនឯកជន និងទៅព្យាបាលជំងឺនៅគ្លីនិកឯកជន។

យន្តការចៀសវាងមួយទៀតគឺការព្យាយាមបង្កើតខ្សែរយៈផ្ទាល់ខ្លួន ដែលអាចកាត់បន្ថយដល់ផលប៉ះពាល់នៃអំពើពុករលួយ។ ការសិក្សាបង្ហាញថា បុគ្គលដែលមានទំនាក់ផ្ទាល់ខ្លួន ឬទំនាក់ទំនងគ្រួសារជាមួយមន្ត្រីដែលផ្តល់សេវា អាចជៀសវាង ឬកាត់បន្ថយការបង់ប្រាក់ពុករលួយ។ លើសពីនេះ ជនណាដែលមានបុណ្យសក្តិខ្ពស់ ជារឿយៗអាចជៀសផុតពីការបង់ប្រាក់ពុករលួយ ដោយសារតែមន្ត្រីដែលយកប្រាក់នោះខ្លាចញញើតនឹងបុណ្យសក្តិខ្ពស់។ ខ្សែរយៈ ឬការស្គាល់គ្នានៅក្នុងសង្គម មានសារៈសំខាន់ណាស់សំរាប់កាត់-បន្ថយផលប៉ះពាល់នៃអំពើពុករលួយនៅថ្នាក់ភូមិ និងថ្នាក់ឃុំ។ ជាការគួរឱ្យសោកស្តាយ អ្នកក្រដូចជាមិនមានខ្សែរយៈ ឬខ្នងក្រាស់នៅក្នុងសង្គមឡើយ ដូច្នេះហើយពួកគាត់គឺជាអ្នកងាយរងគ្រោះបំផុតពីអំពើពុករលួយ។

ប្រជាពលរដ្ឋក៏អាចចរចារលើចំនួនទឹកប្រាក់ដែលត្រូវបង់ដែរ។ រឿងនេះ ជារឿយៗពាក់ព័ន្ធនឹងការនិយាយកុហកអំពីចំនួនទឹកប្រាក់ដែលគ្រួសារនីមួយៗមាន។ ឧទាហរណ៍ នៅពេលមានការតំរូវឱ្យបង់ប្រាក់ ២០.០០០រៀល ពីសំណាក់មន្ត្រីនគរបាល គ្រួសារមួយអាចប្រកែកមិនបង់ក្នុងចំនួននោះ ដោយនិយាយថាខ្លួនក្រណាស់។ ជាយថាហេតុ ពួកគាត់អាចចរចារមកនៅត្រឹមចំនួន ៥.០០០ រៀល។ ក៏ប៉ុន្តែ ក្នុងករណីភាគច្រើន ចំនួនទឹកប្រាក់ដែលត្រូវបង់សំរាប់សេវាជាក់លាក់មួយ ហាក់ដូចជាត្រូវបានកំណត់តាមទម្លាប់ ដូចនេះមានឱកាសតិចតួចណាស់សំរាប់តថ្លៃ។

សូម្បីតែមន្ត្រីរាជការក៏និយាយថាមិនមានលទ្ធភាពប្តឹងពីអំពើពុករលួយដែរ ទោះបីជាតាមទ្រឹស្តី គឺស្ថិតនៅក្នុងស្ថានភាពប្រសើរដើម្បីប្តឹងក៏ដោយ។ មន្ត្រីរាជការ ហាក់មានការយល់ដឹងប្រសើរអំពីរចនាសម្ព័ន្ធនិងវិធានរដ្ឋាភិបាល ព្រមទាំងខ្សែរយៈច្រើននៅក្នុងសង្គម ហើយជាការពិតណាស់គឺខ្សែរយៈក្នុងសង្គមនេះហើយ ដែលរារាំងពួកគេមិនឱ្យធ្វើបណ្តឹង។ មន្ត្រីរាជការ ពឹងលើទំនាក់ទំនងខ្សែរយៈជាមួយថ្នាក់លើរបស់ខ្លួន ដើម្បីសុវត្ថិភាពការងារ ការឡើងឋានៈ និងទទួលបានការងារដែលអនុញ្ញាតឱ្យរកប្រាក់ក្រៅដើម្បីបន្ថែមលើប្រាក់ចំណូលរបស់ខ្លួន។ មានរបាយការណ៍មកថា មន្ត្រីទាំងនោះខ្លាចមិនហ៊ានប្តឹងពីអំពើពុករលួយទៅថ្នាក់លើឡើយ ពីព្រោះវាអាចបំផ្លាញទំនាក់ទំនងខ្សែរយៈ ដែលពួកគេ និងគ្រួសាររបស់គេពឹងពាក់។

មិនមានគ្រួសារណាមួយដែលគេបានស្ទាបស្ទង់មតិ បានរាយការណ៍ជាផ្លូវការពីអំពើពុករលួយឡើយ។ ក៏ប៉ុន្តែនៅពេលសួរថា តើពួកគេនឹងធ្វើយ៉ាងណាចំពោះអំពើពុករលួយ បើសិនជាគេមានអំណាចដើម្បីផ្លាស់ប្តូរវានោះ ចម្លើយពីរច្រើនជាងគេបំផុត គឺ: ១) បណ្តេញចេញ ឬ ដាក់គុកមន្ត្រីពុករលួយ និង ២) អនុវត្តច្បាប់ប្រឆាំងអំពើពុករលួយដែលមានស្រាប់។ ពិតជាមានតំរូវការឱ្យមានវិធានការប្រសើរឡើង ដើម្បី

ប្រឆាំងអំពើពុករលួយនៅថ្នាក់ភូមិ និងឃុំ-សង្កាត់ ទោះបីមានការលំបាកដើម្បីបង្កើតយន្តការដែលប្រជាពលរដ្ឋ មានអារម្មណ៍ងាយស្រួលក្នុងការប្រើក៏ដោយ។

## ខ. ការឆ្លើយតបជាសមូហភាពចំពោះអំពើពុករលួយ

ការសិក្សាថ្មីៗមួយដោយ *មជ្ឈមណ្ឌលសំរាប់ការសិក្សាជាន់ខ្ពស់* និង *ធនាគារពិភពលោក* ដែលមានចំណងជើងថា *"យុត្តិធម៌សំរាប់ជនក្រីក្រ?"* បានបង្ហាញពីប្រភេទនៃវិវាទមួយ ដែលនាំឱ្យមានការប្រឆាំងបែបសកម្ម ជាជាងបែបអកម្ម។ ចរិតលក្ខណៈដ៏សំខាន់មួយនៃវិវាទទាំងនេះ គឺវាពាក់ព័ន្ធចំនួនគ្រួសារច្រើន (ក្នុងករណីខ្លះមានដល់រាប់រយគ្រួសារ ) ដែលការណ៍នេះ វាបានផ្តល់នូវពិឱកាសសំរាប់ការប្រើវិធានការជាសមូហភាព។ គ្រប់ករណីដែលបានសិក្សាក្នុងរបាយការណ៍ ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទចាប់យកដី ក៏ប៉ុន្តែជារឿយៗ ករណីទាំងនោះមានជាប់ជាមួយនឹងការចោទប្រកាន់ថា មន្ត្រីរដ្ឋបាលមូលដ្ឋានពុករលួយ ឬឃុបឃិតជាមួយអ្នកខាងក្រៅ ដោយធ្វើឱ្យខូចប្រយោជន៍របស់ប្រជាពលរដ្ឋមូលដ្ឋាន។ក៏ប៉ុន្តែ ការចាប់យកដីទាំងអស់មិនមែនសុទ្ធតែនាំឱ្យមានសកម្មភាពជាសមូហភាពទេ។ សកម្មភាពដែលត្រូវធ្វើឡើង ឬអត់ គឺអាស្រ័យលើវត្តមានរបស់កត្តាដូចខាងក្រោម :

១. បញ្ហាប៉ះពាល់មនុស្សលើសពីម្នាក់ ឬលើសពីគ្រួសារមួយ ដែលជាហេតុនាំឱ្យមានការលើកទឹកចិត្តឱ្យបុគ្គលទាំងឡាយរួមគ្នាជាក្រុម ដើម្បីការពារសិទ្ធិរបស់ខ្លួន
២. វិវាទគឺជាបញ្ហាមួយសំខាន់ខ្លាំងដែលសមនឹងឱ្យប្រថុយ ដើម្បីការពារ (ដូចជកម្មសិទ្ធិដីធ្លី)
៣. វត្តមានរបស់អ្នកដឹកនាំមិនផ្លូវការនៅមូលដ្ឋាន [៥៦] ដែលអាចជួយសំរបសំរួលសកម្មភាពជាសមូហភាព
៤. លទ្ធភាពទទួលបានពត៌មានពីប្រភពខាងក្រៅ និងការគាំទ្រខាងការតស៊ូមតិ (ជារឿយៗតាមរយៈអង្គការ ឬគណបក្សនយោបាយ )
៥. ភាពដាច់ស្រយាលរបស់ភូមិ [៥៧] និង
៦. ការគាំទ្រពីគ្រហស្ថដែលមានទំនាក់ទំនងជាមួយគណៈកម្មការវត្ត។

នៅក្នុងគ្រប់វិវាទ មិនមែនសុទ្ធតែមានកត្តាទាំងនេះឡើយ ក៏ប៉ុន្តែកត្តាទាំងនេះដូចជាសំខាន់ណាស់សំរាប់កំណត់ ថាតើនឹងមានវិធានការជាសមូហភាព ឬអត់។

---

[៥៦] អ្នកដឹកនាំមូលដ្ឋាន កំរជាផ្នែកផ្លូវការនៃរដ្ឋបាលថ្នាក់ភូមិ និងឃុំ-សង្កាត់ ណាស់ ប៉ុន្តែជារឿយៗពួកគេមានបទពិសោធន៍ ដែលធ្វើឱ្យមានការគោរពនៅក្នុងសហគមន៍។ ជាឧទាហរណ៍ ដូចជា ការចេះអាន និងចេះសរសេរ បទពិសោធន៍ក្នុងគណៈកម្មការវត្ត ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល បទពិសោធន៍ជាមួយរដ្ឋបាលមូលដ្ឋានជាដើម។

[៥៧] ភូមិដែលមានសេវាវិទ្យុ ទូរទស្សន៍ ទូរស័ព្ទ និងផ្លូវថ្នល់ ហាក់ដូចជាងាយស្រួលក្នុងការចងក្រង។

ក្នុងករណីដែលមានវិធានការជាសមូហភាព កត្តាមួយដែលសំខាន់គឺថា យន្តការដោះស្រាយវិវាទផ្លូវការដូចដែលបានរៀបរាប់ក្នុងផ្នែកទី II និងទី III នៃរបាយការណ៍នេះ មិនត្រូវបានប្រើប្រាស់ឡើយ។ ថ្វីបើ ជារឿយៗពាក្យបណ្តឹងត្រូវបានសរសេរ និងផ្តិតមេដៃដោយអ្នកភូមិ ដែលជាវិធីបញ្ជាក់ពីឆន្ទៈរបស់គេដើម្បីធ្វើសកម្មភាពជាសមូហភាព ពាក្យបណ្តឹងទាំងនោះកំរនឹងត្រូវគេដោះស្រាយតាមច្រកផ្លូវការដែលចែងដោយច្បាប់ណាស់។ ផ្ទុយទៅវិញ រដ្ឋបាលថ្នាក់ភូមិ និងឃុំ-សង្កាត់ ជារឿយៗត្រូវប្រជារាស្ត្រមើលឃើញថាពុករលួយ ទទួលរងឥទ្ធិពលពីក្រៅ ស្ពឹកស្រពន់ ឬឃុបឃិតជាមួយអ្នកប្រព្រឹត្តិកំហុស [៥៨]។ ការព្យាយាមពីដំបូងៗ ដើម្បីរកដំណោះស្រាយមិនផ្លូវការជាមួយមេភូមិ ឬក្រុមប្រឹក្សាឃុំ-សង្កាត់ ជារឿយៗមិនត្រូវបានគេចាប់អារម្មណ៍ឡើយ ដោយសារតែមានជាការព្រមានកុំឱ្យបន្តរឿងនេះតទៅទៀត ឬដោយសារដឹងថាមន្ត្រីមូលដ្ឋានបានឃុបឃិតជាមួយជនបង្កបញ្ហា ។ ហេតុនេះ ទើបក្រុមភាគច្រើនដែលធ្វើសកម្មភាពជាសមូហភាព បានជៀសវាងរដ្ឋបាលថ្នាក់ភូមិ និងឃុំ-សង្កាត់ ហើយសុខចិត្តស្វែងរកអ្នកណាមួយនៅថ្នាក់លើ (នៅថ្នាក់ស្រុក ឬ ថ្នាក់ខេត្ត ) ដែលអាចធ្វើអន្តរាគមជួសមុខឱ្យខ្លួនបាន ។ នេះគឺជាការពិត នៅពេលដែលគេយល់ថា "អ្នកមានអំណាច" ពីខាងក្រៅភូមិ មានការពាក់ព័ន្ធជាមួយនឹងវិវាទ ដោយសារតែអាជ្ញាធរភូមិ និងឃុំ-សង្កាត់ ហាក់ដូចជាមិនអាចជួយដោះស្រាយវិវាទនោះបាន បើសិនជាវាពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលដែលមានឋានៈខ្ពស់ជាងខ្លួន។ ទស្សនៈមួយដែលគេដឹងជាទូទៅគឺថា មានតែអភិបាលខេត្តទេដែលមានអំណាចគ្រប់គ្រាន់ដើម្បីធានាឱ្យសេចក្តីសំរេចណាមួយដែលធ្វើឡើង ត្រូវគេគោរពតាម។ ក្នុងករណីសិក្សានីមួយៗ អ្នកមានអំណាច បុគ្គលដែលមានខ្នងក្រាស់ បានត្រួតត្រាលើដំណើរការដោះស្រាយវិវាទ ប៉ុន្តែមិនមែនបទបញ្ញត្តិ ឬច្បាប់ឡើយ។

ការពឹងផ្អែកទៅលើអន្តរាគមន៍របស់បុគ្គលដែលមានឋានៈខ្ពស់នៅក្នុងរដ្ឋាភិបាល ផ្តល់នូវលទ្ធផលដែលពិបាកនឹងទស្សន៍ទាយទុក ហើយអន្តរាគមន៍នោះកំរធ្វើឡើងស្របទៅតាមមូលដ្ឋានដែលច្បាប់បានចែងណាស់។ បើទោះជាអ្នកភូមិដែលបានធ្វើសកម្មភាពជាសមូហភាព ទំនងជាអាចទទួលជោគជ័យច្រើនជាងការដែលមិនធ្វើដូច្នោះក៏ដោយ ពួកគេកំរនឹងទទួលបាននូវអ្វីដែលច្បាប់ចែងថាពួកគេត្រូវទទួលបានណាស់។ ដូចនេះ លទ្ធផល បើទោះជាប្រសើរជាងការដែលមិនធ្វើសកម្មភាពសោះក៏ដោយ គឺមានលក្ខណៈមិនទៀង។ លើសពីនេះ គេសង្កេតឃើញថា បើសិនជាប្រជាពលរដ្ឋមិនជឿជាក់ថាអាជ្ញាធរឃុំ និងស្រុក នឹងដោះស្រាយវិវាទប្រកបដោយយុត្តិធម៌ និងតម្លាភាព ទាក់ទងអំពើពុករលួយ ឬអំពើខុសច្បាប់ទេនោះ ពួកគាត់ទំនងជាមិនប្រើប្រាស់យន្តការផ្លូវការឡើយ។ ផ្ទុយទៅវិញពួកគាត់នឹងព្យាយាមរត់ទៅរកអ្នកមានមុខតំណែងខ្ពស់ដែលមានអំណាចគ្របសង្កត់លើភាគីវិវាទម្ខាងទៀត។

---

[៥៨] ការសិក្សាជាច្រើនបានបង្ហាញថា សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ទទួលខុសត្រូវចំពោះគណបក្សរបស់ខ្លួន និងចំពោះរដ្ឋាភិបាលច្រើនជាង ចំពោះសាធារណជន។

## IV. សេចក្ដីសន្និដ្ឋាន

មានសេចក្ដីសន្និដ្ឋានជាច្រើនដែលអាចទាញចេញពីរបាយការណ៍នេះ។ សេចក្ដីសន្និដ្ឋានដែលជាក់ស្ដែងបំផុតនោះគឺថា មានអំពើពុករលួយច្រើនណាស់នៅក្នុងប្រទេសកម្ពុជា ហើយភាគច្រើនបំផុតមិនត្រូវបានរាយការណ៍ ស៊ើបអង្កេត ឬផ្ដន្ទាទោសឡើយ។ មានហេតុផលជាច្រើនសំរាប់ការសន្និដ្ឋាននេះ។ ជាឧទាហរណ៍ ប្រជាពលរដ្ឋជាច្រើនមិនរាយការណ៍ពីអំពើពុករលួយ ដោយសារពួកគាត់មិនជឿថា រដ្ឋាភិបាលនឹងចាត់វិធានការដើម្បីដោះស្រាយ និងដោយសារពួកគាត់ខ្លាចមានការសងសឹកចំពោះការរាយការណ៍។ លើសពីនេះ ប្រព័ន្ធខ្សែរយៈនៅក្នុងសេវាសាធារណៈ ធ្វើឱ្យមន្ត្រីរដ្ឋាភិបាលមានការពិបាកក្នុងការរាយការណ៍ពីអំពើពុករលួយ ដោយគ្មានគ្រោះថ្នាក់ដល់អាជីពរបស់ខ្លួន។ ជាការពិត ភាគច្រើននៃមន្ត្រីរាជការនៅមានបៀវត្សទាបណាស់សំរាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ដែលការណ៍នេះនាំឱ្យមានប្រព័ន្ធមួយដែលមន្ត្រីរាជការភាគច្រើន ត្រូវ *"រកបន្ថែម"* ពីលើចំណូលរបស់ខ្លួនតាមរយៈអំពើពុករលួយតូចតាច។ បញ្ហាមួយទៀតគឺថា ជំហររបស់រដ្ឋាភិបាលចំពោះអំពើពុករលួយ ទំនងជាមានលក្ខណៈប្រតិកម្ម ជាជាងរៀបជើងព្រួលទុក។ អំពើពុករលួយអាចត្រូវបានស៊ើបអង្កេត លុះត្រាតែវាធ្វើឱ្យរដ្ឋាភិបាលចាប់អារម្មណ៍ ប៉ុន្តែរដ្ឋាភិបាលប្រឹងប្រែងតិចបំផុត ដើម្បីស្វែងរកអំពើពុករលួយដោយខ្លួនឯង។ បញ្ហាធំបំផុត តាមមើលប្រហែលជាមនុស្សជាច្រើនដែលពុករលួយតែងតែបានផលពីអំពើពុករលួយ ហើយភាគតិចណាស់ដែលត្រូវបានផ្ដន្ទាទោស ដែលជាហេតុទោរទន់ទោរកអំពើពុករលួយ។

មានវិស័យជាច្រើនដែលទំនងជាមានការប្រសើរឡើង។ បើទោះជាចំនួននៃការផ្ដន្ទាទោសពីអំពើពុករលួយនៅតិចក៏ដោយ ហើយបើទោះជាអ្នកដែលត្រូវផ្ដន្ទាទោសជាមន្ត្រីរាជការថ្នាក់ទាបក៏ដោយ ការដែលមានការជំនុំជំរះពីអំពើពុករលួយ គឺសំខាន់ណាស់។ រយៈពេល៦-៧ឆ្នាំកន្លងទៅនេះ មិនធ្លាប់មានការជំនុំជំរះអំពីអំពើពុករលួយដោយប្រើច្បាប់អ៊ុនតាក់ឡើយ។ អាចនិយាយបានថា និន្នាការថ្មីៗនេះគឺជាចំណុចចាប់ផ្ដើមសំរាប់យុទ្ធនាការកាន់តែទូលាយក្នុងការផ្ដន្ទាទោសអំពើពុករលួយ។ ជាបណ្ដើរៗ តុលាការនឹងអាចបង្កើនចំនួនរឿងក្ដី ហើយនៅទីបំផុតតុលាការនឹងអាចស៊ើបអង្កេត និងកាត់ទោសសមាជិកជាន់ខ្ពស់របស់រដ្ឋាភិបាល។

មានវិធីជាច្រើនដែលអង្គការសង្គមស៊ីវិល គណបក្សនយោបាយ វិស័យឯកជន និងម្ចាស់ជំនួយ អាចជួយដល់យុទ្ធនាការនេះបាន។ វិធីតបតរបស់រដ្ឋាភិបាលសំរាប់ដោះស្រាយអំពើពុករលួយក្នុងពេលបច្ចុប្បន្ន អាចបណ្ដាលមកពីកត្តាជាច្រើន ដែលក្នុងនោះរួមមាន: ១) ខ្វះឆន្ទៈនយោបាយច្បាស់លាស់ ក្រៅតែពីវោហារសាស្ត្រនយោបាយ ២) ខ្វះមន្ត្រី ៣) ខ្វះការបណ្ដុះបណ្ដាល និង ៤) ខ្វះថវិកា។ ថ្វីបើម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល ប្រហែលជាមិនអាចជួយដល់ការខ្វះខាតឆន្ទៈនយោបាយក៏ដោយ តែគេក៏អាចជួយកាត់បន្ថយកត្តារាំងស្ទះមួយចំនួនដែរ។ ជំនួយនេះអាចមាន: ១) បណ្ដុះបណ្ដាលព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេត អំពីការផ្ដន្ទាទោសបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងអំពើពុករលួយដែលមានចែងរួចស្រាប់ ២)បណ្ដុះបណ្ដាលនគរបាលអំពីការស៊ើបអង្កេតបទឧក្រិដ្ឋទាក់ទងនឹងអំពើពុករលួយ ៣) ឧបត្ថម្ភថវិកាសំរាប់ការ

ស៊ើបអង្កេតអំពើពុករលួយ ដូចជាចេញសោហ៊ុយចំណាយសំរាប់ការធ្វើដំណើរ សំភារៈការិយាល័យ ជាដើម ៤)ផ្តល់ជំនួយថវិកា និងជំនួយបច្ចេកទេសដល់អង្គការក្នុងស្រុក ដែលធ្វើការខាងប្រឆាំងអំពើពុករលួយ នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ៥) បង្កើតសម្ព័ន្ធភាពដែលមានសម្លេងរឹងមាំ ដើម្បីទាមទារឱ្យរដ្ឋាភិបាល ចាត់វិធានការកាន់តែច្រើនឡើងក្នុងការដោះស្រាយអំពើពុករលួយ ៦)ជួយគណបក្សនយោបាយទាំងឡាយ ដើម្បីធ្វើឱ្យការប្រឆាំងអំពើពុករលួយ ក្លាយជាចំណុចនយោបាយដ៏សំខាន់របស់ខ្លួន ៧)ផ្តល់ការអប់រំដល់ វិស័យឯកជនអំពី ការទទួលខុសត្រូវផ្នែកសង្គមរបស់ក្រុមហ៊ុន ៨)ទាមទារឱ្យមានការជឿនលឿនថែមទៀត នូវកំណែទំរង់រដ្ឋបាល។ល។[៥៩] ជាការពិត ដើម្បីទទួលជោគជ័យ ទាមទារឱ្យមានការគាំទ្រ និងការប្តេជ្ញាចិត្ត ដើម្បីខិតខំដោះស្រាយអំពើពុករលួយ។ ទោះយ៉ាងនេះក្តី ការផ្តន្ទាទោសអំពើពុករលួយកាលពីពេលថ្មីៗនេះ អាចបង្ហាញពីឆន្ទៈនយោបាយចាំបាច់ ក្នុងការធ្វើឱ្យការផ្តល់ជំនួយជាវិនិយោគមួយមានប្រយោជន៍។

ចំណុចលេចធ្លោមួយទៀតនៅក្នុងរបាយការណ៍នេះគឺ ក្រុមការងារគណនេយ្យភាព។ ក្រុមការងារ នេះ មើលទៅគឺជាមធ្យោបាយមួយគួរឱ្យសង្ឃឹម ដើម្បីលើកកំពស់គណនេយ្យភាពរបស់រដ្ឋាភិបាលនៅថ្នាក់ភូមិ និងថ្នាក់ឃុំ-សង្កាត់។ ក្រុមការងារនេះមានចំណុចមួយចំនួនដែលប្លែក និងគួរឱ្យចាប់អារម្មណ៍ ដូចជា ១)ពាក្យបណ្តឹង អាចជាបណ្តឹងអនាមិក ដែលអាចលើកទឹកចិត្តប្រជាពលរដ្ឋដែលភ័យខ្លាចការសងសឹកឱ្យដាក់ ពាក្យបណ្តឹង ២)ប្រអប់ពាក្យបណ្តឹងដាក់នៅតាមឃុំ-សង្កាត់ ជាជាងដាក់នៅឯសាលាស្រុក និងសាលាខេត្ត ៣) ថ្នាក់ខេត្តជាអ្នកទទួល និងដោះស្រាយពាក្យបណ្តឹង ដែលការណ៍នេះអាចជួយទប់ស្កាត់ឥទ្ធិពលមិនសមស្រប របស់មន្ត្រីឃុំ-សង្កាត់ ទៅលើការស៊ើបអង្កេត ដោយសារមន្ត្រីឃុំជាកម្មវត្ថុនៃបណ្តឹង ៤) មានការចូលរួម ពីសង្គមស៊ីវិល ក្នុងការស៊ើបអង្កេត និងការដោះស្រាយពាក្យបណ្តឹង និង ៥)ក្រុមការងារគណនេយ្យភាព មានអំណាចដាក់ទណ្ឌកម្ម មន្ត្រីរដ្ឋាភិបាលដែលរកឃើញថាពាក់ព័ន្ធនឹងការ ប្រើប្រាស់មិនត្រឹមត្រូវនូវថវិកា ឃុំ-សង្កាត់។

ជាការពិត ក្រុមការងារគណនេយ្យភាព ក៏មានចំណុចរបស់ខ្លួនដែរ។ ចំណុចខ្សោយធំបំផុតគឺថា ក្រុមការងារមានអាណត្តិ ពិនិត្យតែលើបណ្តឹងដែលទាក់ទងនឹងការប្រើប្រាស់ថវិកាឃុំ-សង្កាត់ មិនត្រឹមត្រូវ ប៉ុណ្ណោះ។ ជាលទ្ធផល មានអំពើពុករលួយជាច្រើនប្រភេទទៀត ដែលក្រុមការងារគណនេយ្យភាពមិនបាន ធ្វើការស៊ើបអង្កេត។ មធ្យោបាយជាក់ស្តែងមួយដើម្បីកែលំអក្រុមការងារគណនេយ្យភាព គឺត្រូវពង្រីកតួនាទី របស់ក្រុមការងារនោះ ឱ្យគ្របដណ្តប់លើអំពើទុច្ចរិតដទៃទៀតរបស់មន្ត្រីថ្នាក់ឃុំ-សង្កាត់។ ជាការគួរសោកស្តាយ ដោយសារក្រសួងមហាផ្ទៃបានអះអាងថា ក្រុមការងារនេះមិនមែនជាយន្តការប្រឆាំងអំពើពុករលួយ ដូចនេះ មធ្យាបាយនេះមិនអាចទៅរួចឡើយ។ ទោះជាយ៉ាងណា មានមធ្យោបាយមួយចំនួនដើម្បីកែលំអប្រតិបត្តិការ របស់ក្រុមការងារនេះ ដោយមិនចំបាច់មានការពង្រីកតួនាទីរបស់ខ្លួន ហួសពីការពិនិត្យមើលការប្រើប្រាស់ មិនត្រឹមត្រូវនូវថវិកាឃុំ-សង្កាត់នោះឡើយ។ ជាឧទាហរណ៍ ក្រៅតែពីការស៊ើបអង្កេតងាយៗបំផុត ក្រុមការងារ

---

[៥៩] កម្មវិធីនីមួយៗ ត្រូវមានការត្រួតពិនិត្យដោយប្រយ័ត្នប្រយែង ដើម្បីធានាថាវាមិនបង្កើតឱ្យមានអំពើពុករលួយ ការកេងបំបាត់ និង អំពើទុច្ចរិតបន្ថែមទៀត ។

ទំនងជាមានជំនាញ ឬសមត្ថភាពតិចតួចបំផុតសំរាប់ធ្វើការងារដទៃទៀត។ វិធីមួយដើម្បីពង្រឹងក្រុមការងារនេះ អាចជាការផ្តល់ការបណ្តុះបណ្តាល ឬជួយពង្រឹងសមត្ថភាពក្នុងការស៊ើបអង្កេត។ រីឯវិធីមួយទៀតអាចជាការជំរុញឱ្យមានការចូលរួមកាន់តែច្រើនពីសង្គមស៊ីវិល ក្នុងក្រុមការងារនេះ ឬបង្កើនការចូលរួមវិភាគទានរបស់តំណាងសង្គមស៊ីវិលដែលមានស្រាប់នៅក្នុងក្រុមការងារ [៦០]។

សិទ្ធិទទួលបានពត៌មានក៏ជាបញ្ហាមួយដែរ ទាំងសំរាប់ក្រុមការងារគណនេយ្យភាព ក៏ដូចជាសង្គមខ្មែរទាំងមូល។ នៅក្នុងករណីក្រុមការងារគណនេយ្យភាព ទំនងជាមិនមានមធ្យោបាយណា ដើម្បីបញ្ជូនលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន ត្រឡប់ទៅឃុំ-សង្កាត់វិញឡើយ។ ដូច្នេះ ប្រជាពលរដ្ឋនៅក្នុងឃុំ-សង្កាត់ មិនអាចដឹងឡើយ ថាតើក្រុមការងារបានចាត់វិធានតាំងពីពេលណា ហើយជាវិធានការអ្វីខ្លះ ដែលការណ៍នេះអាចនាំឱ្យប្រជាពលរដ្ឋមិនទុកចិត្តលើដំណើរការនោះ។ ជាទូទៅ ពត៌មានអំពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ ស្តីពីអំពើពុករលួយ គឺពិបាករកណាស់។ កំណត់ត្រារបស់តុលាការមិនបើកចំហជាសាធារណៈឡើយ ហើយកំណត់ត្រាភាគច្រើនទាក់ទងនឹងការប្រព្រឹត្តទៅរបស់ក្រសួងទាំងឡាយ ក៏ដូច្នោះដែរ ។ សូម្បីតែច្បាប់ ក្រិត្យ អនុក្រិត្យដែលគ្រប់គ្រងប្រទេសកម្ពុជា ក៏ពិបាករកដែរ។ កង្វះតម្លាភាពនេះ ធ្វើឱ្យងាយស្រួលដល់ការប្រព្រឹត្តអំពើពុករលួយផង និងជួយលាក់បាំងបញ្ហាផង។ កង្វះតម្លាភាព ក៏ជាចំណែកក្នុងការមិនអើពើនឹងអំពើពុករលួយផងដែរ។ ការដែលប្រជាពលរដ្ឋកម្ពុជាមិនរាយការណ៍ពីអំពើពុករលួយ គឺដោយសារមួយចំណែកណានោះពួកគាត់មិនមានជំនឿថា រដ្ឋាភិបាលនឹងដោះស្រាយវា។ ដូចគ្នានេះដែរ ការគ្មានព័ត៌មានអំពអ្វីដែលរាជរដ្ឋាភិបាលកំពុងធ្វើនោះ ក៏ធ្វើឱ្យមានការបាត់ជំនឿលើរដ្ឋាភិបាលដែរ។

ការបង្កើនសិទ្ធិទទួលពត៌មានគ្រប់ប្រភេទ អាចជួយដោះស្រាយបញ្ហានេះ។ ជាឧទាហរណ៍ យោងតាមការសិក្សាកាលពីពេលថ្មីៗរបស់ធនាគារពិភពលោក [៦១] កត្តាមួយដែលនាំឱ្យមានវិធានការជាសមូហភាពប្រឆាំងអំពើពុករលួយ ភាគច្រើនគឺទំនងជាដោយសារមានលទ្ធភាពក្នុងការទទួលបានពត៌មាន ហើយជាទូទៅតាមរយៈអង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ។ ប្រជាពលរដ្ឋត្រូវការពត៌មានជាមូលដ្ឋាន ដូចជា : ១)និយមន័យនៃអំពើពុករលួយ និងផលប៉ះពាល់របស់វា ២)របៀបចងក្រងឯកសារពីអំពើពុករលួយ ៣) ទីកន្លែងដែលគេអាចប្តឹងបាន ៤)តើគេមានសិទ្ធិអ្វីខ្លះក្នុងនីតិវិធីធ្វើបណ្តឹង ៥)របៀបទទួលពត៌មានអំពីលទ្ធផលនៃពាក្យបណ្តឹងរបស់គេ ៦)ឯកសាររបស់រដ្ឋាភិបាលដែលជួយធ្វើឱ្យសំណុំរឿងរឹងមាំ ដូចជាឯកសារសម្បទានវិស័យឯកជន និង ៧) ការប្រឹក្សាយោបល់ជាមូលដ្ឋានស្តីពីការតស៊ូមតិ និងការចងក្រង

---

[៦០] មានលទ្ធភាពមួយចំនួនគួរឱ្យចាប់អារម្មណ៍ សំរាប់ធ្វើការជាមួយតំណាងសង្គមស៊ីវិលដែលមានស្រាប់។ ជាឧទាហរណ៍ គេអាចនាំអ្នកតំណាងអង្គការសង្គមស៊ីវិលទូទាំងប្រទេសកម្ពុជា មកជួបពិភាក្សាពីអ្វីដែលពួកគេបានរៀនសូត្រ ហើយស្វែងរកមធ្យោបាយ ដើម្បីកែលំអប្រព័ន្ធនេះ។ ឬមួយគេអាចរៀបចំឱ្យមានការប្រជុំទៀងទាត់នៅតាមឃុំ-សង្កាត់ រវាងតំណាងអង្គការសង្គមស៊ីវិល និងសាធារណជន ដើម្បីពិភាក្សាពីការងាររបស់ក្រុមការងារគណនេយ្យភាព។ គេក៏អាចធ្វើការជាមួយក្រុមសង្គមស៊ីវិលនៅតាមខេត្តនីមួយៗ ដើម្បីពង្រឹងដំណើរការនេះ ដោយធ្វើការជ្រើសរើសតំណាងម្នាក់នៃសង្គមស៊ីវិល ដែលមានលក្ខណៈរឹងមាំ និងចេះប្រុងជើងការ ។

[៦១] សូមមើល ផ្នែក ៥ (ខ)

កម្លាំង។ ម្ចាស់ជំនួយ និងអង្គការសង្គមស៊ីវិល អាចគាំទ្រ និងជួយដល់កិច្ចការនេះតាមរយៈការគាំទ្រដល់សិទ្ធិក្នុងការទទួលព័ត៌មាន ដូចដែលកំណត់នៅក្នុងសូចនាកររបស់ក្រុមពិគ្រោះយោបល់។ ការដែលគ្រាន់តែមានការយល់ដឹងកាន់តែប្រសើរឡើងរបស់សាធារណជនអំពីអំពើពុករលួយ និងវិធីដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយតែម្យ៉ាង នឹងមិនអាចដោះស្រាយបញ្ហាបានឡើយ [៦២] ក៏ប៉ុន្តែមូលហេតុដែលធ្វើឱ្យប្រជាពលរដ្ឋមិនរាយការណ៍ពីអំពើពុករលួយ ទំនងជាមកពីជំនឿដែលថា បើទោះជាពួកគេរាយការណ៍ក៏ដោយក៏គ្មានអ្វីប្លែកដែរ។ ម្យ៉ាងទៀត ប្រជាពលរដ្ឋដែលមានការយល់ដឹង មានលក្ខណៈងាយស្រួលក្នុងការប្រឆាំងអំពើពុករលួយ រាយការណ៍ពីអំពើពុករលួយ និងទាមទារឱ្យរដ្ឋាភិបាលធ្វើការកាន់តែច្រើនដើម្បីកំចាត់អំពើពុករលួយ ។

ខែមករា ឆ្នាំ ២០០៧

ពត៌មាននៅក្នុងឯកសារនេះមានភាពត្រឹមត្រូវបំផុត តាមអ្វីដែលជាចំណេះដឹង និងជំនឿរបស់អង្គការផេកកម្ពុជា។ អង្គការផេកកម្ពុជាស្វាគមន៍រាល់មតិយោបល់ ពត៌មានបន្ថែម ឬការកែតំរូវនានា។ សូមទាក់ទង លោក **សេក បរិសុទ្ធ** នាយកកម្មវិធីប្រឆាំងអំពើពុករលួយ sbarisoth@pactcambodia.org. ។

---

[៦២] រដ្ឋាភិបាលត្រូវមានធនធាន និងឆន្ទៈនយោបាយ ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ការដែលគ្រាន់តែមានពត៌មានច្រើន ពីអំពើ-ពុករលួយ ប៉ុន្តែមិនមានសកម្មភាពប្រឆាំងអំពើពុករលួយពិតប្រាកដ នៅទីបំផុត អាចនាំឱ្យប្រជាពលរដ្ឋបាត់ជំនឿទុកចិត្តកាន់តែខ្លាំងលើរដ្ឋាភិបាល។